# អគ្គិសនីកម្ពុជា

# ELECTRICITE DU CAMBODGE

# របាយការណ៍ប្រចាំឆ្នាំ២០១៥



# សេចក្តីថ្លែងការណ៍របស់ប្រធានក្រុមប្រឹក្សាភិបាល



តាងនាមឲ្យក្រុមប្រឹក្សាភិបាល ខ្ញុំសូមសំដែងនូវការកោតសរសើរយ៉ាងស្មោះចំពោះអគ្គិសនីកម្ពុជា ដែលបានបញ្ចេញនូវរបាយការណ៍ប្រចាំឆ្នាំ ២០១៥ ។ យើងមានមោទនភាព និងការកោតសរសើរចំពោះលទ្ធផល ដែលអគ្គិសនីកម្ពុជាសម្រេចបានអំឡុងឆ្នាំ ២០១៥ នឹងជឿជាក់យ៉ាងខ្លាំងថា អគ្គិសនីកម្ពុជានឹងឈានឆ្ពោះទៅកាន់ការសម្រេចបាននូវគោលដៅ និងចក្ខុវិស័យរបស់ខ្លួន ក្នុងគោលបំណង ដើម្បីឲ្យក្លាយជាក្រុមហ៊ុនឈានមុខគេលើវិស័យថាមពលនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយកសាងទំនាក់ទំនង និងសេវាកម្មល្អ ប្រកបដោយទំនុកចិត្ត ក្នុងការផ្គត់ផ្គង់អគ្គិសនីឲ្យបានគ្រប់គ្រាន់ និងតម្លៃសមរម្យជូនអតិថិជនរបស់ខ្លួន។

ក្នុងនាមជាប្រធានក្រុមប្រឹក្សាភិបាល ខ្ញុំមានសេចក្តីពេញចិត្តយ៉ាងខ្លាំង ចំពោះភាពជោគជ័យដ៏ធំធេងដែលនិយោជិត និយោជក របស់អគ្គិសនីកម្ពុជាសម្រេចបានក្នុងឆ្នាំកន្លងមក។ សមិទ្ធផលមានជាបន្តបន្ទាប់ប៉ុន្មានឆ្នាំកន្លងមកនេះ គឺជាសមិទ្ធផលដែលមិនធ្លាប់មានពីមុនមក។

ក្នុងឱកាសនេះ ខ្ញុំសូមសំដែងនូវអំណរគុណអស់ពីដួងចិត្តខ្ញុំផ្ទាល់ ចំពោះថ្នាក់ដឹកនាំ និងនិយោជិតអគ្គិសនីកម្ពុជាទាំងអស់ ដែលបានបំពេញការងារអស់ពីកម្លាំងកាយ និងកម្លាំងបញ្ញាស្មារតី ដែលធ្វើឲ្យសម្រេចបាននូវសមិទ្ធផលជាច្រើនកន្លងមក ដើម្បីឈានដល់ទិសដៅ និងចក្ខុវិស័យរបស់ខ្លួន។

**ប្រធានក្រុមប្រឹក្សាភិបាល**



**វិចន័រ ហ្សូនា**

# ពីប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា អគ្គនាយកអគ្គិសនីកម្ពុជា



ខ្ញុំមានមោទនភាព និងសូមបង្ហាញជូននូវរបាយការណ៍ប្រចាំឆ្នាំ២០១៥ ដែលអគ្គិសនីកម្ពុជាទទួលបាន ដែលជាចំណុចរបត់ថ្មីមួយទៀតនៅក្នុងការអភិវឌ្ឍន៍វិស័យថាមពលក្នុងព្រះរាជាណាចក្រកម្ពុជា។ ចក្ខុវិស័យរបស់អគ្គិសនីកម្ពុជា គឺធ្វើយ៉ាងណាឲ្យក្លាយជាអង្គភាពអគ្គិសនីឈានមុខគេនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយត្រូវខិតខំយ៉ាងខ្លាំងក្នុងការបំពេញតម្រូវការប្រើប្រាស់ថាមពលអគ្គិសនី និងធ្វើឲ្យប្រសើរឡើងនូវគុណភាព និងប្រសិទ្ធភាពនៃការផ្គត់ផ្គង់។ នេះក៏ជាឆ្នាំនៃការខិតខំប្រឹងប្រែងយ៉ាងខ្លាំងក្លា ដើម្បីពង្រឹងបន្ថែមផ្នែកសេវាកម្មរបស់យើងជូនអតិថិជន។

ក្នុងឆ្នាំ២០១៥ ការលក់ថាមពលអគ្គិសនីរបស់អគ្គិសនីកម្ពុជា បានកើនឡើងដល់ ៥.៣៤១ ជីហ្គាវ៉ាត់ម៉ោង (GWh) ឬ ២៩% ច្រើនជាងឆ្នាំមុន។ ការបាត់បង់លើប្រព័ន្ធទាំងមូលក្នុងឆ្នាំ២០១៥ បានធ្លាក់ចុះមកត្រឹម ៦%។ ចំណូលប្រចាំឆ្នាំមានការកើនឡើងដល់ ៣.៨១៤ ប៊ីលានរៀល ឬ ២៧% ច្រើនជាងឆ្នាំមុន។ យើងមាននិយោជិតសរុបចំនួន ៤.០២៦ នាក់ សម្រាប់បម្រើសេវាកម្មជូនអតិថិជនចំនួន ៧៧៤.៦១៣។

ម៉ាស៊ីនទី២ នៃរោងចក្រអគ្គិសនីដើរដោយធ្យូងថ្ម (CIIDG) នៅខេត្តព្រះសីហនុ ដែលមានអានុភាពតម្លើង ១៣៥ មេហ្គាវ៉ាត់ ត្រូវបានដាក់ឲ្យដំណើរការ។ ខ្សែបញ្ជូន ១១៥ kV ពីអនុស្ថានីយទី៧ មកអនុស្ថានីយទី២ ក្នុងផ្នែកមួយនៃគម្រោងខ្សែបញ្ជូនកងតង់ស្យុងខ្ពស់ជុំវិញរាជធានីភ្នំពេញ ស្ថិតក្រោមប្រាក់កម្ចី ធនាគារចិនអាហារ័ណនីហារ័ណ ត្រូវបានបញ្ចប់ការសាងសង់ និងដាក់ឲ្យដំណើរការ ដើម្បីធានាឲ្យបាននូវការបង្កើនភាពជឿជាក់ខ្ពស់លើប្រភពថាមពលនៅតំបន់ភាគខាងត្បូងនៃរាជធានីភ្នំពេញ។

ខ្សែបញ្ជូនតភ្ជាប់ថ្មីពី អនុស្ថានីយបានហាត ខេត្តចម្ប៉ាសាក់ ប្រទេសឡាវ ទៅ ស្រុកកំពង់ស្រឡៅ ខេត្តព្រះវិហារ ប្រទេសកម្ពុជា ត្រូវបានរៀបចំ និងសាងសង់សម្រាប់ខ្សែបញ្ជូនតង់ស្យុង ១១៥ គីឡូវ៉ុល (kV) ដោយបញ្ជូនថាមពលអគ្គិសនីនៅកម្រិតតង់ស្យុង ២២ kV សម្រាប់ដំណាក់កាលដំបូង រហូតដល់ខ្សែបញ្ជូនពីព្រំប្រទល់ឡាវ ទៅអនុស្ថានីយជ័យសែន សាងសង់រួចរាល់។

គម្រោងខ្សែបញ្ជូនតង់ស្យុងខ្ពស់ និងតង់ស្យុងមធ្យមជាច្រើន កំពុងដំណើរការសាងសង់ ដើម្បីពង្រឹងនិងពង្រីកការផ្គត់ផ្គង់ក្នុងប្រទេសកម្ពុជា។ គម្រោងសំខាន់ៗ មានដូចជា៖

ខ្សែបញ្ជូនតង់ស្យុងខ្ពស់ពីរាជធានីភ្នំពេញ ទៅក្រុងបាវិត ខេត្តស្វាយរៀង និងពីខេត្តកំពង់ចាម ទៅខេត្តក្រចេះ ខេត្តស្ទឹងត្រែង និងភ្ជាប់បន្តទៅរោងចក្រវារីអគ្គិសនីសេសានក្រោម២ ដែលមានប្រវែងសរុបប្រមាណ ៤២៦ km បាននឹងកំពុងស្ថិតក្រោមការសាងសង់។ គម្រោងទាំងនោះ រំពឹងថានឹងត្រូវបានសាងសង់រួចរាល់ជាស្ថាពរនៅចុងឆ្នាំ ២០១៧ ។

គម្រោងអគ្គិសនីភាវូបនីយកម្មជនបទដំណាក់កាលទី២ ស្ថិតក្រោមមូលនិធិរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលគ្របដណ្តប់ខេត្តចំនួន ៦ ដូចជា ខេត្តក្រចេះ ខេត្តស្ទឹងត្រែង ខេត្តរតនគិរី ខេត្តមណ្ឌលគិរី ខេត្តឧត្តរមានជ័យ និងខេត្តសៀមរាប ដែលមានប្រវែងសរុបប្រហែល ១.២០០ km ត្រូវបានរំពឹងថារួចរាល់ជាស្ថាពរនៅឆ្នាំ ២០១៦។

គម្រោងខ្សែបញ្ជូនជុំវិញបឹងទន្លេសាប ដែលតភ្ជាប់ខេត្តបាត់ដំបង ខេត្តសៀមរាប ខេត្តកំពង់ធំ កំពង់ចាម និងគម្រោងខ្សែបញ្ជូនកងជុំវិញរាជធានីភ្នំពេញជំហានទី២ (ខាងជើងភ្នំពេញ - ជ្រោយចង្វារ - ខាងកើតភ្នំពេញ -

ខាងត្បូងភ្នំពេញ) និងគម្រោងខ្សែបញ្ជូនមួយទៀត ដែលតភ្ជាប់ខេត្តកំពង់ធំ ខេត្តព្រះវិហារ និងព្រំប្រទល់ប្រទេសឡាវ កំពុងស្ថិតក្រោមការសិក្សា។ គម្រោងទាំងនេះ ទទួលបានមូលនិធិពីធនាគារចិនអាហារ័ណនីហារ័ណ ។

ឥណទានសម្រាប់ការសាងសង់ខ្សែបណ្តាញចែកចាយប្រវែង ២.០៤០ km និងខ្សែបណ្តាញបញ្ជូនតង់ស្យុងខ្ពស់ប្រវែង ២២០ km ដែលគ្របដណ្តប់ខេត្តចំនួន ១៤ រួមមាន៖ ខេត្តកណ្តាល ខេត្តកំពង់ស្ពឺ ខេត្តកំពង់ឆ្នាំង ខេត្តពោធិ៍សាត់ ខេត្តសៀមរាប ខេត្តឧត្តរមានជ័យ ខេត្តព្រះវិហារ ខេត្តកំពង់ចាម ខេត្តក្រចេះ ខេត្តស្ទឹងត្រែង ខេត្តរតនគិរី ខេត្តមណ្ឌលគិរី ខេត្តកោះកុង និងខេត្តព្រះសីហនុ ត្រូវបានផ្តល់ឲ្យជាបន្តបន្ទាប់ដោយធនាគារចិនអាហារ័ណនីហារ័ណ (China Export Import Bank) សម្រាប់គម្រោងដំណាក់កាលទី២, ៣ និង ៤ ។

ទីភ្នាក់ងារបារាំងសម្រាប់ការអភិវឌ្ឍន៍ហៅកាត់ថា AFD បានផ្តល់កម្ចី ដើម្បីធ្វើការអភិវឌ្ឍន៍ពង្រីកខ្សែបណ្តាញបញ្ជូន និងចែកចាយក្នុងខេត្តកោះកុង និងពីខេត្តកំពង់ចាម និងខេត្តក្រចេះ។

គិតត្រឹមចុងឆ្នាំ២០១៥ កិច្ចព្រមព្រៀងទិញ-លក់ ថាមពលអគ្គិសនីចំនួន ១៩៣ ត្រូវបានចុះហត្ថលេខារវាងអគ្គិសនីកម្ពុជា និងសហគ្រាសអគ្គិសនីជនបទ(REEs) ឬ សេវាករ ដែលជាអ្នកផ្តល់សេវាកម្មចែកចាយអគ្គិសនី ដើម្បីទទួលបានការផ្គត់ផ្គង់អគ្គិសនីចេញពីបណ្តាញជាតិ ដែលជាហេតុនាំឲ្យមានការបញ្ឈប់ដំណើរការម៉ាស៊ីនភ្លើងតូចៗ ដែលជាប្រភពប្រើប្រាស់ប្រេងមានតម្លៃខ្ពស់។

នៅក្នុងឆ្នាំនេះដែរ អគ្គិសនីកម្ពុជាបានផ្តល់ហិរញ្ញប្បទានឥតសំណងចំនួន ៩ លានដុល្លារអាមេរិកទៅឲ្យនាយកដ្ឋានមូលនិធិអគ្គិសនីភាវូបនីយកម្មជនបទ ដើម្បីបន្តការជំរុញ និងអភិវឌ្ឍន៍វិស័យអគ្គិសនីភាវូបនីយកម្មជនបទទូទាំងប្រទេស។

អគ្គិសនីកម្ពុជា បានបង្កើតប្រព័ន្ធទូរស័ព្ទទំនាក់ទំនង ២៤ ម៉ោង និងបណ្តាញសង្គមហ្វេសប៊ុកផ្លូវការក្នុងការផ្តល់ និងទទួលព័ត៌មានសំខាន់ៗ ដើម្បីបង្កើនប្រសិទ្ធភាពក្នុងការបម្រើសេវាអតិថិជន ព្រមទាំងផ្តល់ព័ត៌មានសំខាន់ៗ និងសេចក្តីជូនដំណឹងទាន់ហេតុការជូនអតិថិជន។

លទ្ធផលនៃកិច្ចខំប្រឹងប្រែងខាងលើ បានផ្តល់នូវប្រយោជន៍ដោយផ្ទាល់ និងដោយប្រយោលជាច្រើនជូនដល់ប្រជាជនរាប់លានគ្រួសារ និងក្រុមហ៊ុនពាណិជ្ជកម្មទូទាំងប្រទេស ដែលប្រការទាំងនេះ បានឆ្លុះបញ្ចាំងឲ្យឃើញពីភាពរឹងមាំ និងការរីកចម្រើនយ៉ាងពិតប្រាកដ ក្នុងការរួមចំណែកការអភិវឌ្ឍន៍ប្រទេសកម្ពុជា ដើម្បីស្ថាបនាបាននូវគ្រឹះដ៏រឹងមាំ សម្រាប់កិច្ចអភិវឌ្ឍន៍ឲ្យមាននិរន្តរភាពសេដ្ឋកិច្ច និងសង្គមជាតិ។

ឆ្លៀតក្នុងឱកាសនេះ យើងខ្ញុំសូមធ្វើការកត់សម្គាល់ពីការចូលរួមចំណែក និងការប្តេជ្ញាចិត្តដ៏មោះមុតរបស់និយោជិតយើងទាំងអស់គ្នា ដែលបានដើរតួនាទីដ៏សំខាន់ និងមិនអាចខ្វះបានក្នុងការសម្រេចបានជោគជ័យជូនអង្គភាពនេះ។ យើងខ្ញុំសូមសម្តែងនូវកតញ្ញូដ៏ជ្រាលជ្រៅ ចំពោះការណែនាំដ៏មានសារៈសំខាន់ប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ដែលសម្តេចតែងផ្តល់ការគាំទ្រជាគន្លឹះៗ នៅគ្រប់របត់សំខាន់ៗ ទាំងអស់។

យើងខ្ញុំសូមសម្តែងនូវការដឹងគុណ ចំពោះក្រសួង រ៉ែ និង ថាមពល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលបានបន្តចង្អុលបង្ហាញទិសដៅ និងគាំទ្រយ៉ាងខ្លាំងក្លា ។ យើងខ្ញុំសូមសំដែងនូវសេចក្តីសោមនស្សរីករាយជាពិសេសជូនដល់អាជ្ញាធរអគ្គិសនីកម្ពុជា និងចំពោះសមាជិកក្រុមប្រឹក្សាភិបាលអគ្គិសនីកម្ពុជា សម្រាប់ការចូលរួមចំណែក ការគាំទ្រ និងការណែនាំកន្លងមក ។ យើងខ្ញុំសូមវាយតម្លៃយ៉ាងខ្ពស់ផងដែរ ចំពោះការគាំទ្រ

ពីសំណាក់អតិថិជនគ្រប់ប្រភេទរបស់អគ្គិសនីកម្ពុជា ជាងនេះទៅទៀត យើងខ្ញុំសូមសម្តែងនូវការកោតសរសើរ ចំពោះដៃគូអភិវឌ្ឍន៍នានា ជាពិសេសធនាគារចិនអាហារណ៍នីហរណ៍របស់សាធារណៈរដ្ឋប្រជាមានិតចិន និងដៃគូផលិតករថាមពលឯករាជ្យទាំងអស់ ។

ជាមួយការរីកចំរើននេះ អគ្គិសនីកម្ពុជាកំពុងបោះជំហានទៅមុន ប្រកបដោយសុទិដ្ឋិនិយម ក្នុងបេសកកម្មរបស់ខ្លួនដ៏ប្រសើរ ដើម្បីជួយអភិវឌ្ឍវិស័យថាមពលក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា**
**ទទួលបន្ទុកជា អគ្គនាយកអគ្គិសនីកម្ពុជា**

**កែវ រតនៈ**

# មាតិកា


| | |
|---|---|
| សេចក្តីសង្ខេប | ១ |
| ការអភិវឌ្ឍន៍ធនធានមនុស្ស | ៧ |
| មធ្យោបាយផលិតថាមពល និងការផ្គត់ផ្គង់ថាមពលអគ្គិសនី | ៨ |
| ខ្សែបណ្តាញបញ្ជូន និងបណ្តាញចែកចាយ | ២១ |
| មូលនិធិអគ្គិសនីភាវូបនីយកម្មជនបទនៃអគ្គិសនីកម្ពុជា | ២៨ |
| ផែនការអភិវឌ្ឍន៍វិស័យថាមពលអគ្គិសនីនៅព្រះរាជាណាចក្រកម្ពុជា | ២៩ |
| ការភ្ជាប់បណ្តាញអគ្គិសនីជាមួយប្រទេសជិតខាង | ៣៣ |
| ទិន្នន័យហិរញ្ញវត្ថុ | ៣៦ |

# សេចក្តីសង្ខេប

## ចក្ខុវិស័យ

ចក្ខុវិស័យរបស់អគ្គិសនីកម្ពុជា គឺធ្វើយ៉ាងណាឲ្យក្លាយជាអង្គភាពអគ្គិសនី ឈានមុខគេ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយត្រូវខិតខំយ៉ាងខ្លាំង ក្នុងការបំពេញតម្រូវការប្រើប្រាស់ថាមពលអគ្គិសនី និងធ្វើឲ្យប្រសើរឡើងនូវគុណភាព និងប្រសិទ្ធភាពនៃការផ្គត់ផ្គង់ថាមពលអគ្គិសនីជូនអតិថិជន។

## ទស្សនវិស័យ

ផ្តល់ការផ្គត់ផ្គង់អគ្គិសនីឲ្យបានគ្រប់គ្រាន់ ប្រកបដោយ ស្ថេរភាព គុណភាព ប្រសិទ្ធភាព ជូនអតិថិជននៅក្នុងតំបន់ដែលមានអាជ្ញាប័ណ្ណរបស់ខ្លួន ដោយតម្លៃប្រកួតប្រជែង។ បង្កើនប្រតិបត្តិការអាជីវកម្មឲ្យបានប្រសើរបំផុត និងប្រកបដោយប្រសិទ្ធភាព និងឧត្តមភាព និងចូលរួមអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាលដើម្បីកាត់បន្ថយភាពក្រីក្រ ការពារបរិស្ថាន និងអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម។

## តួនាទី និងការទទួលខុសត្រូវ

អគ្គិសនីកម្ពុជាមានសិទ្ធិ និងការទទួលខុសត្រូវចំពោះការផលិត បញ្ជូន និងចែកចាយថាមពលអគ្គិសនីទូទាំងព្រះរាជាណាចក្រកម្ពុជា ដោយអនុលោមតាមកាតព្វកិច្ចនៃការធ្វើពាណិជ្ជកម្មរបស់ខ្លួន ដែលមានចែងនៅក្នុងច្បាប់លក្ខន្តិកៈ អាជ្ញាប័ណ្ណ និងបទបញ្ញត្តិដទៃទៀតរបស់រាជរដ្ឋាភិបាលកម្ពុជា។

អគ្គិសនីកម្ពុជា ប្រតិបត្តិជាសហគ្រាសពាណិជ្ជកម្មមួយ មានឯករាជ្យភាព ក្នុងការរៀបចំអាជីវកម្មរបស់ខ្លួនលើការផលិត បញ្ជូន និងចែកចាយថាមពលអគ្គិសនី និងបង្កើតទុនវិនិយោគ ដើម្បីឆ្លើយតបទៅនឹងតម្រូវការទីផ្សារ និងមានការទទួលខុសត្រូវលើចំណូល ចំណាយ។

អគ្គិសនីកម្ពុជា ត្រូវអនុវត្តន៍តាមលក្ខខណ្ឌរបស់អាជ្ញាប័ណ្ណ ចេញដោយអាជ្ញាធរអគ្គិសនីកម្ពុជា ដើម្បីផ្តល់សេវាកម្មអគ្គិសនី។ អគ្គិសនីកម្ពុជា ត្រូវអនុវត្តន៍ និងធ្វើឲ្យសម្រេចនូវផែនការអាជីវកម្មរបស់ខ្លួន ដែលបានអនុម័តដោយក្រុមប្រឹក្សាភិបាលអគ្គិសនីកម្ពុជា និងអនុលោមតាមគោលនយោបាយថាមពលអគ្គិសនីជាតិ និងផែនការអភិវឌ្ឍន៍ជាតិ ។

អគ្គិសនីកម្ពុជា ត្រូវកំណត់សកម្មភាពអាជីវកម្ម ដែលមានចែងនៅក្នុងលក្ខន្តិកៈ និងអាជ្ញាប័ណ្ណដែលបានអនុម័តដោយអាជ្ញាធរអគ្គិសនីកម្ពុជា។

អគ្គិសនីកម្ពុជា ត្រូវបានអនុញ្ញាតលើការទទួលខុសត្រូវចំពោះ ៖

១ ការផលិត ការបញ្ជូន និងការបែងចែកថាមពលអគ្គិសនី ក្នុងគោលបំណង ដើម្បីឆ្លើយតបតាមតម្រូវការថាមពលរបស់អ្នកជាវគ្រប់ប្រភេទ។

២ ការនាំចូល និងនាំចេញថាមពលអគ្គិសនីជាមួយប្រទេសជិតខាង ។

៣ ការសាងសង់ និងដាក់ឲ្យដំណើរការបណ្តាញជាតិបញ្ជូនអគ្គិសនី ដើម្បីធានានូវការផ្គត់ផ្គង់អគ្គិសនីឲ្យបានគ្រប់គ្រាន់ និងមានគុណភាព។

៤ ការសាងសង់ និងដាក់ឲ្យដំណើរការបណ្តាញបញ្ជូនរង ក្នុងគោលបំណង ចែកចាយអគ្គិសនី និងផ្គត់ផ្គង់ដល់តំបន់គ្រប់គ្រងដោយអគ្គិសនីកម្ពុជា និងតំបន់ដទៃទៀត។

៥ ការលក់ថាមពលអគ្គិសនី និងការបម្រើសេវាកម្មដែលពាក់ព័ន្ធ ។

៦ ការទិញថាមពល ការបញ្ជូនថាមពល និងការទិញ-លក់ថាមពល រវាងអគ្គិសនីកម្ពុជា និងដៃគូអ្នកផលិតថាមពលឯករាជ្យផ្សេងៗទៀត។

អគ្គិសនីកម្ពុជា បានប្រភពទុនមកពី ៖

១ ការផ្តល់ជំនួយពីរាជរដ្ឋាភិបាលកម្ពុជា ។

២ អចលនទ្រព្យនិងដីធ្លីទាំងឡាយ ដែលត្រូវបានផ្ទេរជូនអគ្គិសនីកម្ពុជា ដោយរាជរដ្ឋាភិបាល ដូចមាននៅក្នុងមាត្រា ៧ នៃអនុក្រឹត្យលេខ ២៣។

៣ ប្រាក់ចំណូល ដោយយោងតាមគោលការណ៍គណនេយ្យរបស់អគ្គិសនីកម្ពុជា ។

៤ ការផ្តល់ហិរញ្ញប្បទានឥតសំណង និងហិរញ្ញប្បទានឥណទានផ្សេងៗ ដែលអគ្គិសនីកម្ពុជាបានទទួលដោយមានការអនុម័តពីរាជរដ្ឋាភិបាលកម្ពុជា ។

៥ ការផ្តល់ឥណទានដល់អគ្គិសនីកម្ពុជាពីប្រភពហិរញ្ញវត្ថុផ្សេងៗ ដែលត្រូវអនុម័តដោយរាជរដ្ឋាភិបាលកម្ពុជា។

## ការវិវឌ្ឍនរបស់អគ្គិសនីកម្ពុជា

ការប្រើប្រាស់អគ្គិសនី មានវត្តមាននៅប្រទេសកម្ពុជា ក្នុងឆ្នាំ១៩០៦ ។ មុនខែ តុលា ឆ្នាំ១៩៥៨ ថាមពលអគ្គិសនី និងការប្រើប្រាស់សម្រាប់បំភ្លឺផ្សេងៗ នៅប្រទេសកម្ពុជា ត្រូវបានផ្គត់ផ្គង់ដោយក្រុមហ៊ុនឯកជនចំនួន ០៣ ៖

- ក្រុមហ៊ុនទឹក និងអគ្គិសនី ហៅកាត់ថា CEE
- សហព័ន្ធអគ្គិសនីឥណ្ឌូចិន ហៅកាត់ថា UNEDI
- ក្រុមហ៊ុនអគ្គិសនីបារាំង-ខ្មែរ ហៅកាត់ថា CFKE

ក្រុមហ៊ុនទឹក និងអគ្គិសនី (CEE) បានបម្រើសេវាអគ្គិសនីយ៉ាងធំនៅតំបន់ទីក្រុងភ្នំពេញ។ សហព័ន្ធអគ្គិសនីឥណ្ឌូចិន (UNEDI) ទទួលខុសត្រូវគ្រប់បណ្តាខេត្តផ្សេងៗទាំងអស់លើកលែងតែខេត្តបាត់ដំបង ដែលត្រូវបានផ្គត់ផ្គង់អគ្គិសនីដោយក្រុមហ៊ុនអគ្គិសនីបារាំង-ខ្មែរ (CFKE)។

យោងតាមក្រឹត្យលេខ ៦៦៥-NS ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ១៩៥៨ ក្រុមហ៊ុនចំនួនពីរគឺ ក្រុមហ៊ុនទឹក និងអគ្គិសនី (CEE) និងសហព័ន្ធអគ្គិសនីឥណ្ឌូចិន (UNEDI) បានដាក់បញ្ចូលគ្នា ដោយដាក់ឈ្មោះថា **អគ្គិសនីកម្ពុជា** ។

អំឡុងឆ្នាំ១៩៧០ ដល់ឆ្នាំ១៩៧៩ វិស័យថាមពលអគ្គិសនីនៅក្នុងប្រទេសបានឆ្លងកាត់ព្រឹត្តិការណ៍ចំនួនពីរដែលទទួលរងគ្រោះថ្នាក់ដោយសារ ៖ សង្គ្រាមស៊ីវិល (ពីឆ្នាំ១៩៧០ - ១៩៧៥) និងមានភាពចលាចលជាប្រវត្តិសាស្ត្រ អំឡុងរបបខ្មែរក្រហម (ពីឆ្នាំ១៩៧៥ - ១៩៧៩)។ អំឡុងពេលនោះ មធ្យោបាយនៃការផលិត ការបញ្ជូន និងការចែកចាយ គ្រប់ប្រភេទទាំងអស់ត្រូវបានបំផ្លាញ មិនត្រឹមតែនៅរាជធានីភ្នំពេញទេ ប៉ុន្តែថែមទាំងនៅតំបន់ដទៃៗទៀតទូទាំងប្រទេសផងដែរ។

នៅឆ្នាំ១៩៧៩ អគ្គិសនីកម្ពុជាត្រូវបានបង្កើតឡើងវិញ ដោយរចនាសម្ព័ន្ធរដ្ឋបាល ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងឧស្សាហកម្ម។ នៅឆ្នាំ ១៩៩១ អគ្គិសនីកម្ពុជា ត្រូវបានផ្ទេរឲ្យស្ថិតក្រោមការគ្រប់គ្រងរបស់សាលារាជធានីភ្នំពេញ ដោយដាក់ឈ្មោះថា អគ្គិសនីភ្នំពេញ ហើយមានភារកិច្ចផ្គត់ផ្គង់អគ្គិសនីនៅរាជធានីភ្នំពេញ ទន្ទឹមនឹងនោះ ការផ្គត់ផ្គង់អគ្គិសនីនៅតាមបណ្តាខេត្តទាំងអស់ ត្រូវបានគ្រប់គ្រងដោយមន្ទីរឧស្សាហកម្មខេត្ត។

នៅឆ្នាំ ១៩៩២ អគ្គិសនីភ្នំពេញ ត្រូវបានផ្ទេរឲ្យស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងឧស្សាហកម្ម ដោយប្តូរឈ្មោះជាថ្មីទៅជាអគ្គិសនីកម្ពុជាវិញ ។ ក្រោយការបោះឆ្នោតជាសកលនៅឆ្នាំ១៩៩៣ អគ្គិសនីកម្ពុជា ត្រូវបានធ្វើកំណែទម្រង់ ឲ្យស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួង ឧស្សាហកម្ម រ៉ែ និងថាមពល(១) ហើយទទួលខុសត្រូវសម្រាប់ការផ្គត់ផ្គង់ថាមពលអគ្គិសនីនៅរាជធានីភ្នំពេញ។ ចំណែកឯ អង្គភាពបម្រើសេវាកម្មថាមពលអគ្គិសនីនៅតាមបណ្តាខេត្តមួយចំនួន នៅតែស្ថិតក្រោមការគ្រប់គ្រងរបស់អាជ្ញាធរខេត្ត ប៉ុន្តែទទួលការឧបត្ថម្ភថវិកាតាមរយៈក្រសួង ឧស្សាហកម្ម រ៉ែ និងថាមពល។

នៅខែមីនា ឆ្នាំ១៩៩៦ តាមព្រះរាជក្រឹត្យលេខ ០៣៩៦/១០ អគ្គិសនីកម្ពុជាបានក្លាយជាក្រុមហ៊ុនស្វយ័តទទួលខុសត្រូវមានកំណត់មួយ ជាកម្មសិទ្ធិរបស់រដ្ឋទាំងស្រុង ដែលមានកាតព្វកិច្ចក្នុងការផលិត បញ្ជូន និងចែកចាយថាមពលអគ្គិសនីទូទាំងព្រះរាជាណាចក្រកម្ពុជា។ អគ្គិសនីកម្ពុជា ជាស្ថាប័នមួយស្របច្បាប់ដោយមានស្វ័យភាពនៃការគ្រប់គ្រងរដ្ឋបាល និងហិរញ្ញវត្ថុ។ អគ្គិសនីកម្ពុជា ទទួលខុសត្រូវចំពោះប្រាក់ចំណេញ ប្រាក់ខាតបង់ និងទទួលសងបំណុលទៅតាមទំហំនៃតម្លៃទ្រព្យសម្បត្តិរបស់ខ្លួន។

---

(១) នៅខែធ្នូ ឆ្នាំ២០១៣ តាមព្រះរាជក្រមលេខ នស/រកម/១២១៣/០១៧ បានប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួង រ៉ែ និងថាមពល ។

## រចនាសម្ព័ន្ធគ្រប់គ្រង

ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា ក្រសួង រ៉ែ និងថាមពល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុគឺជាម្ចាស់សហាកម្មសិទ្ធិលើក្រុមហ៊ុនអគ្គិសនីកម្ពុជា។

## ក្រុមប្រឹក្សាភិបាល

ឆ្នាំ ២០១៥ ក្រុមប្រឹក្សាភិបាលនៃអគ្គិសនីកម្ពុជា មានសមាជិកចំនួន ០៧ រូប



**ឯកឧត្តម ទិចច័រ ហ្សូនា**

ប្រធាន

តំណាង ក្រសួង រ៉ែ និងថាមពល



**ឯកឧត្តម កែវ រតនៈ**

សមាជិក

ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា អគ្គនាយកអគ្គិសនីកម្ពុជា (ទីប្រឹក្សាផ្ទាល់របស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្រ្តី នៃព្រះរាជាណាចក្រកម្ពុជា)



**ឯកឧត្តម ចាន់ សុធី**

សមាជិក

តំណាង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ



**ឯកឧត្តម ហែម ក្រាញ់ តូនី**

សមាជិក

តំណាង ទីស្តីការគណៈរដ្ឋមន្រ្តី



**លោក ហង់ ទូច**

សមាជិក

តំណាង និយោជិតកម្មករ អគ្គិសនីកម្ពុជា



**លោក គី ខេមលីន**

សមាជិក

តំណាង ក្រសួងយុត្តិធម៌



**លោកស្រី សុខ សុធាវី**

សមាជិក

តំណាង សតាពាណិជ្ជកម្មកម្ពុជា

## ការគ្រប់គ្រងរបស់អគ្គិសនីកម្ពុជា

អគ្គិសនីកម្ពុជា ត្រូវបានដឹកនាំដោយប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា អគ្គនាយកអគ្គិសនីកម្ពុជា ដោយមានឋានៈស្មើនឹងរដ្ឋលេខាធិការក្នុងជួររាជរដ្ឋាភិបាល ដែលជាអ្នករាយការណ៍ជូនក្រុមប្រឹក្សាភិបាល និងទទួលរបាយការណ៍ត្រឡប់មកវិញ ដើម្បីរាយការណ៍ជូនទៅរដ្ឋមន្ត្រីក្រសួងអាណាព្យាបាលទាំងពីរ។ ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា អគ្គនាយកអគ្គិសនីកម្ពុជា ត្រូវបានជួយការងារ ដោយអគ្គនាយករង ចំនួន ០៤ រូប និងនាយក ចំនួន ០៩ រូប ។ ឆ្នាំ ២០១៥ ថ្នាក់គ្រប់គ្រងរបស់អគ្គិសនីកម្ពុជា រួមមាន៖



**ឯកឧត្តម កែវ រតនៈ**

ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា អគ្គនាយកអគ្គិសនីកម្ពុជា

ទីប្រឹក្សាផ្ទាល់របស់ សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា



**បណ្ឌិត ប្រាំង ចលសា**

អគ្គនាយករង

ផែនការ និងបច្ចេកទេស



**លោក ឆឹង អ៊ីង**

អគ្គនាយករង

ហិរញ្ញកិច្ច-អាជីវកម្ម



**ឯកឧត្តម អេង គន្ធា**

អគ្គនាយករង

រដ្ឋបាល



**លោក កែវ វីរៈ**

អគ្គនាយករង

មូលនិធិអគ្គិសនីតាវូបនីយកម្មជនបទ



**លោក ជុន ពិសិដ្ឋ**

នាយក ផែនការយុទ្ធសាស្ត្រ និងគម្រោងការ



**កញ្ញា ស៊ិន សុវណ្ណានី**

នាយិកា ហិរញ្ញកិច្ច-គណនេយ្យ



**លោក លី ទីឃា**

នាយក រដ្ឋបាល



**លោក នូ សុខុន**

នាយក បញ្ជូនអគ្គិសនី



**លោក អូន ហេមរិទ្ធ**

នាយក ផលិតកម្ម



**លោក ជា ស៊ីនហ៊ើល**

នាយក អាជីវកម្ម-ចែកចាយ



**លោក ង៉ែត សុខន**

នាយក លទ្ធកម្ម



**លោក អ៊ុំ ពិសិដ្ឋ**

នាយក វិទ្យាស្ថានវិទ្យាសាស្ត្រអគ្គិសនី



**លោក លឿង កែវសិលា**

នាយក មូលនិធិអគ្គិសនីតាវូបនីយកម្មជនបទ

# អង្គការលេខ និងរចនាសម្ព័ន្ធគ្រប់គ្រង អគ្គិសនីកម្ពុជា



# ការអភិវឌ្ឍន៍ធនធានមនុស្ស

នៅឆ្នាំ ២០១៥ វិទ្យាស្ថានវិទ្យាសាស្ត្រអគ្គិសនី បានបណ្តុះបណ្តាលដល់សិក្ខាកាមជានិយោជិត មកពីនាយកដ្ឋាន និងអង្គភាពអគ្គិសនីខេត្ត-ក្រុងចំនួន ៨៧២ នាក់ លើវគ្គជំនាញចំនួន ១៦៣ វគ្គ និង ៨៩ មុខវិជ្ជា។ សិក្ខាកាមទាំងនោះ ត្រូវបានបណ្តុះបណ្តាលលើជំនាញផ្សេងៗគ្នា ក្នុងនោះរួមមាន៖ សិក្ខាកាម ២៥៨ នាក់ ខាងផ្នែកបណ្តាញចែកចាយ សិក្ខាកាម ៨០ នាក់ ខាងផ្នែកប្រព័ន្ធការពាររោងចក្រផលិតអគ្គិសនី សិក្ខាកាម ១៧១ នាក់ ខាងផ្នែកនាឡិកាស្ទង់ សិក្ខាកាម ១០៥ នាក់ ខាងផ្នែកសុវត្ថិភាពពលកម្ម សិក្ខាកាម ៣៣ នាក់ ខាងផ្នែកផលិតថាមពល សិក្ខាកាម ១៦៤ នាក់ ខាងផ្នែកបណ្តាញបញ្ជូនតង់ស្យុងខ្ពស់ សិក្ខាកាម ៧០ នាក់ ខាងផ្នែកកម្មវិធីកុំព្យូទ័រ និងសិក្ខាកាម ៣១ នាក់ ខាងផ្នែកភាសាអង់គ្លេសបច្ចេកទេស ។

អគ្គិសនីកម្ពុជា ក៏បានសហការជាមួយស្ថាប័នជាតិ និងអន្តរជាតិដទៃទៀត ក្នុងការផ្តល់នូវវគ្គបណ្តុះបណ្តាលវិស័យថាមពលអគ្គិសនី ដើម្បីបង្កើនចំណេះដឹង និងបច្ចេកវិទ្យាថ្មីៗ ដល់និយោជិតរបស់ខ្លួន។

## តារាងទី ១ : និយោជិត-កម្មករ អគ្គិសនីកម្ពុជាពីឆ្នាំ ២០១០ - ២០១៥

| ប្រភេទ | ២០១០ | ២០១១ | ២០១២ | ២០១៣ | ២០១៤ | ២០១៥ |
|---|---|---|---|---|---|---|
| បណ្ឌិត | ១ | ២ | ៣ | ៤ | ៤ | ៤ |
| អនុបណ្ឌិត | ១០៤ | ១១៩ | ១៤២ | ១៤១ | ១៥១ | ១៦៥ |
| វិស្វករ និងបរិញ្ញាប័ត្រផ្សេងៗ | ៥៥១ | ៦៧២ | ៨២២ | ៩៣៤ | ១.០៧៨ | ១.២៤០ |
| បច្ចេកទេសជំនាញ | ៣៩០ | ៤២៩ | ៤៩៣ | ៥៧០ | ៧៣៦ | ៩១៧ |
| កម្មករជំនាញ | ២៤៦ | ២០៧ | ១៨៨ | ១៩០ | ១៧៨ | ១៧៣ |
| ទុតិយភូមិ និង គ្មានជំនាញ | ១.២៧៨ | ១.៣៣១ | ១.២៨៧ | ១.៣៩៨ | ១.៤៣៨ | ១.៥២៧ |
| សរុប | ២.៥៧០ | ២.៧៦០ | ២.៩៣៥ | ៣.២២៧ | ៣.៥៨៥ | ៤.០២៦ |

ចក្ខុវិស័យរបស់អគ្គិសនីកម្ពុជា សម្រាប់និយោជិតរបស់ខ្លួន គឺមានដូចខាងក្រោម ៖

- ផ្តល់ឲ្យនិយោជិតរបស់ខ្លួន មានឱកាស ដើម្បីពង្រឹងសមត្ថភាពវិជ្ជាជីវៈ ដោយផ្តោតលើសមត្ថភាពការងារ ភាពសុចរិត និងភាពស្មោះត្រង់ចំពោះអគ្គិសនីកម្ពុជា។
- ផ្តល់ឲ្យនិយោជិតរបស់ខ្លួន នូវស្ថានភាពជីវភាពរស់នៅបានល្អ និងសមរម្យ។
- ធានានូវភាពត្រឹមត្រូវ ស្មើភាព និងផ្តល់ឱកាសដល់និយោជិតទាំងឡាយ ដើម្បីទទួលបាននូវការចូលរួមចំណែកក្នុងការអភិវឌ្ឍន៍អគ្គិសនីកម្ពុជា។
- ផ្តល់ជូននូវលក្ខខណ្ឌការងារល្អសមរម្យ ដោយបើកទូលាយក្នុងការប្រាស្រ័យទាក់ទងព័ត៌មាន ប្រកបដោយភាពស្មោះត្រង់ ក្នុងចំណោមនិយោជិតទាំងអស់ និងជួយជំរុញលើការចូលរួមធ្វើការជាក្រុម ក្នុងគោលបំណងបង្កើនប្រសិទ្ធភាពការងារ ដោយផ្តោតលើទិសដៅស្លាបនាក្រុមហ៊ុនឲ្យមានការរីកចម្រើន។

# មធ្យោបាយផលិតថាមពល និងការផ្គត់ផ្គង់ថាមពលអគ្គិសនី

## ប្រភពផលិតកម្ម

ក្នុងឆ្នាំ២០១៥ អានុភាពតម្លើងសរុបប្រមាណ ១.៩៧២ MW ដែលក្នុងនោះរួមមាន វារីអគ្គិសនីប្រមាណ ៩៣០ MW ធ្យូងថ្មប្រមាណ ៥០០ MW ប្រេងឥន្ធនៈប្រមាណ ២៤៨ MW ជីវម៉ាសប្រមាណ ៦ MW និងនាំចូលពីប្រទេសជិតខាងដូចជាប្រទេសថៃឡង់ដ៍ ប្រទេសវៀតណាម និងប្រទេសឡាវ សរុបប្រមាណ ៣៨៨ MW ។ ថាមពលផលិតសរុបប្រមាណ ៥.៦៩៨ GWh ក្នុងនោះប្រភពពីវារីអគ្គិសនីមាន ៣៨% ប្រភពធ្យូងថ្ម ៣៧% ប្រភពប្រេងឥន្ធនៈ ៣% ប្រភពជីវម៉ាស់ ០,៥% និង ការនាំចូលពីប្រទេសជិតខាង ២២% ។ ជាលទ្ធផលនៃការអភិវឌ្ឍន៍ប្រភពអគ្គិសនីក្នុងស្រុក បានធ្វើឲ្យការនាំចូលថាមពលពីប្រទេសជិតខាង ថយចុះគួរកត់សំគាល់ពី ៦២% នៅឆ្នាំ២០១០ មកត្រឹម ២២% នៅឆ្នាំ២០១៥ និងការប្រើប្រាស់ប្រេងឥន្ធនៈថយចុះយ៉ាងគំហោគពី ៣៤% មកត្រឹម ៣% រៀងគ្នា និងមានកំណើនផលិតកម្មប្រចាំឆ្នាំប្រមាណ ៨%។

## តម្រូវការថាមពល និងការផ្គត់ផ្គង់អគ្គិសនី នៅក្នុងបណ្តាញជាតិ

នៅចុងឆ្នាំ២០១៥ នេះ «បណ្តាញជាតិ» កម្ពុជា ក្រៅពីបានភ្ជាប់ជាមួយប្រព័ន្ធអគ្គិសនីតង់ស្យុងខ្ពស់ប្រទេសវៀតណាម ភ្ជាប់ជាមួយប្រព័ន្ធអគ្គិសនីតង់ស្យុងខ្ពស់ប្រទេសថៃឡង់ដ៍ និងភ្ជាប់ជាមួយប្រភពវារីអគ្គិសនីនៅតំបន់កំពង់ស្ពឺ កោះកុង និងពោធិ៍សាត់ ប្រភពវារីអគ្គិសនីនៅតំបន់ជួរភ្នំគិរីរម្យ និងជួរភ្នំកំចាយ ព្រមទាំងភ្ជាប់ជាមួយប្រភពអគ្គិសនីផលិតដោយធ្យូងថ្មនាំចូលនៅខេត្តព្រះសីហនុ ការផ្គត់ផ្គង់អគ្គិសនីរបស់«បណ្តាញជាតិ»នេះ បានគ្របដណ្តប់ផ្ទាល់លើរាជធានី/ខេត្តចំនួន ១៤ គឺ៖ ភ្នំពេញ កណ្តាល កំពង់ស្ពឺ តាកែវ កំពត កែប ព្រះសីហនុ កំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង បន្ទាយមានជ័យ សៀមរាប កំពង់ចាម និងកោះកុង រួចហើយ និងបានបញ្ជូនទៅជួយខេត្តចំនួន ៤ ទៀតគឺ៖ ត្បូងឃ្មុំ ព្រៃវែង កំពង់ធំ និងប៉ៃលិន ដែលមានអានុភាពតម្រូវការអតិបរមាប្រមាណ ៩៥១ MW និងថាមពលផលិត ៥.៣៩៩ GWh ហើយតំបន់គ្របដណ្តប់ទាំងនោះមានដូចខាងក្រោម៖

**អគ្គិសនីភ្នំពេញ (ប្រព័ន្ធភ្នំពេញ)** ភ្នំពេញ គឺជារាជធានីនៃព្រះរាជាណាចក្រកម្ពុជា។ ក្នុងរបាយការណ៍នេះ ប្រព័ន្ធអគ្គិសនីភ្នំពេញ ផ្គត់ផ្គង់ពីបណ្តាញជាតិតាមរយៈអនុស្ថានីយតង់ស្យុង ២៣០ kV ដូចជា៖ អនុស្ថានីយទី៤ អនុស្ថានីយទី៦ និងអនុស្ថានីយទី៧ ជាមួយនឹងអានុភាពសរុបប្រមាណ ៩០០ MW ព្រមទាំងផលិតកម្មដោយប្រេងមានប្រមាណ ១៩៤ MW ដោយបញ្ចូះមកក្នុងប្រព័ន្ធភ្នំពេញ តាមអនុស្ថានីយតង់ស្យុង ១១៥ kV ដែលរួមមាន៖ អនុស្ថានីយទី១ អនុស្ថានីយទី២ អនុស្ថានីយទី៣ អនុស្ថានីយទី៤ អនុស្ថានីយទី៥ អនុស្ថានីយទី៦ និងអនុស្ថានីយទី៧។ តំបន់ស្ថិតក្នុងការគ្រប់គ្រងរបស់អគ្គិសនីភ្នំពេញរួមមាន រាជធានីភ្នំពេញ តំបន់ជាយក្រុង ជុំវិញក្រុងភ្នំពេញ និងទីប្រជុំជនក្រុងតាខ្មៅ ខេត្តកណ្តាល។

នៅឆ្នាំ២០១៥ តម្រូវការអានុភាពអតិបរមារបស់ប្រព័ន្ធភ្នំពេញគឺ ៦៧៤ MW ។ ក្នុងការផ្គត់ផ្គង់ជូនអតិថិជនគ្រប់ប្រភេទចំនួន ៧៧៤.៦១៣ អគ្គិសនីកម្ពុជាបានទាញថាមពលពីប្រភពបណ្តាញជាតិប្រមាណ ៤.១១៣ GWh ក្នុងឆ្នាំ២០១៥ និងមានត្រឹម ៣.២៦៨ GWh ក្នុងឆ្នាំ២០១៤ ។

**អគ្គិសនីសៀមរាប** សៀមរាប គឺជាតំបន់ទាក់ទាញភ្ញៀវទេសចរណ៍ និងមានទីតាំងស្ថិតនៅភាគពាយ័ព្យនៃប្រទេសកម្ពុជា។ អគ្គិសនីសៀមរាប ត្រូវបានផ្ទេរមកនៅក្រោមការគ្រប់គ្រងរបស់អគ្គិសនីកម្ពុជានៅថ្ងៃទី៣០ ខែធ្នូ ឆ្នាំ ១៩៩៥។ ការផ្គត់ផ្គង់អគ្គិសនីនៅខេត្តសៀមរាប បានមកពីការផលិត ដោយរោងចក្រអគ្គិសនីកម្ពុជាផ្ទាល់ខ្លួន និងពីអនុស្ថានីយពូក ដែលបាននាំចូលថាមពលពីប្រទេសថៃឡង់ដ៍តាមខ្សែបញ្ជូន ១១៥ kV តាំងពីឆ្នាំ ២០០៧។ ប្រព័ន្ធអគ្គិសនីសៀមរាប បានភ្ជាប់ជាមួយបណ្តាញជាតិ នៅឆ្នាំ ២០១៣។

ប្រព័ន្ធអគ្គិសនីសៀមរាប សម្រាប់ឆ្នាំ២០១៥ មានសមត្ថភាពផ្គត់ផ្គង់ ១១ MW និងតម្រូវការប្រើប្រាស់អានុភាពជាអតិបរមា ៦៨ MW ។ ប្រភពថាមពលនៅក្នុងប្រព័ន្ធទាំងមូល ទទួលបានពីបណ្តាញជាតិ

បញ្ជូន ការនាំចូលពីប្រទេសថៃឡង់ដ៏តាមរយៈអនុស្ថានីយ ១១៥/២២ kV និងការផលិតដោយរោងចក្រផ្ទាល់ខ្លួន និងពីអនុស្ថានីយពួក ដែលបាននាំចូលថាមពលពីប្រទេសថៃឡង់ដ៏តាមខ្សែបញ្ជូន ១១៥ kV តាំងពីឆ្នាំ ២០០៧។ ប្រព័ន្ធអគ្គិសនីសៀមរាប បានភ្ជាប់ជាមួយបណ្ដាញជាតិនៅឆ្នាំ ២០១៣។

ចំណុចសំខាន់ៗនៃប្រតិបត្តិការរបស់ប្រព័ន្ធអគ្គិសនីសៀមរាប សម្រាប់ឆ្នាំ២០១៥ មានដូចតទៅ៖ សមត្ថភាពផ្គត់ផ្គង់ប្រមាណ ៩០ MW បានមកពីបណ្ដាញជាតិ និង ១១ MW បានមកពីផលិតកម្មដោយរោងចក្រផ្ទាល់ខ្លួន។ តម្រូវការប្រើប្រាស់អានុភាពជាអតិបរមា ៦៨ MW ។ ប្រភពថាមពលនៅក្នុងប្រព័ន្ធទាំងមូលទទួលបានពីបណ្ដាញជាតិបញ្ជូនសរុបប្រមាណ ៤០២ GWh ។ ប្រវែងខ្សែបណ្ដាញចែកចាយតង់ស្យុងមធ្យម ២២ kV និងប្រវែងបណ្ដាញតង់ស្យុងទាប ០,៤ kV មានប្រវែងសរុបចំនួន ១.១២៩ km ដែលបានផ្គត់ផ្គង់ជូនអតិថិជនគ្រប់ប្រភេទចំនួន ៤០.៩៤៩។

**អគ្គិសនីខេត្តព្រះសីហនុ** ខេត្តព្រះសីហនុ គឺជាតំបន់ទេសចរណ៍ ដែលមានឆ្នេរសមុទ្រស្អាតជាប់ចំណាត់ថ្នាក់លេខ១ ស្ថិតនៅភាគនិរតីនៃប្រទេសកម្ពុជា។ អគ្គិសនីខេត្តព្រះសីហនុ ត្រូវបានផ្ទេរមកនៅក្រោមការគ្រប់គ្រងរបស់អគ្គិសនីកម្ពុជានៅថ្ងៃទី១១ ខែមិថុនា ឆ្នាំ១៩៩៦។ កន្លងមកប្រព័ន្ធអគ្គិសនីក្រុងព្រះសីហនុជាប្រព័ន្ធដាច់ដោយឡែកពីគេ និងទទួលការផ្គត់ផ្គង់ពីរោងចក្រផលិតអគ្គិសនីក្នុងខេត្ត ដែលមានអានុភាពសរុប ២០ MW ។ នៅចុងឆ្នាំ ២០១១ ប្រព័ន្ធនេះបានតភ្ជាប់ជាមួយប្រព័ន្ធអគ្គិសនីកំពត ដែលទទួលថាមពលពីបណ្ដាញជាតិ ព្រមទាំងថាមពលនាំចូលពីប្រទេសវៀតណាម។ ចុងឆ្នាំ ២០១២ និងដើមឆ្នាំ ២០១៣ ប្រព័ន្ធអគ្គិសនីខេត្តព្រះសីហនុ ត្រូវបានផ្គត់ផ្គង់ដោយផ្ទាល់ពីបណ្ដាញជាតិតាមរយៈខ្សែបញ្ជូន ២៣០ kV ពីអនុស្ថានីយកំពត ទៅអនុស្ថានីយស្ទឹងហាវ និងខ្សែបញ្ជូន ១១៥ kV ពីអនុស្ថានីយស្ទឹងហាវ ទៅអនុស្ថានីយក្រុងព្រះសីហនុ។ ក្នុងឆ្នាំ២០១៥ អគ្គិសនីខេត្តព្រះសីហនុ បានទទួលការផ្គត់ផ្គង់ពីបណ្ដាញជាតិ ៩០ MW និងពីផលិតកម្មដោយរោងចក្រផលិតអគ្គិសនីក្នុងខេត្ត ២០ MW ដែលនាំឲ្យមានការកើនឡើងនូវលទ្ធភាពផ្គត់ផ្គង់របស់ប្រព័ន្ធទៅកាន់តំបន់ផ្សេងទៀត និងសេវាករជាច្រើននៅក្នុងខេត្តព្រះសីហនុ។ ចំណុចសំខាន់ៗនៃប្រតិបត្តិការរបស់ប្រព័ន្ធអគ្គិសនីខេត្តព្រះសីហនុ សម្រាប់ឆ្នាំ២០១៥ មានដូចតទៅ៖ ផលិតកម្មថាមពលប្រចាំឆ្នាំមាន ១៩៤ GWh។ តម្រូវការប្រើប្រាស់អានុភាពជាអតិបរមា ៤០ MW ។ ប្រវែងខ្សែបណ្ដាញចែកចាយតង់ស្យុងមធ្យម ២២ kV និងប្រវែងបណ្ដាញតង់ស្យុងទាប ០,៤ kV មានប្រវែងសរុបចំនួន ៥០៣ km ដែលបានផ្គត់ផ្គង់ជូនអតិថិជនគ្រប់ប្រភេទចំនួន ១៥.៩៧៥។

**អគ្គិសនីកំពង់ចាម** កំពង់ចាម ជាខេត្តដែលប្រកបដោយដីមានជីវជាតិសម្រាប់ចម្ការកៅស៊ូ មានទីតាំងស្ថិតនៅភាគខាងកើតនៃប្រទេសកម្ពុជា។ អគ្គិសនីកំពង់ចាម ត្រូវបានផ្ទេរមកនៅក្រោមការគ្រប់គ្រងរបស់អគ្គិសនីកម្ពុជា នៅថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៩៨។ ក្នុងឆ្នាំ ១៩៩៦ ប្រព័ន្ធអគ្គិសនីកំពង់ចាម ត្រូវបានផ្គត់ផ្គង់ដោយរោងចក្រផលិតអគ្គិសនីក្នុងខេត្ត។ លុះដល់ឆ្នាំ ២០១១ ផ្នែកមួយចំនួននៃប្រព័ន្ធនេះ បានទទួលថាមពលដែលនាំចូលពីប្រទេសវៀតណាម។ អគ្គិសនីកំពង់ចាមបានភ្ជាប់មកបណ្ដាញជាតិបញ្ជូននៅឆ្នាំ២០១៣។ ចំណុចសំខាន់ៗនៃប្រតិបត្តិការរបស់ប្រព័ន្ធអគ្គិសនីកំពង់ចាម សម្រាប់ឆ្នាំ២០១៥ មានដូចតទៅ៖ សមត្ថភាពផ្គត់ផ្គង់ប្រមាណ ៩០ MW បានមកពីបណ្ដាញជាតិ និង ៨ MW បានមកពីផលិតកម្មដោយរោងចក្រផលិតអគ្គិសនីក្នុងខេត្ត។ ផលិតកម្មថាមពលប្រចាំឆ្នាំមាន ៤៩ GWh។ អានុភាពតម្លើងមាន ៩ MW និងតម្រូវការប្រើប្រាស់អានុភាពជាអតិបរមា ២២ MW ។ ប្រវែងខ្សែបណ្ដាញចែកចាយតង់ស្យុងមធ្យម ២២ kV និងប្រវែងបណ្ដាញតង់ស្យុងទាប ០,៤ kV មានប្រវែងសរុបចំនួន ៧៣២ km ដែលបានផ្គត់ផ្គង់ដល់អតិថិជនគ្រប់ប្រភេទចំនួន ១៦.៩៩៩។

**សាខាមេមត់ និងពញាក្រែក** ប្រព័ន្ធផ្គត់ផ្គង់អគ្គិសនីសម្រាប់ស្រុកមេមត់ និងពញាក្រែក មានទីតាំងស្ថិតនៅខេត្តកំពង់ចាម និងប្រើប្រាស់ប្រព័ន្ធបណ្ដាញតង់ស្យុងមធ្យម ២២ kV ។ ការផ្គត់ផ្គង់ថាមពលអគ្គិសនីទៅតំបន់ទាំងពីរនេះ ត្រូវបាននាំចូលពីប្រទេសវៀតណាម ចាប់ពីឆ្នាំ២០០២ ដែលមានអានុភាពផ្គត់ផ្គង់តាមកិច្ចសន្យា ១០ MW។ ក្នុងឆ្នាំ ២០១៥ ថាមពលនាំចូលទទួលបាន ៤១ GWh ព្រមទាំងប្រវែងខ្សែបណ្ដាញ

ចែកចាយតង់ស្យុងមធ្យម ២២ kV និងប្រវែងបណ្តាញតង់ស្យុងទាប ០,៤ kV មានប្រវែងសរុបចំនួន ៣២១ km ដែលតម្រូវការប្រើប្រាស់អានុភាពជាអតិបរមា ១១ MW និងបានផ្គត់ផ្គង់ដល់អតិថិជនគ្រប់ប្រភេទចំនួន ១១.៥៦៦ ។

**អគ្គិសនីបាត់ដំបង** បាត់ដំបង ជាខេត្តដែលឈានមុខគេ និងមានសក្តានុពលសេដ្ឋកិច្ចផ្នែកកសិកម្ម ជាពិសេសគឺផលិតកម្មស្រូវអង្ករ។ ខេត្តនេះមានទីតាំងស្ថិតនៅភាគពាយ័ព្យនៃប្រទេសកម្ពុជា។ អគ្គិសនីបាត់ដំបងត្រូវបានផ្ទេរមកនៅក្រោមការគ្រប់គ្រងរបស់អគ្គិសនីកម្ពុជានៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០០០។ អគ្គិសនីបាត់ដំបងបានគ្របដណ្តប់លើខ្សែបញ្ជូនរងក្នុងខេត្តពោធិ៍សាត់។ ខ្សែបញ្ជូន ១១៥ kV សម្រាប់នាំចូលថាមពលអគ្គិសនីពីប្រទេសថៃឡង់ដ៍ ត្រូវបានតភ្ជាប់ជាមួយប្រព័ន្ធបញ្ជូនអគ្គិសនីសៀមរាប និងបន្ទាយមានជ័យក្នុងឆ្នាំ២០០៧ ព្រមទាំងភ្ជាប់បន្តទៅបណ្តាញជាតិបញ្ជូនក្នុងឆ្នាំ២០១២។ ការផ្គត់ផ្គង់ថាមពលអគ្គិសនីក្នុងខេត្តបាត់ដំបងបានពីបណ្តាញជាតិ តាមរយៈអនុស្ថានីយបាត់ដំបង (CPG) និងអនុស្ថានីយបាត់ដំបង (CPTL) ដោយមានសមត្ថភាពសរុប ១៨៥ MW ពីរោងចក្រអគ្គិសនីកម្ពុជាផ្ទាល់ប្រហែលជិត ២ MW។ ក្នុងឆ្នាំ ២០១៥ ប្រព័ន្ធអគ្គិសនីបាត់ដំបង មានថាមពលផលិតសរុបប្រមាណ ២៣៦ GWh ព្រមទាំងតម្រូវការប្រើប្រាស់អានុភាពជាអតិបរមា ៤៧ MW ។ ប្រវែងខ្សែបណ្តាញចែកចាយតង់ស្យុងមធ្យម ២២ kV និងប្រវែងបណ្តាញតង់ស្យុងទាប ០,៤ kV មានប្រវែងសរុបចំនួន ៦៩៦ km ដែលបានផ្គត់ផ្គង់ដល់អតិថិជនគ្រប់ប្រភេទចំនួន ៤៥.២១៦ ។

**អគ្គិសនីបន្ទាយមានជ័យ និងសាខាមង្គលបូរី** បន្ទាយមានជ័យមានទីតាំងស្ថិតនៅភាគពាយ័ព្យនៃប្រទេសកម្ពុជា ។ អគ្គិសនីបន្ទាយមានជ័យ ត្រូវបានផ្ទេរមកនៅក្រោមការគ្រប់គ្រងរបស់អគ្គិសនីកម្ពុជានៅថ្ងៃទី១៤ ខែសីហា ឆ្នាំ២០០៣។ ការផ្គត់ផ្គង់ថាមពលអគ្គិសនីក្នុងខេត្តបន្ទាយមានជ័យ បានពីការនាំចូលពីប្រទេសថៃឡង់ដ៍ និងការផលិតថាមពលពីរោងចក្រអគ្គិសនីកម្ពុជាផ្ទាល់ ក្នុងឆ្នាំ២០០៧។ បន្ទាប់មកប្រព័ន្ធអគ្គិសនីរបស់ខេត្តនេះ បានតភ្ជាប់ថាមពលពីបណ្តាញជាតិបញ្ជូននៅឆ្នាំ២០១៣ ។ នៅឆ្នាំ ២០១៥ ការផ្គត់ផ្គង់ ៦៨ MW បានមកពីបណ្តាញជាតិបញ្ជូន (ពីអនុស្ថានីយបន្ទាយមានជ័យ និងអនុស្ថានីយ IE) និង ៣ MW ទៀតបានពីរោងចក្រអគ្គិសនីកម្ពុជាផ្ទាល់។ ថាមពលទិញសរុបគឺ ១១២ GWh ដែលតម្រូវការប្រើប្រាស់អានុភាពអតិបរមា ២៣ MW ។ ប្រវែងខ្សែបណ្តាញចែកចាយតង់ស្យុងមធ្យម ២២ kV និងប្រវែងបណ្តាញតង់ស្យុងទាប ០,៤ kV មានប្រវែងសរុបចំនួន ៣១៨ km និងបានផ្គត់ផ្គង់ដល់អតិថិជនគ្រប់ប្រភេទចំនួន ២១.១៨៦។

**អគ្គិសនីស្ទឹងត្រែង** ស្ទឹងត្រែង គឺជាខេត្តដាច់ស្រយាលមួយ និងមានប្រជាជនរស់នៅរង្វើលៗ ឃ្លាតៗពីគ្នាដែលស្ថិតនៅភាគឦសាននៃប្រទេសកម្ពុជា ។ អគ្គិសនីស្ទឹងត្រែង ត្រូវបានផ្ទេរមកនៅក្រោមការគ្រប់គ្រងរបស់អគ្គិសនីកម្ពុជានៅថ្ងៃទី១៤ ខែសីហា ឆ្នាំ ២០០៣។ ប្រព័ន្ធអគ្គិសនីក្រុងស្ទឹងត្រែង បានតភ្ជាប់ទៅប្រព័ន្ធអគ្គិសនីប្រទេសឡាវ តាមរយៈតង់ស្យុង ២២ kV តាំងពីឆ្នាំ ២០១០។ ក្នុងឆ្នាំ២០១៥ សមត្ថភាពផ្គត់ផ្គង់សរុបគឺ ៦ MW ( ដែលប្រហែលជិត ២ MW ផ្គត់ផ្គង់ដោយរោងចក្រអគ្គិសនីកម្ពុជាផ្ទាល់ និង ៤ MW នាំចូលពីប្រទេសឡាវ )។ តម្រូវការប្រើប្រាស់អានុភាពជាអតិបរមា ៣ MW និងថាមពលផលិតសរុប ១៨ GWh។ ប្រវែងខ្សែបណ្តាញចែកចាយតង់ស្យុងមធ្យម ២២ kV និងប្រវែងបណ្តាញតង់ស្យុងទាប ០,៤ kV មានប្រវែងសរុបចំនួន ២៤០ km ដែលបានផ្គត់ផ្គង់ដល់អតិថិជនគ្រប់ប្រភេទចំនួន ៦.២៨០ ។

**អគ្គិសនីរតនគិរី** រតនគិរី ស្ថិតនៅជាប់ព្រំដែនខ្ពង់រាបកណ្តាល នៃប្រទេសវៀតណាម និងប្រទេសឡាវ។ អគ្គិសនីរតនគិរី ត្រូវបានផ្ទេរមកនៅក្រោមការគ្រប់គ្រងរបស់អគ្គិសនីកម្ពុជានៅថ្ងៃទី១៤ ខែសីហា ឆ្នាំ ២០០៣។ ក្នុងឆ្នាំ ២០១៥ ប្រព័ន្ធអគ្គិសនីរតនគិរី មានអានុភាពតម្លើង ៤ MW ពីរោងចក្រវារីអគ្គិសនីរបស់អគ្គិសនីកម្ពុជាផ្ទាល់ និងរោងចក្រផលិតថាមពលក្នុងខេត្តប្រមាណ ៨ MW បាននាំចូលពីប្រទេសវៀតណាម តាមរយៈខ្សែបញ្ជូនរងតង់ស្យុង ៣៥ kV ។ នៅឆ្នាំ ២០១៥ តម្រូវការប្រើប្រាស់អានុភាពជាអតិបរមា ៦ MW ថាមពលផលិត និងនាំចូលសរុបប្រចាំឆ្នាំប្រមាណ ៣៣ GWh ។ ប្រវែងខ្សែបណ្តាញចែកចាយតង់ស្យុងមធ្យម ២២ kV និងប្រវែងបណ្តាញតង់ស្យុងទាប ០,៤ kV មានប្រវែងសរុបចំនួន ១៦៧ km ដែលបានផ្គត់ផ្គង់ដល់អតិថិជនគ្រប់ប្រភេទចំនួន ៥.២៣៥។

**អគ្គិសនីតាកែវ និងសាខាអង្គតាសោម** តាកែវ មានទីតាំងស្ថិតនៅតំបន់វាលរាបភាគខាងត្បូងនៃប្រទេសកម្ពុជា។ អគ្គិសនីតាកែវ ត្រូវបានផ្ទេរមកនៅក្រោមការគ្រប់គ្រងរបស់អគ្គិសនីកម្ពុជានៅថ្ងៃទី២៦ ខែមិថុនា ឆ្នាំ ២០០០។ ខ្សែបញ្ជូនតង់ស្យុង ២៣០ kV ចេញពីប្រទេសវៀតណាម និងអនុស្ថានីយតាកែវ ត្រូវបានដាក់ឲ្យដំណើរការនៅថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០០៩ ដើម្បីនាំចូលថាមពលពីប្រទេសវៀតណាម។ នៅឆ្នាំ ២០១៥ ការផ្គត់ផ្គង់ពីបណ្តាញជាតិមានប្រមាណ ៤៥ MW ហើយពីរោងចក្រផលិតអគ្គិសនីប្រើប្រេងប្រមាណជិត ២ MW ។ នៅឆ្នាំ២០១៥ តម្រូវការប្រើប្រាស់អានុភាពជាអតិបរមា ២០ MW ដែលប្រវែងខ្សែបណ្តាញចែកចាយតង់ស្យុងមធ្យម ២២ kV និងប្រវែងបណ្តាញតង់ស្យុងទាប ០,៤ kV មានប្រវែងសរុបចំនួន ៧៩៦ km ថាមពលផលិត ដោយរោងចក្រអគ្គិសនីកម្ពុជាផ្ទាល់ ការនាំចូល និងទិញពីបណ្តាញជាតិបញ្ជូនសរុបប្រចាំឆ្នាំ ៩៤ GWh ដែលបានផ្គត់ផ្គង់ដល់អតិថិជនគ្រប់ប្រភេទចំនួន ២០.២០៣ ។

**អគ្គិសនីកំពត** កំពត មានទីតាំងស្ថិតនៅភាគខាងត្បូងនៃប្រទេសកម្ពុជា។ អគ្គិសនីកំពត ត្រូវបានផ្ទេរមកនៅក្រោមការគ្រប់គ្រងរបស់អគ្គិសនីកម្ពុជានៅថ្ងៃទី១៤ ខែសីហា ឆ្នាំ ២០០៣។ ផលិតកម្មពីរោងចក្រប្រើប្រេងរបស់អគ្គិសនីកំពត និងការនាំចូលថាមពលពីប្រទេសវៀតណាម តាមរយៈខ្សែបណ្តាញតង់ស្យុង ២២ kV ឆ្លងកាត់ស្រុកកំពង់ត្រាច ត្រូវបានប្រើសម្រាប់ផ្គត់ផ្គង់ឲ្យក្រុងកំពត ។ ក្នុងឆ្នាំ ២០១១ ការផ្គត់ផ្គង់ពីបណ្តាញជាតិមានប្រមាណ ៤៥ MW។ នៅឆ្នាំ ២០១៥ ថាមពលផលិត ដែលផ្គត់ផ្គង់ដោយរោងចក្រអគ្គិសនីកម្ពុជាផ្ទាល់ ការនាំចូល ការទិញពីបណ្តាញជាតិបញ្ជូនមានសរុប ៧២ GWh ហើយតម្រូវការប្រើប្រាស់អានុភាពជាអតិបរមា ១៨ MW ។ ប្រវែងខ្សែបណ្តាញចែកចាយតង់ស្យុងមធ្យម ២២ kV និងប្រវែងបណ្តាញតង់ស្យុងទាប ០,៤ kV មានប្រវែងសរុបចំនួន ៤៣៦ km ដែលបានផ្គត់ផ្គង់ដល់អតិថិជនគ្រប់ប្រភេទចំនួន ១១.៩៨៩។

**សាខាកំពង់ត្រាច** ប្រព័ន្ធអគ្គិសនីកំពង់ត្រាច ស្ថិតនៅក្នុងខេត្តកំពត និងនាំចូលអគ្គិសនីពីប្រទេសវៀតណាម តាំងពីឆ្នាំ២០០២ ។ ក្នុងឆ្នាំ២០១៤ ប្រព័ន្ធអគ្គិសនីកំពង់ត្រាច ត្រូវបានភ្ជាប់ជាមួយបណ្តាញជាតិបញ្ជូន។ នៅឆ្នាំ ២០១៥ អានុភាពជាវតាមកិច្ចសន្យាគឺ ១០ MW ហើយប្រវែងខ្សែបណ្តាញចែកចាយតង់ស្យុងមធ្យម ២២ kV និងប្រវែងបណ្តាញតង់ស្យុងទាប ០,៤ kV មានប្រវែងសរុបចំនួន ១០០ km មានថាមពលផលិតសរុប ១៣ GWh និងតម្រូវការប្រើប្រាស់អានុភាពជាអតិបរមា ៥ MW ដែលបានផ្គត់ផ្គង់ដល់អតិថិជនគ្រប់ប្រភេទចំនួន ៤.១៧៦។

**អគ្គិសនីព្រៃវែង** ព្រៃវែង មានទីតាំងស្ថិតនៅភាគអាគ្នេយ៍ នៃប្រទេសកម្ពុជា។ អគ្គិសនីព្រៃវែង ត្រូវបានផ្ទេរមកនៅក្រោមការគ្រប់គ្រងរបស់អគ្គិសនីកម្ពុជានៅថ្ងៃទី១៤ ខែសីហា ឆ្នាំ២០០៣។ ប្រព័ន្ធអគ្គិសនីព្រៃវែង មានប្រភពពីរោងចក្រអគ្គិសនីផ្ទាល់ខ្លួន ដែលមានអានុភាពតម្លើងប្រមាណជិត ១ MW (ក្នុងឆ្នាំ ២០០៣) និងអានុភាពនាំចូលពីវៀតណាម (ក្នុងឆ្នាំ ២០០៩)។ ក្រោយពីដាក់ឲ្យដំណើរការបណ្តាញអគ្គិសនីក្នុងគម្រោងជនបទ ខេត្តព្រៃវែងទទួលបានការផ្គត់ផ្គង់ពីប្រព័ន្ធអគ្គិសនីកំពង់ចាម (ក្នុងឆ្នាំ ២០១៣) ប្រព័ន្ធអគ្គិសនីភ្នំពេញសម្រាប់ផ្គត់ផ្គង់តំបន់តាមបណ្តោយផ្លូវជាតិលេខ ៨ (ក្នុងឆ្នាំ ២០១៤) និងរោងចក្រអគ្គិសនីដើរដោយធ្យូងថ្មសុវណ្ណភូមិ (ក្នុងឆ្នាំ ២០១៥)។ ប្រវែងខ្សែបណ្តាញចែកចាយតង់ស្យុងមធ្យម ២២ kV និងប្រវែងបណ្តាញតង់ស្យុងទាប ០,៤ kV មានប្រវែងសរុបចំនួន ៧៩៤ km និងតម្រូវការ អានុភាពអតិបរមា ១៤ MW ព្រមទាំងថាមពលផលិត និងនាំចូលក្នុងឆ្នាំ២០១៥ ប្រមាណ ៣៣ GWh ដែលបានផ្គត់ផ្គង់ដល់អតិថិជនគ្រប់ប្រភេទចំនួន ៦.៤៩៧ ។

**អគ្គិសនីស្វាយរៀង** ស្វាយរៀង មានទីតាំងស្ថិតនៅភាគអាគ្នេយ៍នៃប្រទេសកម្ពុជា។ អគ្គិសនីស្វាយរៀង ត្រូវបានផ្ទេរមកនៅក្រោមការគ្រប់គ្រងរបស់អគ្គិសនីកម្ពុជានៅថ្ងៃទី១៤ ខែសីហា ឆ្នាំ ២០០៣។ អគ្គិសនីស្វាយរៀង ត្រូវបានផ្គត់ផ្គង់ដោយការនាំចូលថាមពលពីប្រទេសវៀតណាម (ក្នុងឆ្នាំ២០០៣) ពីរោងចក្រអគ្គិសនីកម្ពុជាផ្ទាល់អានុភាពផលិតសរុបប្រមាណ ៨ MW (ក្នុងឆ្នាំ ២០០៦) និងពីរោងចក្រអគ្គិសនីដើរដោយធ្យូងថ្មសុវណ្ណភូមិ (ក្នុងឆ្នាំ ២០១៥)។ នៅឆ្នាំ ២០១៥ ថាមពលនាំចូល និងផលិតដោយរោងចក្រអគ្គិសនីកម្ពុជាផ្ទាល់គឺ ១៦៦ GWh ដែលមានតម្រូវការប្រើប្រាស់អានុភាពជាអតិបរមា ១២ MW ។ ប្រវែងខ្សែបណ្តាញចែកចាយ

តង់ស្យុងមធ្យម ២២ kV និងប្រវែងបណ្តាញតង់ស្យុងទាប ០,៤ kV មានប្រវែងសរុបចំនួន ៣៦៩ km ព្រមទាំងបានផ្គត់ផ្គង់ដល់អតិថិជនគ្រប់ប្រភេទចំនួន ១៣.៩៦៨។

**សាខាបាវិត** ប្រព័ន្ធអគ្គិសនីបាវិត ស្ថិតនៅខេត្តស្វាយរៀង និងទទួលការផ្គត់ផ្គង់ថាមពលតាមរយៈការនាំចូលពីប្រទេសវៀតណាម។ នៅឆ្នាំ២០១៥ អានុភាពនាំចូលពីប្រទេសវៀតណាមប្រមាណ ១៦ MW និងមានតម្រូវការប្រើប្រាស់អានុភាពជាអតិបរមា ១៧ MW ដែលបានផ្គត់ផ្គង់ដល់អតិថិជនគ្រប់ប្រភេទចំនួន ៦.៧៤២ ។

**អគ្គិសនីមណ្ឌលគិរី** អគ្គិសនីមណ្ឌលគិរី ត្រូវបានផ្ទេរមកនៅក្រោមការគ្រប់គ្រងរបស់អគ្គិសនីកម្ពុជានៅថ្ងៃទី១០ ខែឧសភា ឆ្នាំ ២០១០។ អានុភាពតម្លើង ៣៧០ kW ផលិតដោយរោងចក្រវារីអគ្គិសនីអានុភាពផលិតដោយម៉ាស៊ីនឌីយ៉េសែល ៣០០ kW និងអានុភាពនាំចូលពីប្រទេសវៀតណាមប្រមាណ ១ MW ។ ក្រោមការគ្រប់គ្រងរបស់អគ្គិសនីកម្ពុជានៅឆ្នាំ២០១៥ ថាមពលផលិត និងនាំចូលសរុប ៥ GWh និងតម្រូវការប្រើប្រាស់អានុភាពជាអតិបរមាជាង ១ MW ។ ប្រវែងខ្សែបណ្តាញចែកចាយតង់ស្យុងមធ្យម ២២ kV និងប្រវែងបណ្តាញតង់ស្យុងទាប ០,៤ kV មានប្រវែងសរុបចំនួន ១៣៣ km ដែលបានផ្គត់ផ្គង់ដល់អតិថិជនគ្រប់ប្រភេទចំនួន ២.៣៤៨។

**សាខាកែវសីមា** អគ្គិសនីកែវសីមា ស្ថិតនៅក្នុងខេត្តមណ្ឌលគិរី។ ការផ្គត់ផ្គង់ថាមពល គឺតាមរយៈការនាំចូលពីប្រទេសវៀតណាម ដែលអានុភាពបញ្ជាញតាមកិច្ចសន្យា ០,៤ MW ។ ថាមពលនាំចូលគឺ ៤ GWh និងតម្រូវការប្រើប្រាស់អានុភាពជាអតិបរមាជិត ១ MW ។ ប្រវែងខ្សែបណ្តាញចែកចាយតង់ស្យុងមធ្យម ២២ kV និងប្រវែងបណ្តាញតង់ស្យុងទាប ០,៤ kV មានប្រវែងសរុបចំនួន ៩០ km ដែលបានផ្គត់ផ្គង់ដល់អតិថិជនគ្រប់ប្រភេទចំនួន ១.៧៥៣។

**អគ្គិសនីក្រចេះ** អគ្គិសនីក្រចេះ ត្រូវបានផ្ទេរមកនៅក្រោមការគ្រប់គ្រងរបស់អគ្គិសនីកម្ពុជានៅថ្ងៃទី២០ ខែមេសា ឆ្នាំ ២០១១។ ប្រព័ន្ធអគ្គិសនីក្រចេះ ជាប្រព័ន្ធនៅដាច់ដោយឡែក ដែលផ្គត់ផ្គង់ដោយរោងចក្រផលិតថាមពលអគ្គិសនីផ្ទាល់ខ្លួន ដែលមានអានុភាពតម្លើងជិត ១ MW (ក្នុងឆ្នាំ ២០១១) និងពីប្រព័ន្ធអគ្គិសនីកំពង់ចាម (ក្នុងឆ្នាំ ២០១៥)។ ក្រោមការគ្រប់គ្រងដោយអគ្គិសនីកម្ពុជានៅឆ្នាំ២០១៥ ថាមពលទិញ និងនាំចូលប្រចាំឆ្នាំប្រមាណ ២៨ GWh និងតម្រូវការប្រើប្រាស់អានុភាពជាអតិបរមាប្រហែល ៣ MW ។ ប្រវែងខ្សែបណ្តាញចែកចាយតង់ស្យុងមធ្យម ២២ kV និងប្រវែងបណ្តាញតង់ស្យុង ទាប ០,៤ kV មានប្រវែងសរុបចំនួន ២២៥ km ដែលបានផ្គត់ផ្គង់ដល់អតិថិជនគ្រប់ប្រភេទចំនួន ៦.៧០៧។

**សាខាស្នួល** ប្រព័ន្ធអគ្គិសនីស្នួល ស្ថិតនៅខេត្តក្រចេះ ។ ប្រព័ន្ធនេះ បានផ្គត់ផ្គង់ដោយការនាំចូលថាមពលពីប្រទេសវៀតណាមប្រមាណ ៥ MW ដោយមានថាមពលផលិតប្រចាំឆ្នាំ ១២ GWh និងតម្រូវការប្រើប្រាស់អានុភាពជាអតិបរមា ២ MW ។ ប្រវែងខ្សែបណ្តាញចែកចាយតង់ស្យុងមធ្យម ២២ kV និងប្រវែងបណ្តាញតង់ស្យុងទាប ០,៤ kV មានប្រវែងសរុបចំនួន ៣៧ km ដែលបានផ្គត់ផ្គង់ដល់អតិថិជនគ្រប់ប្រភេទចំនួន ១.៣១១។

**អគ្គិសនីកំពង់ស្ពឺ** នៅថ្ងៃទី ១៤ ខែមីនា ឆ្នាំ២០១២ សាខាកំពង់ស្ពឺ ត្រូវបានបង្កើតជាអង្គភាពខេត្ត ខណៈដែលសាខានេះ កាលពីពេលកន្លងមក បានស្ថិតក្រោមប្រព័ន្ធគ្រប់គ្រងអគ្គិសនីភ្នំពេញ។ អង្គភាពនេះទទួលបន្ទុកគ្រប់គ្រងប្រព័ន្ធអគ្គិសនីក្នុងក្រុងកំពង់ស្ពឺ និងតំបន់តាមបណ្តោយផ្លូវជាតិលេខ៤ ដែលចែកចាយថាមពលដល់អនុស្ថានីយកំពង់ស្ពឺ។ ក្នុងឆ្នាំ២០១៥ ថាមពលទិញពីបណ្តាញជាតិប្រមាណ ១២២ GWh និងថាមពលលក់ប្រចាំឆ្នាំគឺ ១៣៧ GWh មានប្រវែងខ្សែបណ្តាញចែកចាយតង់ស្យុងមធ្យម ២២ kV និងប្រវែងបណ្តាញតង់ស្យុងទាប ០,៤ kV មានប្រវែងសរុបចំនួន ៤០១ km ដែលបានផ្គត់ផ្គង់ដល់អតិថិជនគ្រប់ប្រភេទចំនួន ១២.៩៩៦ ។

## តារាងទី ២ : អានុភាពតម្លើង និងអានុភាពបញ្ចេញពីប្រភពរោងចក្រ និងការនាំចូល ( MW )

| ឆ្នាំ | | | | ២០១០ | ២០១១ | ២០១២ | ២០១៣ | ២០១៤ | ២០១៥ |
|---|---|---|---|---|---|---|---|---|---|
| ទីតាំង | | | អានុភាព | | | | | | |
| បណ្តាញជាតិ | | | តម្លើង | ៤៣៤ | ៤៣៨ | ៧៥១ | ១.៣៦៤ | ១.៩១៣ | ១.៨៩៦ |
| | | | បញ្ចេញ | ៣២២ | ៣៤១ | ៦៨៨ | ១.១០៧ | ១.៧០៨ | ១.៨២៥ |
| ភ្នំពេញ | | | តម្លើង | ៤២៩ | ៤២៩ | ៦៣៤ | ១.២២០ | ១.៧២៨ | ១.៨៤២ |
| | | | បញ្ចេញ | ៣១៨ | ៣៣៣ | ៥៧១ | ៩៦៨ | ១.៥៣៣ | ១.៧៧៨ |
| អគ្គិសនីកម្ពុជា | | ប្រេង | តម្លើង | ៩៤ | ៩៤ | ៩៤ | ៩៤ | ៩៤ | ៨១ |
| | | | បញ្ចេញ | ៩១ | ៩១ | ៩១ | ៩១ | ៩១ | ៧៥ |
| CUPL | IPP | ប្រេង | តម្លើង | ៣៧ | ៣៧ | ៣៧ | ៣៧ | ៣៧ | - |
| | | | បញ្ចេញ | ៣២ | ៣២ | ៣២ | ៣២ | ៣២ | - |
| KEP | IPP | ប្រេង | តម្លើង | ៤៩ | ៤៩ | ៤៩ | ៤៩ | ៤៩ | ៤៩ |
| | | | បញ្ចេញ | ៤៥ | ៤៥ | ៤៣ | ៤៣ | ៤៣ | ៤៣ |
| CITY POWER | IPP | ប្រេង | តម្លើង | ៨ | ៨ | - | ៨ | - | - |
| | | | បញ្ចេញ | ៧ | ៧ | - | ៧ | - | - |
| CEP | IPP | ប្រេង | តម្លើង | ៤៩ | ៤៩ | ៤៩ | ៤៩ | ៤៩ | ៤៩ |
| | | | បញ្ចេញ | ៤៥ | ៤៥ | ៤៥ | ៤៥ | ៤៥ | ៤៥ |
| COLBEN | IPP | ប្រេង | តម្លើង | ២០ | ២០ | ២០ | ២០ | ២០ | ១៤ |
| | | | បញ្ចេញ | ១០ | ១០ | ១០ | ១០ | ១០ | ១០ |
| គិរីរម្យ ១ | IPP | វារី | តម្លើង | ១២ | ១២ | ១២ | ១២ | ១២ | ១២ |
| | | | បញ្ចេញ | ១១ | ១១ | ១១ | ១១ | ១១ | ១១ |
| គិរីរម្យ ៣ | IPP | វារី | តម្លើង | - | - | ១៨ | ១៨ | ១៨ | ១៨ |
| | | | បញ្ចេញ | - | - | ១៨ | ១៨ | ១៨ | ១៨ |
| កំចាយ | IPP | វារី | តម្លើង | - | - | ១៩៤ | ១៩៤ | ១៩៤ | ១៩៤ |
| | | | បញ្ចេញ | - | - | ១៩៤ | ១៩៤ | ១៩៤ | ១៩៤ |
| អាតៃ | IPP | វារី | តម្លើង | - | - | - | ១២០ | ១២០ | ១២០ |
| | | | បញ្ចេញ | - | - | - | ១២០ | ១២០ | ១២០ |
| ឫស្សីជ្រុំក្រោម | IPP | វារី | តម្លើង | - | - | - | ៣៣៨ | ៣៣៨ | ៣៣៨ |
| | | | បញ្ចេញ | - | - | - | ១៦៩ | ៣៣៨ | ៣៣៨ |
| តាតៃ | IPP | វារី | តម្លើង | - | - | - | - | ២៤៦ | ២៤៦ |
| | | | បញ្ចេញ | - | - | - | - | ២៤៦ | ២៤៦ |
| CEL | IPP | ធ្យូងថ្ម | តម្លើង | - | - | - | ១២០ | ១២០ | ១២០ |
| | | | បញ្ចេញ | - | - | - | ១០០ | ១០០ | ១០០ |
| CIIDG | IPP | ធ្យូងថ្ម | តម្លើង | - | - | - | - | ២៧០ | ២៧០ |
| | | | បញ្ចេញ | - | - | - | - | ១២៥ | ២៤១ |

## តារាងទី ២ : អានុភាពតម្លើង និងអានុភាពបញ្ចេញពីប្រភពរោងចក្រ និងការនាំចូល (MW) (ត)

| ឆ្នាំ | | | | ២០១០ | ២០១១ | ២០១២ | ២០១៣ | ២០១៤ | ២០១៥ |
|---|---|---|---|---|---|---|---|---|---|
| ទីតាំង | | | អានុភាព | | | | | | |
| សុវណ្ណភូមិ | IPP | ធ្យូងថ្ម | តម្លើង | ១០ | ១០ | ១០ | ១០ | ១០ | ១០ |
| | | | បញ្ចេញ | ៧ | ៧ | ៧ | ៨ | ៨ | ៨ |
| ថៃឡង់ដ៍ | នាំចូល | | កិច្ចព្រមព្រៀង | - | - | - | - | - | ១២០ |
| | | | បញ្ចេញ | - | - | - | - | - | ១២០ |
| វៀតណាម | នាំចូល | | កិច្ចព្រមព្រៀង | ២០០ | ២០០ | ២០០ | ២០០ | ២០០ | ២០០ |
| | | | បញ្ចេញ | ១២០ | ១៣៥ | ១៧០ | ១៧០ | ២០០ | ២០០ |
| **អគ្គិសនី ខេត្ត-ក្រុង** | | | **តម្លើង** | **១៧៥** | **១៨៧** | **២១៥** | **២១៧** | **២៥៧** | **១៣១** |
| | | | **បញ្ចេញ** | **១៦៨** | **១៧៩** | **២០៧** | **២១០** | **២៤៨** | **១២១** |
| អគ្គិសនី សៀមរាប | EDC | ប្រេង | តម្លើង | ១១ | ១១ | ១១ | ១១ | ១១ | ១១ |
| | | | បញ្ចេញ | ១១ | ១១ | ១១ | ១១ | ១១ | ១១ |
| | បណ្ដាញជាតិ | | តម្លើង | ៤០ | ៤០ | ៤០ | ៤០ | ៨០ | - |
| | | | បញ្ចេញ | ៤០ | ៤០ | ៤០ | ៤០ | ៨០ | - |
| អគ្គិសនី ខេត្តព្រះសីហនុ | EDC | ប្រេង | តម្លើង | ៦ | ៦ | ៦ | ៦ | ៦ | ៦ |
| | | | បញ្ចេញ | ៥ | ៥ | ៥ | ៥ | ៥ | ៥ |
| | IPP | ប្រេង | តម្លើង | ១៤ | ១៤ | ១៤ | ១៤ | ១៤ | ១៤ |
| | | | បញ្ចេញ | ១០ | ១០ | ១០ | ១០ | ១០ | ១០ |
| អគ្គិសនី កំពង់ចាម | IPP | ប្រេង | តម្លើង | ៨ | ៨ | ៨ | ៨ | ៨ | ៨ |
| | | | បញ្ចេញ | ៧ | ៧ | ៧ | ៧ | ៥ | ៥ |
| | បណ្ដាញជាតិ | | តម្លើង | - | ២ | ២ | ២ | ២ | ២ |
| | | | បញ្ចេញ | - | ២ | ២ | ២ | ២ | ២ |
| អគ្គិសនី តាកែវ | EDC | ប្រេង | តម្លើង | ២ | ២ | ២ | ២ | ២ | ២ |
| | | | បញ្ចេញ | ២ | ២ | ២ | ២ | ២ | ២ |
| | បណ្ដាញជាតិ | | តម្លើង | ៣ | ៤ | ១៦ | ១៦ | ១៦ | - |
| | | | បញ្ចេញ | ៣ | ៤ | ១៦ | ១៦ | ១៦ | - |
| អគ្គិសនី បាត់ដំបង | EDC | ប្រេង | តម្លើង | ៣ | ៣ | ៣ | ២ | ២ | ២ |
| | | | បញ្ចេញ | ២ | ២ | ២ | ២ | ២ | ២ |
| | បណ្ដាញជាតិ | | តម្លើង | ២០ | ២០ | ២០ | ២០ | ២០ | - |
| | | | បញ្ចេញ | ២០ | ២០ | ២០ | ២០ | ២០ | - |
| អគ្គិសនី បន្ទាយមានជ័យ | EDC | ប្រេង | តម្លើង | ៣ | ៣ | ៣ | ៣ | ៣ | ៣ |
| | | | បញ្ចេញ | ៣ | ៣ | ៣ | ៣ | ៣ | ៣ |
| | បណ្ដាញជាតិ | | តម្លើង | ២០ | ២០ | ២០ | ២០ | ២០ | - |
| | | | បញ្ចេញ | ២០ | ២០ | ២០ | ២០ | ២០ | - |

## តារាងទី ២ : អានុភាពតម្លើង និងអានុភាពបញ្ចេញពីប្រភពរោងចក្រ និងការនាំចូល (MW)(ត)

| ឆ្នាំ<br>ទីតាំង | | | អានុភាព | ២០១០ | ២០១១ | ២០១២ | ២០១៣ | ២០១៤ | ២០១៥ |
|---|---|---|---|---|---|---|---|---|---|
| អគ្គិសនីកំពត | EDC | ប្រេង | តម្លើង | ៣ | ៣ | ៣ | ៣ | ៣ | ៣ |
| | | | បញ្ចេញ | ៣ | ៣ | ៣ | ៣ | ៣ | ៣ |
| កំពង់ស្ពឺ | IPP | ជីវម៉ាស់ | តម្លើង | - | - | - | - | - | ៦ |
| | | | បញ្ចេញ | - | - | - | - | - | ៦ |
| **ក្រៅបណ្តាញជាតិ** | | | **តម្លើង** | **៤៣** | **៥៣** | **៦៩** | **៧៣** | **៧៣** | **៧៦** |
| | | | **បញ្ចេញ** | **៤២** | **៥១** | **៦៧** | **៧១** | **៧១** | **៧៤** |
| សាខាពញាក្រែក | នាំចូល | | កិច្ចព្រមព្រៀង | ៥ | ៥ | ៥ | ៥ | ៥ | ៥ |
| | | | បញ្ចេញ | ៥ | ៥ | ៥ | ៥ | ៥ | ៥ |
| សាខាមេមត់ | នាំចូល | | កិច្ចព្រមព្រៀង | ៥ | ៥ | ៥ | ៥ | ៥ | ៥ |
| | | | បញ្ចេញ | ៥ | ៥ | ៥ | ៥ | ៥ | ៥ |
| សាខាកំពង់ត្រាច | នាំចូល | | កិច្ចព្រមព្រៀង | ១០ | ១០ | ១០ | ១០ | ១០ | ១០ |
| | | | បញ្ចេញ | ១០ | ១០ | ១០ | ១០ | ១០ | ១០ |
| អគ្គិសនីព្រៃវែង | EDC | ប្រេង | តម្លើង | ២ | ២ | ២ | ២ | ២ | ២ |
| | | | បញ្ចេញ | ២ | ២ | ២ | ២ | ២ | ២ |
| | នាំចូល | | កិច្ចព្រមព្រៀង | ១ | ១ | ១ | ៣ | ៣ | ៣ |
| | | | បញ្ចេញ | ១ | ១ | ១ | ៣ | ៣ | ៣ |
| អគ្គិសនីស្ទឹងត្រែង | EDC | ប្រេង | តម្លើង | ២ | ២ | ២ | ២ | ២ | ២ |
| | | | បញ្ចេញ | ២ | ២ | ២ | ២ | ២ | ២ |
| | នាំចូល | | កិច្ចព្រមព្រៀង | ២ | ២ | ៤ | ៤ | ៤ | ៦ |
| | | | បញ្ចេញ | ២ | ២ | ៤ | ៤ | ៤ | ៦ |
| អគ្គិសនីរតនគិរី | IPP | ប្រេង | តម្លើង | ២ | ១ | - | - | ៣ | ៣ |
| | | | បញ្ចេញ | ១ | ១ | - | - | ១ | ១ |
| | EDC | វារី | តម្លើង | ១ | ១ | ១ | ១ | ១ | ១ |
| | | | បញ្ចេញ | ១ | ១ | ១ | ១ | ១ | ១ |
| | នាំចូល | | កិច្ចព្រមព្រៀង | - | ៧ | ៧ | ៨ | ៨ | ៨ |
| | | | បញ្ចេញ | - | ៧ | ៧ | ៨ | ៨ | ៨ |
| អគ្គិសនីស្វាយរៀង | EDC | ប្រេង | តម្លើង | ១ | ១ | ១ | ១ | ១ | ១ |
| | | | បញ្ចេញ | ១ | ១ | ១ | ១ | ១ | ១ |
| | នាំចូល | | កិច្ចព្រមព្រៀង | ៨ | ៨ | ៧ | ៨ | ៨ | ៨ |
| | | | បញ្ចេញ | ៨ | ៨ | ៧ | ៨ | ៨ | ៨ |
| សាខាបាវិត | នាំចូល | | កិច្ចព្រមព្រៀង | ៥ | ៥ | ១៦ | ១៦ | ១៦ | ១៦ |
| | | | បញ្ចេញ | ៥ | ៥ | ១៦ | ១៦ | ១៦ | ១៦ |
| អគ្គិសនីមណ្ឌលគិរី | EDC | ប្រេង/វារី | តម្លើង | ១ | ១ | ១ | ១ | ១ | ១ |
| | | | បញ្ចេញ | ១ | ១ | ១ | ១ | ១ | ១ |
| | នាំចូល | | កិច្ចព្រមព្រៀង | - | - | ១ | ១ | ១ | ១ |
| | | | បញ្ចេញ | - | - | ១ | ១ | ១ | ១ |

## តារាងទី ២ : អានុភាពតម្លើង និងអានុភាពបញ្ចេញពីប្រភពរោងចក្រ និងការនាំចូល (MW) (ត)

| ទីតាំង | | | អានុភាព | ២០១០ | ២០១១ | ២០១២ | ២០១៣ | ២០១៤ | ២០១៥ |
|---|---|---|---|---|---|---|---|---|---|
| សាខាកែវសីមា | នាំចូល | | កិច្ចព្រមព្រៀង | ០,៤ | ០,៤ | ០,៤ | ០,៤ | ០,៤ | ០,៤ |
| | | | បញ្ចេញ | ០,៤ | ០,៤ | ០,៤ | ០,៤ | ០,៤ | ០,៤ |
| អគ្គិសនីក្រចេះ | EDC | ប្រេង | តម្លើង | - | - | - | ១ | ១ | ១ |
| | | | បញ្ចេញ | - | - | - | ១ | ១ | ១ |
| | IPP | ប្រេង | តម្លើង | - | ៣ | ៣ | ៣ | - | - |
| | | | បញ្ចេញ | - | ១ | ១ | ១ | - | - |
| សាខាស្នួល | នាំចូល | | កិច្ចព្រមព្រៀង | - | ១ | ៤ | ៤ | ៤ | ៥ |
| | | | បញ្ចេញ | - | ១ | ៤ | ៤ | ៤ | ៥ |
| សរុប | | | តម្លើង | ៦០៤ | ៦១៧ | ៨៤៩ | ១.៤៣៧ | ១.៩៨៥ | ១.៩៧២ |
| | | | បញ្ចេញ | ៤៨៦ | ៥១២ | ៧៧៨ | ១.១៧៨ | ១.៧៧៩ | ១.៨៩៩ |
| ជាភាគរយ , % | | | | ៨០% | ៨៣% | ៩២% | ៨២% | ៩០% | ៩៦% |




**រូបភាពទី ១ : អានុភាពតម្លើងតាមប្រភេទនៅឆ្នាំ ២០១០ - ២០១៥**

## តារាងទី ៣ : ថាមពលផលិតពីប្រភពរោងចក្រ និងការនាំចូល (GWh)

| ឆ្នាំ / ទីតាំង | ២០១០ | ២០១១ | ២០១២ | ២០១៣ | ២០១៤ | ២០១៥ |
|---|---|---|---|---|---|---|
| **បណ្តាញជាតិ** | **២.០៩៨** | **២.៣៨៩** | **៣.០៨២** | **៣.៤២៣** | **៤.២២៨** | **៥.៣៩៩** |
| អគ្គិសនីកម្ពុជា | ៣៣ | ៤៩ | ៥៨ | ៣៦ | ២៦ | ៩ |
| CUPL | ១២០ | ១៣៣ | ១៣២ | ៧៣ | ៣៥ | ៥ |
| គិរីរម្យ ១ | ២៤ | ៣៨ | ២៩ | ៤៥ | ៣៩ | ៣៥ |
| កំចាយ | - | - | ៣៩៦ | ៤៦៣ | ៤២៤ | ៣៦៣ |
| គិរីរម្យ ៣ | - | - | ៨៦ | ៩០ | ៨០ | ៧៩ |
| អាតៃ | - | - | - | ២៦៧ | ៣២៧ | ១០៦ |
| ឫស្សីជ្រុំក្រោម | - | - | - | ១៣៨ | ៨៦៦ | ៨៣១ |
| តាតៃ | - | - | - | - | ១០៤ | ៧៣៦ |
| KEP | ២៣០ | ២៣២ | ១៩៧ | ១៤០ | ៨០ | ៥១ |
| City Power | ១៨ | ២៥ | ១៦ | ១៣ | - | - |
| CEP | ២៤៧ | ២២៨ | ២០៩ | ១៤៤ | ៩៦ | ៦៦ |
| COLBEN | ៣៦ | ៣៤ | ៣១ | ១៩ | ១១ | ៤ |
| S.L Garment | ៤ | ១២ | ១០ | ៦ | ១ | ៤ |
| សុវណ្ណភូមិ | ៣២ | ៤៦ | ៣៧ | ៣០ | ៤៣ | ៣៤ |
| CEL | - | - | - | ១៣៩ | ៦៥៤ | ៦២០ |
| CIIDG | - | - | - | - | ១៦៧ | ១.៤៧៤ |
| ថៃឡង់ដ៍ | - | - | ៧៦ | ៤១៧ | ៣៥០ | ១៣៩ |
| វៀតណាម | ៩៥៥ | ១.១២១ | ១.១៩៩ | ១.៣២៩ | ៨៧៩ | ៨០៤ |
| PP Sugar | - | - | ១ | ១ | ១០ | ២៣ |
| សៀមរាប | ១៩៤ | ២១៤ | ២៦៨ | ៤ | ៥ | ៤ |
| ព្រះសីហានុ | ៦៥ | ៧៦ | ៩០ | ២៥ | ៩ | ៣ |
| កំពង់ចាម | ៣៥ | ៣៨ | ៥៧ | ៣២ | ៨ | ០,២ |
| តាកែវ | ៩ | ១៣ | ២៦ | ០,០៣ | ០,០២ | ០,០២ |
| បាត់ដំបង | ៥០ | ៦៨ | ១០៦ | ០,០១ | ០,០១ | ០,០១ |
| កំពត | ២១ | ៣៣ | ១៤ | ១២ | ១៥ | ១២ |
| បន្ទាយមានជ័យ | ២៥ | ២៨ | ៤០ | ០,១៦ | ០,០៤ | ០,០៤ |
| **ក្រៅបណ្តាញជាតិ** | **១៤៤** | **១៧៥** | **២២៩** | **២៦៦** | **២៨៤** | **២៩៩** |
| ពញាក្រែក | ២៦ | ៣២ | ៤០ | ៣៩ | ៣០ | ២២ |
| មេមត់ | ១០ | ១១ | ១៤ | ១៦ | ១៦ | ១៩ |
| កំពង់ត្រាច | ៩ | ១៥ | ១៧ | ១៧ | ១៣ | ៧ |
| ព្រៃវែង | ៥ | ៧ | ១២ | ១៥ | ១៣ | ៩ |
| ស្ទឹងត្រែង | ៦ | ៧ | ៩ | ១១ | ១៤ | ១៨ |
| រតនគិរី | ៨ | ៩ | ១៧ | ២៣ | ២៨ | ៣៣ |
| ស្វាយរៀង | ១៨ | ២៤ | ២៧ | ៣៣ | ១៣៧ | ១៥៥ |

## តារាងទី ៣ : ថាមពលផលិតពីប្រភពវារីអគ្គិសនី និងការនាំចូល ( GWh ) ( ត )

| ឆ្នាំ / ទីតាំង | ២០១០ | ២០១១ | ២០១២ | ២០១៣ | ២០១៤ | ២០១៥ |
|---|---|---|---|---|---|---|
| បារិត | ៦១ | ៥៩ | ៧៤ | ៨៧ | - | - |
| មណ្ឌលគិរី | ១ | ២ | ៣ | ៣ | ៤ | ៥ |
| កែវសីមា | ០,៤ | ១ | ១ | ២ | ៣ | ៤ |
| ក្រចេះ | - | ២ | ៧ | ១០ | ១៥ | ១៥ |
| ស្ទួល | - | ៥ | ៧ | ៩ | ១០ | ១១ |
| **សរុប** | **២.២៤២** | **២.៥៦៤** | **៣.៣១០** | **៣.៦៨៩** | **៤.៥១២** | **៥.៦៩៨** |

## តារាងទី ៤ : ការផលិតថាមពលតាមប្រភេទក្នុងឆ្នាំ ២០១៥ (GWh)

| ទីតាំង | | ប្រេងឥន្ធនៈ | វារីអគ្គិសនី | ជីវម៉ាស់ | ធ្យូងថ្ម | នាំចូល | សរុប |
|---|---|---|---|---|---|---|---|
| **បណ្តាញជាតិ** | | **១៤១** | **២.១៤៩** | **២៧** | **២.១២៨** | **៩៥៤** | **៥.៣៩៩** |
| ភ្នំពេញ | អ.ក | ៩ | - | - | - | - | **៩** |
| | ផ.ឯ | ១២៥ | ២.១៤៩ | ២៧ | ២.១២៨ | ៩៤២ | **៥.៣៧១** |
| កំពង់ស្ពឺ | | - | - | - | - | - | **-** |
| សៀមរាប | | ៤ | - | - | - | - | **៤** |
| ព្រះសីហានុ | | ៣ | - | - | - | - | **៣** |
| កំពង់ចាម | | ០,២ | - | - | - | - | **០,២** |
| តាកែវ | | ០,០២ | - | - | - | - | **០,០២** |
| បាត់ដំបង | | ០,០១ | - | - | - | - | **០,០១** |
| កំពត | | ០,១ | - | - | - | ១២ | **១២** |
| បន្ទាយមានជ័យ | | ០,០៤ | - | - | - | - | **០,០៤** |
| **ក្រៅបណ្តាញ** | | **០,៥** | **៤** | **-** | **-** | **២៩៥** | **២៩៩** |
| ពញាក្រែក | | - | - | - | - | ២២ | **២២** |
| មេមត់ | | - | - | - | - | ១៩ | **១៩** |
| កំពង់ត្រាច | | - | - | - | - | ៧ | **៧** |
| ព្រៃវែង | | ០,១ | - | - | - | ៩ | **៩** |
| ស្ទឹងត្រែង | | ០,០៣ | - | - | - | ១៨ | **១៨** |
| រតនគិរី | | ០,២ | ២ | - | - | ៣១ | **៣៣** |
| ស្វាយរៀង | | ០,០១ | - | - | - | ១៥៥ | **១៥៥** |
| មណ្ឌលគិរី | | ០,១ | ១ | - | - | ៤ | **៥** |
| កែវសីមា | | - | - | - | - | ៤ | **៤** |
| ក្រចេះ | | ០,០១ | - | - | - | ១៥ | **១៥** |
| ស្នួល | | - | - | - | - | ១១ | **១១** |
| **សរុប** | | **១៤១** | **២.១៥៣** | **២៧** | **២.១២៨** | **១.២៤៩** | **៥.៦៩៨** |




**រូបភាពទី២ : ការផលិតថាមពលតាមប្រភេទ នៅឆ្នាំ២០១៥**

## តារាងទី ៥ : អានុភាពអតិបរមាតាមខេត្ត-ក្រុង (MW)

| ទីតាំង | ២០១០ | ២០១១ | ២០១២ | ២០១៣ | ២០១៤ | ២០១៥ |
|---|---|---|---|---|---|---|
| បណ្តាញជាតិ | ៣៣៤ | ៤០៧ | ៥០៨ | ៦២៥ | ៧៨៤ | ៩៥១ |
| ភ្នំពេញ | ៣០០ | ៣៤៩ | ៤១០ | ៤៩៣ | ៥៦៣ | ៦៧៤ |
| សៀមរាប | ៣៥ | ៣៩ | ៤៧ | ៥៧ | ៥៩ | ៦៨ |
| ព្រះសីហនុ | ១៣ | ១៦ | ១៩ | ២៥ | ៣០ | ៤០ |
| កំពង់ចាម | ៧ | ៨ | ១០ | ១៧ | ១៤ | ២២ |
| ពញាក្រែក | ៥ | ៧ | ៧ | ៧ | ៦ | ៤ |
| មេមត់ | ៣ | ៤ | ៤ | ៥ | ៤ | ៧ |
| តាកែវ | ៣ | ៥ | ៧ | ៩ | ១៨ | ២០ |
| បាត់ដំបង | ១០ | ១៧ | ២១ | ២៣ | ២៦ | ៤៧ |
| កំពត | ៥ | ៥ | ៥ | ៦ | ១៣ | ១៨ |
| កំពង់ត្រាច | ២ | ២ | ៣ | ៣ | ៣ | ៥ |
| ព្រៃវែង | ១ | ១ | ៣ | ៣ | ៨ | ១៤ |
| បន្ទាយមានជ័យ | ៦ | ៦ | ៩ | ១១ | ១៩ | ២៣ |
| ស្ទឹងត្រែង | ២ | ២ | ៣ | ៤ | ៥ | ៣ |
| រតនគិរី | ២ | ២ | ៤ | ៤ | ៥ | ៦ |
| ស្វាយរៀង | ៤ | ៥ | ៥ | ៧ | ៨ | ១២ |
| បាវិត | ១១ | ១១ | ១៥ | ១៦ | ១៧ | ១៧ |
| មណ្ឌលគិរី | ០,៥ | ១ | ១ | ១ | ១ | ១ |
| កែវសីមា | - | - | ០,៤ | ០,៥ | ១ | ១ |
| ក្រចេះ | - | ២ | ១ | ២ | ៣ | ៣ |
| ស្នួល | - | - | ១ | ១ | ២ | ២ |
| កំពង់ស្ពឺ | - | - | - | - | - | ៣៨ |




រូបភាពទី៣ : ថាមពលផលិត, ថាមពលលក់ និងប្រើប្រាស់ផ្ទាល់ខ្លួន
សម្រាប់ប្រព័ន្ធអគ្គិសនីភ្នំពេញ

**តារាងទី ៦ : ថាមពលលក់តាមខេត្ត-ក្រុង** (GWh)

| ទីតាំង | ២០១០ | ២០១១ | ២០១២ | ២០១៣ | ២០១៤ | ២០១៥ |
|---|---|---|---|---|---|---|
| ភ្នំពេញ | ១.៥៤០ | ១.៧៥២ | ២.២៦៦ | ២.៥៣១ | ២.៩៥៦ | ៣.៧៤៨ |
| សៀមរាប | ១៧១ | ១៨៨ | ២៣៧ | ២៧០ | ៣១៩ | ៣៧៦ |
| ព្រះសីហនុ | ៥៨ | ៦៩ | ៨០ | ៩៦ | ១៤១ | ១៨៦ |
| កំពង់ចាម | ៣១ | ៣៥ | ៥២ | ៤៤ | ៤៣ | ៦៨ |
| ពញាក្រែក | ២៥ | ៣១ | ៣៨ | ៣៧ | ២៩ | ២៣ |
| មេមត់ | ១០ | ១១ | ១៣ | ១៥ | ១៥ | ១៩ |
| តាកែវ | ៨ | ១២ | ២៤ | ៣៧ | ៥៤ | ៩០ |
| បាត់ដំបង | ៤៥ | ៦៣ | ៩៩ | ១២៧ | ១៦១ | ២២២ |
| កំពត | ១៥ | ៣១ | ៤៩ | ២៩ | ៤៤ | ៨១ |
| កំពង់ត្រាច | ៨ | ១៥ | ១៧ | ១៦ | ១៣ | - |
| ព្រៃវែង | ៤ | ៦ | ១១ | ១៤ | ២០ | ៤២ |
| បន្ទាយមានជ័យ | ២៣ | ២៦ | ៣៦ | ៤៧ | ៧១ | ១០៦ |
| ស្ទឹងត្រែង | ៥ | ៦ | ៨ | ១០ | ១២ | ១៦ |
| រតនគិរី | ៨ | ៩ | ១៦ | ២១ | ២៦ | ៣១ |
| ស្វាយរៀង | ១៧ | ២៣ | ២៤ | ២៦ | ១២៩ | ១៥៩ |
| បាវិត | ៦២ | ៥៥ | ៧១ | ៨៧ | - | - |
| មណ្ឌលគិរី | ១ | ២ | ៣ | ៣ | ៤ | ៥ |
| កែវសីមា | ០,៤ | ១ | ១ | ២ | ៣ | ៣ |
| ក្រចេះ | - | ២ | ៦ | ១០ | ១៥ | ១៨ |
| ស្ទួល | - | ២ | ៦ | ៨ | ១១ | ១០ |
| កំពង់ស្ពឺ | - | ១៦ | ៤២ | ៥២ | ៨៤ | ១៣៧ |
| សរុប | ២.០៣២ | ២.៣៥៤ | ៣.០៩៨ | ៣.៨៨៤ | ៤.១៥២ | ៥.៣៤១ |




**រូបភាពទី៤ : ថាមពលលក់តាមប្រភេទអតិថិជនសម្រាប់ប្រព័ន្ធអគ្គិសនីកម្ពុជានៅឆ្នាំ ២០១៥**




រូបភាពទី៥ : ខ្សែកោងបន្ទុកប្រើប្រាស់អតិបរមាពីឆ្នាំ២០១០ - ២០១៥ ក្នុងប្រព័ន្ធបណ្តាញជាតិ




រូបភាពទី៦ : ថាមពលបាត់បង់លើប្រព័ន្ធបណ្តាញចែកចាយពីឆ្នាំ ២០១០-២០១៥

## តារាងទី ៧ : ចំនួនអតិថិជនតាមខេត្ត-ក្រុងពីឆ្នាំ ២០១០ - ២០១៥

| ទីតាំង | ២០១០ | ២០១១ | ២០១២ | ២០១៣ | ២០១៤ | ២០១៥ |
|---|---|---|---|---|---|---|
| ភ្នំពេញ | ២៤០.៩៩២ | ២៥៦.៦៤២ | ២៧៦.៣០៧ | ២៩៩.៧៧៤ | ៣១៩.៤២៣ | ៥២២.៥១៧ |
| សៀមរាប | ១៩.៩៥១ | ២៦.១៥៦ | ២៨.៧៩១ | ៣២.៧២៥ | ៣៦.៦៩៤ | ៤០.៩៤៩ |
| ព្រះសីហនុ | ១០.៦៣៦ | ១១.៤៧២ | ១២.២៤៦ | ១៣.១៤៦ | ១៤.២៣៨ | ១៥.៩៧៥ |
| កំពង់ចាម | ១០.៤៧៨ | ១១.៧៣៩ | ១២.២៣៩ | ១៣.០០៣ | ១៤.៨៧៦ | ១៦.៩៩៩ |
| ពញាក្រែក | ២.៣៨៦ | ២.៥១៩ | ២.៦៩៤ | ២.៨៤៩ | ២.៩៩៦ | ៣.៩៥៨ |
| មេមត់ | ៤.០១៨ | ៤.២៨៥ | ៤.៩៩២ | ៥.៣២១ | ៥.៥៩១ | ៧.៦០៨ |
| តាកែវ | ៥.៩៨៧ | ៧.៦៨២ | ១១.២០១ | ១៣.០៨១ | ១៥.៦៣៦ | ២០.២០៣ |
| បាត់ដំបង | ៣១.៥៧៥ | ៣២.៧៥៦ | ៣៨.៤៩៨ | ៤០.៧៣៥ | ៤២.៣៣៦ | ៤៥.២១៦ |
| កំពត | ៧.១៧១ | ៧.៧៩៦ | ៩.៣៣២ | ១០.៥៥៩ | ១១.២៣៤ | ១១.៩៨៩ |
| កំពង់ត្រាច | ២.៥១៥ | ២.៦៧៦ | ២.៨៣១ | ៣.៤៩៩ | ៣.៦៧០ | ៤.១៧៦ |
| ព្រៃវែង | ៤.៤៤៧ | ៤.៧២៥ | ៥.៥៣៨ | ៥.៧៩០ | ៦.១១០ | ៦.៤៩៧ |
| បន្ទាយមានជ័យ | ១៤.៨១៦ | ១៦.០៨៥ | ១៧.២១៣ | ១៨.០២២ | ១៩.២១៧ | ២១.១៨៦ |
| ស្ទឹងត្រែង | ២.៦៣៦ | ៣.០៩០ | ៣.៥៦៣ | ៤.៦៦៨ | ៥.៧៨២ | ៦.២៨០ |
| រតនគិរី | ២.៩១០ | ៣.១៩៧ | ៣.៥៣៨ | ៤.២៣៣ | ៤.៧២២ | ៥.២៣៥ |
| ស្វាយរៀង | ១០.៧៩៥ | ១១.៣៩០ | ១០.២៩៨ | ១២.៤៧៤ | ១៣.៨៩២ | ១៦.៥៧៩ |
| បារិត | ២.៤៩៥ | ២.៥៦២ | ៤.៥១៨ | ៣.១៧៤ | ៣.៨០២ | ៦.៧៤២ |
| មណ្ឌលគិរី | ១.៣២៨ | ១.៤៤៤ | ១.៧១៩ | ២.០៧០ | ២.១៩៥ | ២.៣៤៨ |
| កែវសីមា | ៨៦១ | ៩៧៣ | ១.២០២ | ១.៣៣៧ | ១.៥៥៤ | ១.៧៥៣ |
| ក្រចេះ | - | ៣.៥៥២ | ៣.៦៣២ | ៤.៤០៤ | ៤.៧៧៦ | ៦.៧០៧ |
| ស្ទួល | - | ១.០៥១ | ១.០៩៤ | ១.១៦៧ | ១.២៣៨ | ១.៣១១ |
| កំពង់ស្ពឺ | - | ៦.២៧៤ | ៩.៥៤៧ | ១០.៨២៨ | ១១.១៥៩ | ១២.៩៩៦ |
| សរុប | ៣៧៥.៩៩៧ | ៤១៨.០៦៦ | ៤៦០.៩៩៣ | ៥០២.៨៥៩ | ៥៤១.១៤១ | ៧៧៤.៦១៣ |




រូបភាពទី ៧ : ប្រភេទអតិថិជននៅឆ្នាំ ២០១៥

# បណ្តាញខ្សែបញ្ជូន និងចែកចាយ

## បណ្តាញខ្សែបញ្ជូន

ខ្សែបញ្ជូន ១១៥ kV លើកទីមួយមានប្រវែង ២៣ km ដែលតភ្ជាប់ពីអនុស្ថានីយចំនួនបី (អនុស្ថានីយទី១, អនុស្ថានីយទី២ និងអនុស្ថានីយទី៣) នៅក្នុងប្រព័ន្ធបណ្តាញរាជធានីភ្នំពេញ បានផ្គត់ផ្គង់ថាមពលក្នុងឆ្នាំ ១៩៩៩។ នៅឆ្នាំ ២០០២ មានខ្សែបញ្ជូន ១១៥ kV បន្ថែមមួយទៀត ដែលមានប្រវែង ១១១ km ត្រូវបានសាងសង់ ដើម្បីតភ្ជាប់ពីរោងចក្រវារីអគ្គិសនីគិរីរម្យ ១ មកកាន់អនុស្ថានីយទី១។ គោលបំណងដ៏ចម្បងនៃខ្សែបញ្ជូន ដែលមានតង់ស្យុង ១១៥ kV ព័ទ្ធជុំវិញរាជធានីភ្នំពេញ គឺដើម្បីផ្គត់ផ្គង់អគ្គិសនីឲ្យតំបន់រាជធានីភ្នំពេញ និងបង្កើនស្ថិរភាពលើប្រព័ន្ធផ្គត់ផ្គង់ថាមពល រាជធានីភ្នំពេញនេះ ដោយតភ្ជាប់ទៅវិញទៅមករវាងអនុស្ថានីយចំនួនបី។

ខេត្តចំនួនបី ស្ថិតនៅភាគពាយ័ព្យនៃប្រទេសកម្ពុជា មានខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ និងខេត្តសៀមរាប បានផ្គត់ផ្គង់ថាមពលដោយខ្សែបញ្ជូន ១១៥ kV មានប្រវែង ១៨៥ km ដោយនាំចូលថាមពលពីប្រទេសថៃឡង់ដ៍ និងបានដាក់ឲ្យដំណើរការនៅចុងឆ្នាំ២០០៧។

នៅឆ្នាំ ២០០៩ ខ្សែបញ្ជូនតង់ស្យុង ២៣០ kV ជាលើកដំបូងក្នុងប្រវត្តិសាស្ត្ររបស់ប្រទេសកម្ពុជា ដែលមានប្រវែង ៩៧ km បានដាក់ឲ្យបម្រើសេវាកម្មផ្គត់ផ្គង់ ដែលនាំថាមពលពីប្រទេសវៀតណាម ដើម្បីផ្គត់ផ្គង់ថាមពលទៅអនុស្ថានីយតាកែវ និងអនុស្ថានីយខាងលិចភ្នំពេញ (អនុស្ថានីយទី៤)។ ប្រព័ន្ធខ្សែបញ្ជូន ១១៥ kV ដែលតភ្ជាប់អនុស្ថានីយខាងលិចភ្នំពេញ (អនុស្ថានីយទី៤) ទៅភ្ជាប់អនុស្ថានីយទី១ និងអនុស្ថានីយទី២ នៅរាជធានីភ្នំពេញ ត្រូវបានសាងសង់រួច និងដាក់ឲ្យដំណើរការក្នុងឆ្នាំ២០០៩។

នៅឆ្នាំ ២០១១ ខ្សែបញ្ជូនតង់ស្យុង ២៣០ kV ដែលមានប្រវែង ៧៣ km ត្រូវបានពង្រីកចេញពីអនុស្ថានីយ តាកែវទៅអនុស្ថានីយកំពត និងតភ្ជាប់ទៅរោងចក្រវារីអគ្គិសនីកំចាយ តាមខ្សែបញ្ជូន ២៣០ kV មួយទៀត ដែលមានប្រវែង ១១ km ក៏ត្រូវបានដាក់ឲ្យដំណើរការផងដែរនៅចុងឆ្នាំ ២០១១។

ខ្សែបញ្ជូនតង់ស្យុងខ្ពស់ ២៣០ kV ពីរាជធានីភ្នំពេញទៅខេត្តបាត់ដំបង ត្រូវបានចាប់ផ្តើមដាក់ឲ្យដំណើរការក្នុងខែមេសា ឆ្នាំ ២០១២ ដែលមានប្រវែង ៣០០ km និងខ្សែបញ្ជូនតង់ស្យុងខ្ពស់ ២៣០ kV មួយខ្សែទៀត ពីអនុស្ថានីយអូរសោម (ខេត្តកោះកុង) ទៅអនុស្ថានីយខេត្តពោធិ៍សាត់ ស្ថិតក្រោមគម្រោង សាងសង់ ដំណើរការ និងផ្ទេរ (BOT) ដែលមានប្រវែង ១៣០ km កំពុងសាងសង់ ។ ការសាងសង់ខ្សែបណ្តាញ ១១៥ kV ចេញពីអនុស្ថានីយ ២៣០/១១៥/២២ kV របស់ក្រុមហ៊ុន CPG ទៅភ្ជាប់ជាមួយអនុស្ថានីយ ១១៥ kV របស់ក្រុមហ៊ុន CPTL បានដាក់ឲ្យប្រើប្រាស់នៅថ្ងៃទី ០១ ខែកញ្ញា ឆ្នាំ២០១២ ដែលផ្តល់លទ្ធភាពឲ្យបណ្តាញជាតិបញ្ជូន មានសមត្ថភាពពង្រីកវិសាលភាពគ្របដណ្តប់ពីផ្នែកមួយនៃបណ្តាញភាគខាងត្បូង (រាជធានីភ្នំពេញ ខេត្តកណ្តាល ខេត្តកំពង់ស្ពឺ ខេត្តតាកែវ ខេត្តកំពត និងខេត្តកែប) ទៅកាន់បណ្តាញភាគខាងជើងឆៀងខាងលិច (ខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ និងខេត្តសៀមរាប) កាត់តាមខេត្តកំពង់ឆ្នាំង និងខេត្តពោធិ៍សាត់។

នៅឆ្នាំ ២០១៣ ខ្សែបញ្ជូនតង់ស្យុងខ្ពស់ ២៣០ kV ពីខេត្តកំពត ទៅខេត្តព្រះសីហនុ ស្ថិតក្រោមប្រាក់កម្ចីធនាគារអភិវឌ្ឍន៍អាស៊ី (ADB) និងភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA) មានប្រវែង ៨៨ km និងខ្សែបញ្ជូនតង់ស្យុងខ្ពស់ ២៣០ kV មួយខ្សែទៀតពីភ្នំពេញទៅខេត្តកំពង់ចាម ដែលមានប្រវែង ១១០ km ត្រូវបានដាក់ឲ្យដំណើរការ។ គម្រោងទាំងនេះ បានធ្វើឲ្យបណ្តាញជាតិគ្របដណ្តប់លើខេត្តចំនួន ២ បន្ថែមទៀតរួមមាន ខេត្តព្រះសីហនុ និងខេត្តកំពង់ចាម។

នៅឆ្នាំ ២០១៤ ខ្សែបញ្ជូនតង់ស្យុងខ្ពស់ ១១៥ kV ពីអនុស្ថានីយស្ទឹងហាវ ទៅអនុស្ថានីយខេត្តព្រះសីហនុ ស្ថិតក្រោមប្រាក់កម្ចីរបស់ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA) មានប្រវែង ១១ km និងខ្សែបញ្ជូនតង់ស្យុងខ្ពស់ ១១៥ kV ពីអនុស្ថានីយឈ្មូក ទៅអនុស្ថានីយបន្ទាយមាស ក្រោមថវិការបស់អគ្គិសនីកម្ពុជា ដែលមានប្រវែង ១២ km ព្រមទាំងខ្សែបញ្ជូនតង់ស្យុងខ្ពស់ ២៣០ kV ក្នុងគម្រោងខ្សែបញ្ជូនកងជុំវិញរាជធានីភ្នំពេញ ដែលភ្ជាប់ពីអនុស្ថានីយទី៦

ទៅអនុស្ថានីយទី៥ ដែលមានប្រវែង ៤៨ km ស្ថិតក្រោមប្រាក់កម្ចីរបស់ធនាគារចិនអាហារណ៍នីហរណ៍ ត្រូវបានដាក់ឲ្យដំណើរការជាស្ថាពរ។

នៅឆ្នាំ២០១៥ ខ្សែបញ្ជូន ១១៥ kV ពីអនុស្ថានីយទី៧ មកអនុស្ថានីយទី២ ក្នុងគម្រោងខ្សែបញ្ជូនកងតង់ស្យុងខ្ពស់ជុំវិញរាជធានីភ្នំពេញ ស្ថិតក្រោមប្រាក់កម្ចី ធនាគារចិនអាហារណៃនីហរណៃ ត្រូវបានបញ្ចប់ការសាងសង់ និងដាក់ឲ្យដំណើរការ ដើម្បីធានាឲ្យបាននូវការបង្កើនភាពជឿជាក់ខ្ពស់លើប្រភពថាមពលនៅតំបន់ភាគខាងត្បូងនៃរាជធានីភ្នំពេញ។ ខ្សែបញ្ជូនតភ្ជាប់ថ្មីពី អនុស្ថានីយបានហាត ខេត្តចម្ប៉ាសាក់ ប្រទេសឡាវ ទៅស្រុកកំពង់ស្រឡៅ ខេត្តព្រះវិហារ ប្រទេសកម្ពុជា ត្រូវបានរៀបចំ និងសាងសង់សម្រាប់ខ្សែបញ្ជូនតង់ស្យុង ១១៥ kV ប៉ុន្តែបញ្ជូនថាមពលអគ្គិសនីនៅកម្រិតតង់ស្យុង ២២ kV សម្រាប់ដំណាក់កាលដំបូង រហូតដល់ខ្សែបញ្ជូនពីព្រំប្រទល់ឡាវ ទៅអនុស្ថានីយជ័យសែន សាងសង់រួចរាល់។

ខ្សែបញ្ជូនតង់ស្យុងខ្ពស់ពីរាជធានីភ្នំពេញ ទៅក្រុងបាវិត ខេត្តស្វាយរៀង និងពីខេត្តកំពង់ចាម ទៅខេត្តក្រចេះ ខេត្តស្ទឹងត្រែង និងភ្ជាប់បន្តទៅរោងចក្រវារីអគ្គិសនីសេសានក្រោម២ ដែលមានប្រវែងសរុបប្រមាណ ៤២៦ km បាននឹងកំពុងស្ថិតក្រោមការសាងសង់។ គម្រោងទាំងនោះ រំពឹងថានឹងត្រូវបានសាងសង់រួចរាល់ជាស្ថាពរនៅចុងឆ្នាំ ២០១៧។

គម្រោងខ្សែបញ្ជូនជុំវិញបឹងទន្លេសាប ដែលតភ្ជាប់ខេត្តបាត់ដំបង ខេត្តសៀមរាប ខេត្តកំពង់ធំ កំពង់ចាមនិងគម្រោងខ្សែបញ្ជូនកងជុំវិញរាជធានីភ្នំពេញជំហានទី២ (ខាងជើងភ្នំពេញ - ជ្រោយចង្វារ - ខាងកើតភ្នំពេញ - ខាងត្បូងភ្នំពេញ) និងគម្រោងខ្សែបញ្ជូនមួយទៀត ដែលតភ្ជាប់ខេត្តកំពង់ធំ ខេត្តព្រះវិហារ និងព្រំប្រទល់ប្រទេសឡាវ កំពុងស្ថិតក្រោមការសិក្សា។ គម្រោងទាំងនេះ ទទួលបានមូលនិធិពីធនាគារចិនអាហារណៃនីហរណៃ ។

### តារាងទី ៨ : ខ្សែបញ្ជូនតង់ស្យុងខ្ពស់សំខាន់ៗ

| I | ខ្សែបញ្ជូនតង់ស្យុងខ្ពស់ ១១៥ kV | ចំនួនសៀគ្វី | មុខកាត់ខ្សែ (mm$^2$) | ប្រវែងខ្សែ (km) | ឆ្នាំដំណើរការ | ប្រភពទុន |
|---|---|---|---|---|---|---|
| ១ | អនុស្ថានីយទី ១ - អនុស្ថានីយទី ៣ | ១ | ២x២៥០ | ១២ | ១៩៩៩ | ធនាគារពិភពលោក |
| ២ | អនុស្ថានីយទី ៣ - អនុស្ថានីយទី ២ | ១ | ២x២៥០ | ១២ | ១៩៩៩ | ធនាគារពិភពលោក |
| ៣ | អនុស្ថានីយទី១ - អនុស្ថានីយកំពង់ស្ពឺ | ១ | ១៥០ | ៤១ | ២០០២ | BOT |
| ៤ | អនុស្ថានីយកំពង់ស្ពឺ - គិរីរម្យ ១ | ១ | ១៥០ | ៦៥ | ២០០២ | BOT |
| ៥ | ព្រំដែនថៃ - អនុស្ថានីយ IE | ២ | ៤០០ | ៤ | ២០០៧ | BOT |
| ៦ | អនុស្ថានីយ IE - អនុស្ថានីយបន្ទាយមានជ័យ | ២ | ៤០០ | ៤៣ | ២០០៧ | BOT |
| ៧ | អនុស្ថានីយបន្ទាយមានជ័យ-អនុស្ថានីយសៀមរាប | ១ | ៤០០ | ៨៥ | ២០០៧ | BOT |
| ៨ | អនុស្ថានីយបន្ទាយមានជ័យ-អនុស្ថានីយបាត់ដំបង | ១ | ៤០០ | ៥៣ | ២០០៧ | BOT |
| ៩ | អនុស្ថានីយទី៤ - អនុស្ថានីយទី១ | ១ | ២x២៥០ | ៣០ | ២០០៩ | ធនាគារពិភពលោក |
| ១០ | អនុស្ថានីយទី៤ - KEP | ១ | ២x២៥០ | ២៣ | ២០០៩ | ធនាគារពិភពលោក |
| ១១ | KEP - អនុស្ថានីយទី ២ | ១ | ២x២៥០ | ៧ | ២០០៩ | ធនាគារពិភពលោក |
| ១២ | គិរីរម្យ ១ - គិរីរម្យ ៣ | ១ | ១៥០ | ៣២ | ២០១២ | BOT |
| ១៣ | រោងចក្រវារីអគ្គិសនីស្ទឹងអាតៃ - អនុស្ថានីយអូរសោម | ២ | ៦៣០ | ១៨ | ២០១៣ | BOT |

## តារាងទី ៨ : ខ្សែបញ្ជូនតង់ស្យុងខ្ពស់សំខាន់ៗ (ត)

| I | ខ្សែបញ្ជូនតង់ស្យុងខ្ពស់ ១១៥ kV | ចំនួនសៀគ្វី | មុខកាត់ខ្សែ (mm²) | ប្រវែងខ្សែ (km) | ឆ្នាំដំណើរការ | ប្រភពទុន |
|---|---|---|---|---|---|---|
| ១៤ | អនុស្ថានីយស្ទឹងហាវ-អនុស្ថានីយខេត្តព្រះសីហនុ | ២ | ៤០០ | ១១ | ២០១៤ | JICA |
| ១៥ | អនុស្ថានីយឈូក - អនុស្ថានីយបន្ទាយមាស | ១ | ៤០០ | ១២ | ២០១៤ | អគ្គិសនីកម្ពុជា |
| ១៦ | ខ្សែបញ្ជូនកងជុំវិញរាជធានីភ្នំពេញ | ២ | ២x២៥០ | ៤៥ | ២០១៥ | ធនាគារចិន អាហារ័ណនីហារ័ណ |
| ប្រវែងខ្សែសរុប | | | | ៤៩៣ km | | |

| II | ខ្សែបញ្ជូនតង់ស្យុងខ្ពស់ ២៣០ kV | ចំនួនសៀគ្វី | មុខកាត់ខ្សែ (mm²) | ប្រវែងខ្សែ (km) | ឆ្នាំដំណើរការ | ប្រភពទុន |
|---|---|---|---|---|---|---|
| ១ | ព្រំដែនវៀតណាម - អនុស្ថានីយតាកែវ | ២ | ៤០០ | ៥០ | ២០០៩ | ADB - NDF |
| ២ | អនុស្ថានីយតាកែវ - អនុស្ថានីយទី៤ | ២ | ៦៣០ | ៤៧ | ២០០៩ | ADB - NDF |
| ៣ | អនុស្ថានីយតាកែវ - អនុស្ថានីយកំពត | ២ | ៤៥០ | ៧៣ | ២០១១ | KfW |
| ៤ | អនុស្ថានីយកំពត - រោងចក្រវារីអគ្គិសនីកំចាយ | ២ | ៤០០ | ១១ | ២០១២ | BOT |
| ៥ | អនុស្ថានីយទី៤ - អនុស្ថានីយទី៦ - អនុស្ថានីយកំពង់ឆ្នាំង - អនុស្ថានីយពោធិ៍សាត់ - អនុស្ថានីយបាត់ដំបង | ២ | ២x៦៣០ | ២៩៧ | ២០១២ | BOT |
| ៦ | អនុស្ថានីយពោធិ៍សាត់ - អនុស្ថានីយអូរសោម | ២ | ២x៦៣០ | ១៣២ | ២០១២ | BOT |
| ៧ | អនុស្ថានីយកំពត - អនុស្ថានីយស្ទឹងហាវ | ២ | ៦៣០ | ៨២ | ២០១៣ | ADB - JICA |
| ៨ | អនុស្ថានីយទី៦(ខាងជើងភ្នំពេញ) - អនុស្ថានីយកំពង់ចាម | ២ | ២x៤០០ | ៩៧ | ២០១៣ | BOT |
| ៩ | អនុស្ថានីយអូរសោម - រោងចក្រវារីអគ្គិសនីស្ទឹងឫស្សីជ្រុំក្រោម | ២ | ២x៤០០ | ៤២ | ២០១៣ | BOT |
| ១០ | ជុំវិញរាជធានីភ្នំពេញ (ខាងលិច - ខាងត្បូងភ្នំពេញ) | ២ | ២x៦៣០ | ២៤ | ២០១៤ | ធនាគារចិន អាហារ័ណ នីហារ័ណ |
| ១១ | រោងចក្រវារីអគ្គិសនីស្ទឹងឫស្សីជ្រុំលើក្រោម - រោងចក្រវារីអគ្គិសនីស្ទឹងតាតៃ | ២ | ២x៤០០ | ៣៨ | ២០១៤ | BOT |
| ប្រវែងខ្សែសរុប | | | | ៨៩៣ km | | |

## តារាងទី ៩ : អនុស្ថានីយអគ្គិសនីតង់ស្យុងខ្ពស់

| ល.រ | អនុស្ថានីយ | តង់ស្យុង (kV) | ចំនួនត្រង់ស្វូម៉ាទ័រ | អានុភាពសរុប (MVA) | ឆ្នាំដំណើរការ |
|---|---|---|---|---|---|
| ១ | អនុស្ថានីយទី១ | ១១៥/២២ | ២ x ៧៥ | ១៥០ | ២០១៣ |
| ២ | អនុស្ថានីយទី២ | ១១៥/២២ | ៣ x ៥០ | ១៥០ | ១៩៩៩ បន្ថែម ១គ្រឿង ឆ្នាំ ២០១៣ |

## តារាងទី ៩ : អនុស្ថានីយអគ្គិសនីតង់ស្យុងខ្ពស់ (ត)

| ល.រ | អនុស្ថានីយ | តង់ស្យុង (kV) | ចំនួនត្រង់ស្វូម៉ាទ័រ | អានុភាព (MVA) | ឆ្នាំដំណើរការ |
|---|---|---|---|---|---|
| ៣ | អនុស្ថានីយទី៣ | ១១៥/២២ | ២ x ៥០ | ១០០ | ១៩៩៩ |
| | | ១១៥/២២/១៥ | ១ x ៥០ | ៥០ | ២០១៣ |
| ៤ | អនុស្ថានីយកំពង់ស្ពឺ | ១១៥/២២ | ១ x ៥០ | ៥០ | ២០០២ |
| ៥ | អនុស្ថានីយបាត់ដំបង(CPTL) | ១១៥/២២ | ១ x ២៥ | ២៥ | ២០០៧ |
| ៦ | អនុស្ថានីយបន្ទាយមានជ័យ | ១១៥/២២ | ១ x ២៥ | ២៥ | ២០០៧ |
| ៧ | អនុស្ថានីយសៀមរាប | ១១៥/២២ | ២ x ៥០ | ១០០ | ២០០៧ បន្ថែម ១គ្រឿង ឆ្នាំ ២០១៤ |
| ៨ | អនុស្ថានីយទី៤ (ខាងលិចភ្នំពេញ) | ២៣០/១១៥ | ២ x ១០០ | ២០០ | ២០០៩ |
| | | ១១៥/២២ | ២ x ៥០ | ១០០ | |
| ៩ | អនុស្ថានីយតាកែវ | ២៣០/២២ | ១ x ៥០ | ៥០ | ២០០៩ |
| ១០ | អនុស្ថានីយកំពត | ២៣០/២២ | ១ x ៥០ | ៥០ | ២០១១ |
| ១១ | អនុស្ថានីយកំពង់ឆ្នាំង | ២៣០/២២ | ១ x ២៥ | ២៥ | ២០១២ |
| ១២ | អនុស្ថានីយពោធិ៍សាត់ | ២៣០/២២ | ១ x ២៥ | ២៥ | ២០១២ |
| ១៣ | អនុស្ថានីយបាត់ដំបង(CPG) | ២៣០/១១៥/២២ | ២ x ៩០ | ១៨០ | ២០១២ បន្ថែម ១គ្រឿង ឆ្នាំ ២០១៥ |
| ១៤ | អនុស្ថានីយទី៥ | ១១៥/២២ | ២ x ៥០ | ១០០ | ២០១៣ |
| ១៥ | អនុស្ថានីយស្ទឹងហាវ | ២៣០/២២ | ១ x ៥០ | ៥០ | ២០១៣ |
| ១៦ | អនុស្ថានីយទី៦ (ខាងជើងភ្នំពេញ) | ១១៥/២២ | ១ x ៥០ | ៥០ | ២០១៣ |
| | | ២៣០/១១៥ | ២ x ២០០ | ៤០០ | |
| ១៧ | អនុស្ថានីយអូរសោម | ២៣០/១១៥/២២ | ១ x ១៥០ | ១៥០ | ២០១៣ |
| ១៨ | អនុស្ថានីយកំពង់ចាម | ១១៥/២២ | ២ x ៥០ | ១០០ | ២០១៣ បន្ថែម ១គ្រឿង ឆ្នាំ ២០១៥ |
| ១៩ | អនុស្ថានីយឈូក | ២៣០/១១៥ | ១ x ១០០ | ១០០ | ២០១៤ |
| ២០ | អនុស្ថានីយខេត្តព្រះសីហនុ | ១១៥/២២ | ១ x ៥០ | ៥០ | ២០១៤ |
| ២១ | អនុស្ថានីយបន្ទាយមាស (SWS) | ១១៥ | - | - | ២០១៤ |
| ២២ | អនុស្ថានីយទី៧ (ខាងត្បូងភ្នំពេញ) | ២៣០/១១៥ | ១ x ២០០ | ២០០ | ២០១៥ |
| | | ១១៥/២២ | ១ x ៥០ | ៥០ | |
| ២៣ | អនុស្ថានីយស្ទឹងតាតៃ | ២៣០/៣៥/២២ | ១ x ៦០ | ៦០/៦០/៤០ | ២០១៥ |
| ២៤ | អនុស្ថានីយ IE | ១១៥/២២ | ១ x ៥០ | ៥០ | ២០១៥ |

## បណ្តាញខ្សែចែកចាយ

បណ្តាញចែកចាយ និងបណ្តាញបញ្ជូនរងរបស់អគ្គិសនីកម្ពុជា ជាទូទៅ គឺមានតង់ស្យុង ២២ kV និងតង់ស្យុងទាប ០,៤/០,២៣ kV ។ អំឡុងឆ្នាំ២០០៩ និង ២០១០ បណ្តាញចែកចាយនៅរាជធានីភ្នំពេញ ខេត្តកំពង់ស្ពឺ ខេត្តព្រៃវែង

ស្រុកបានលុង (ខេត្តរតនគិរី) ខេត្តស្ទឹងត្រែង និងខេត្តព្រះសីហនុ ត្រូវបានសាងសង់បន្ថែម ដើម្បីបង្កើនប្រសិទ្ធភាពនៃការផ្គត់ផ្គង់។ ចំពោះទិន្នន័យលម្អិតរបស់ខ្សែបណ្ដាញប្រភេទតង់ស្យុងខុសៗគ្នាដូចមានបង្ហាញក្នុងតារាងបន្ទាប់។

គម្រោងអគ្គិសនីភាវូបនីយកម្មជនបទ ដែលស្ថិតក្រោមប្រាក់កម្ចីរបស់ធនាគារចិនអាហារណែនីហារណែ (China Exim Bank) កំពុងដំណើរការសាងសង់ប្រព័ន្ធចែកចាយតង់ស្យុងមធ្យម ដែលគ្របដណ្ដប់ខេត្តចំនួន ០៤ រួមមាន ខេត្តកំពង់ចាម ខេត្តព្រៃវែង ខេត្តកំពង់ស្ពឺ និងខេត្តព្រះសីហនុ ដែលមានប្រវែងសរុប ២.០០០ km ។ បន្ថែមពីនេះ គម្រោងអគ្គិសនីភាវូបនីយកម្មជនបទដំណាក់កាលទី២ ស្ថិតក្រោមមូលនិធិរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលគ្របដណ្ដប់ខេត្តចំនួន ៦ រួមមាន ខេត្តក្រចេះ ខេត្តស្ទឹងត្រែង ខេត្តរតនគិរី ខេត្តមណ្ឌលគិរី ខេត្តឧត្តរមានជ័យ និងខេត្តសៀមរាប ដែលមានប្រវែងសរុបប្រមាណ ១.២០០ km បានចាប់ផ្ដើមសាងសង់ ហើយរំពឹងថារួចរាល់ជាស្ថាពរនៅឆ្នាំ ២០១៦។

ឥណទានសម្រាប់ការសាងសង់ខ្សែបណ្ដាញចែកចាយប្រវែង ២.០៤០ km និងខ្សែបណ្ដាញបញ្ជូន តង់ស្យុងខ្ពស់ប្រវែង ២២០ km ដែលគ្របដណ្ដប់ខេត្តចំនួន ១៤ រួមមាន៖ ខេត្តកណ្ដាល ខេត្តកំពង់ស្ពឺ ខេត្តកំពង់ឆ្នាំង ខេត្តពោធិ៍សាត់ ខេត្តសៀមរាប ខេត្តឧត្តរមានជ័យ ខេត្តព្រះវិហារ ខេត្តកំពង់ចាម ខេត្តក្រចេះ ខេត្តស្ទឹងត្រែង ខេត្តរតនគិរី ខេត្តមណ្ឌលគិរី ខេត្តកោះកុង និងខេត្តព្រះសីហនុ ត្រូវបានផ្ដល់ឲ្យជាបន្តបន្ទាប់ដោយធនាគារចិនអាហារណែនីហារណែ (China Export Import Bank) សម្រាប់គម្រោងដំណាក់កាលទី២, ៣ និង ៤ ។

## តារាងទី ១០ : ទិន្នន័យសន្ទេបនៃប្រព័ន្ធចែកចាយ និងបញ្ជូនរង

| ទីតាំង | ប្រភេទ | ២០១០ | ២០១១ | ២០១២ | ២០១៣ | ២០១៤ | ២០១៥ |
|---|---|---|---|---|---|---|---|
| ភ្នំពេញ និង កណ្តាល | ប្រវែងខ្សែ,cct-km | ១.៨៧៧ | ២.០៥៨ | ២.៥៧៣ | ៣.៥៨៦ | ៣.៧៧៩ | ៤.១៨៧ |
| | តង់ស្យុងមធ្យម | ៩៣៣ | ១.០៧៦ | ១.២៨៧ | ២.២០៤ | ២.៣២៥ | ២.៦៤១ |
| | តង់ស្យុងទាប | ៩៤៥ | ៩៨២ | ១.២៨៥ | ១.៣៨២ | ១.៤៥៣ | ១.៥៤៦ |
| | បន្ទប់ភ្លើងសរុប | ១.៥៩១ | ១.៨៧៥ | ២.១៧០ | ២.៣៨៥ | ២.៦៦៥ | ២.៩៩៤ |
| | បន្ទប់ភ្លើង | - | - | - | - | ១.០៧៦ | ១.២១៨ |
| | ប៉ុស្តិ៍លើបង្គោល | - | - | - | - | ១.៥៨៩ | ១.៧៧៦ |
| កំពង់ស្ពឺ | ប្រវែងខ្សែ,cct-km | ១១៦ | ១២៨ | ១៥២ | ៨០៦ | ៨២៥ | ៨០១ |
| | តង់ស្យុងមធ្យម | ៦១ | ៧៤ | ៩៦ | ៦៧៣ | ៦៨៣ | ២៤២ |
| | តង់ស្យុងទាប | ៥៥ | ៥៤ | ៥៦ | ១៣២ | ១៤២ | ១៦០ |
| | បន្ទប់ភ្លើងសរុប | ២៣ | ៦២ | ៧១ | ៨៧ | ៩៥ | ១០២ |
| | បន្ទប់ភ្លើង | - | - | - | - | - | ៣ |
| | ប៉ុស្តិ៍លើបង្គោល | - | - | - | - | ៩៥ | ៩៩ |
| សៀមរាប | ប្រវែងខ្សែ,cct-km | ៤១៧ | ៦២៦ | ៦៥៨ | ៧៣៦ | ៨០៨ | ១.១២៩ |
| | តង់ស្យុងមធ្យម | ១៩២ | ៣៥០ | ៣៦៨ | ៤១៤ | ៤៦២ | ៧៤៩ |
| | តង់ស្យុងទាប | ២២៥ | ២៧៦ | ២៩០ | ៣២២ | ៣៤៦ | ៣៨០ |
| | បន្ទប់ភ្លើងសរុប | ១២៦ | ១៥៨ | ១៨៤ | ១៩៦ | ២៣០ | ៣០៨ |
| | បន្ទប់ភ្លើង | - | - | - | - | ១៣២ | ១៤១ |
| | ប៉ុស្តិ៍លើបង្គោល | - | - | - | - | ៩៨ | ១៦៧ |
| ព្រះសីហនុ | ប្រវែងខ្សែ,cct-km | ២៨៤ | ២៩៨ | ២៩៨ | ៣០៤ | ៣៦២ | ៥០៣ |
| | តង់ស្យុងមធ្យម | ២០៣ | ២០៤ | ២០៤ | ២០៨ | ២៦៦ | ៤០១ |
| | តង់ស្យុងទាប | ៨០ | ៩៤ | ៩៤ | ៩៦ | ៩៦ | ១០៣ |
| | បន្ទប់ភ្លើងសរុប | ១៩៤ | ១៥៥ | ១៧៨ | ១៨៧ | ២៨១ | ៣១២ |
| | បន្ទប់ភ្លើង | - | - | - | - | ៥១ | ៥៤ |
| | ប៉ុស្តិ៍លើបង្គោល | - | - | - | - | ២៣០ | ២៥៨ |
| កំពង់ចាម | ប្រវែងខ្សែ,cct-km | ១៤២ | ១៤៤ | ១៤៥ | ១៥០ | ៦៦៧ | ៧៣២ |
| | តង់ស្យុងមធ្យម | ៥១ | ៥១ | ៥១ | ៥២ | ៥៤៨ | ៦០៧ |
| | តង់ស្យុងទាប | ៩១ | ៩៣ | ៩៤ | ៩៨ | ១១៩ | ១២៥ |
| | បន្ទប់ភ្លើងសរុប | ៥២ | ៥៩ | ៥៩ | ៦៤ | ១៤១ | ២០១ |
| | បន្ទប់ភ្លើង | - | - | - | - | ៦ | ៦ |
| | ប៉ុស្តិ៍លើបង្គោល | - | - | - | - | ១៣៥ | ១៩៥ |
| ពញាក្រែក | ប្រវែងខ្សែ,cct-km | ៤០ | ៤៤ | ៤៥ | ៤៥ | ៦៤ | ៧៥ |
| | តង់ស្យុងមធ្យម | ២៤ | ២៧ | ២៧ | ២៧ | ៤៦ | ៥០ |
| | តង់ស្យុងទាប | ១៦ | ១៧ | ១៨ | ១៨ | ១៨ | ២៥ |
| | បន្ទប់ភ្លើងសរុប | ២៧ | ៣១ | ៣១ | ២១ | ៣៣ | ៤៣ |
| | បន្ទប់ភ្លើង | - | - | - | - | - | - |
| | ប៉ុស្តិ៍លើបង្គោល | - | - | - | - | ៣៣ | ៤៣ |

## តារាងទី ១០ : ទិន្នន័យសង្ខេបនៃប្រព័ន្ធចែកចាយ និងបញ្ជូនខេត្ត(ត)

| ទីតាំង | ប្រភេទ | ២០១០ | ២០១១ | ២០១២ | ២០១៣ | ២០១៤ | ២០១៥ |
|---|---|---|---|---|---|---|---|
| មេមត់ | ប្រវែងខ្សែ,cct-km | ៤៦ | ៤៦ | ៤៦ | ៤៨ | ២១៦ | ២៤៦ |
| | តង់ស្យុងមធ្យម | ២៣ | ២៣ | ២៣ | ២៣ | ១៨៩ | ១៨៩ |
| | តង់ស្យុងទាប | ២៣ | ២៣ | ២៣ | ២៥ | ២៦ | ៥៦ |
| | បន្ទប់ភ្លើងសរុប | ៣១ | ៣៧ | ៣៧ | ២៤ | ២៥ | ៧៧ |
| | បន្ទប់ភ្លើង | - | - | - | - | - | - |
| | ប៉ុស្តិ៍លើបង្គោល | - | - | - | - | ២៥ | ៧៧ |
| តាកែវ | ប្រវែងខ្សែ,cct-km | ១០៦ | ២៨០ | ២៨០ | ៣៦៨ | ៥៦៧ | ៧៤៦ |
| | តង់ស្យុងមធ្យម | ៣២ | ១៥៨ | ១៥៨ | ១៥៨ | ៣១៦ | ៣៥៣ |
| | តង់ស្យុងទាប | ៧៤ | ១២២ | ១២២ | ២១០ | ២៥១ | ៣៩៤ |
| | បន្ទប់ភ្លើងសរុប | ៣១ | ១០១ | ១០៤ | ១១៣ | ១៦៧ | ១៨៨ |
| | បន្ទប់ភ្លើង | - | - | - | - | ១៧ | ២៥ |
| | ប៉ុស្តិ៍លើបង្គោល | - | - | - | - | ១៥០ | ១៦៣ |
| បាត់ដំបង | ប្រវែងខ្សែ,cct-km | ២៤៩ | ៦៤៣ | ៦៤៣ | ៦៩២ | ៦៩១ | ៦៩៦ |
| | តង់ស្យុងមធ្យម | ៧៥ | ៤០១ | ៤០១ | ៤៤៤ | ៤៤៤ | ៤៤៧ |
| | តង់ស្យុងទាប | ១៧៤ | ២៤២ | ២៤២ | ២៤៧ | ២៤៧ | ២៤៩ |
| | បន្ទប់ភ្លើងសរុប | ៧៩ | ២២៧ | ២២៨ | ២៤០ | ២៤០ | ២៥២ |
| | បន្ទប់ភ្លើង | - | - | - | - | - | ១ |
| | ប៉ុស្តិ៍លើបង្គោល | - | - | - | - | ២៤០ | ២៥១ |
| កំពត | ប្រវែងខ្សែ,cct-km | ១៤៨ | ២៩០ | ៣៣៩ | ៣៣៩ | ៣៣៩ | ៤៣៦ |
| | តង់ស្យុងមធ្យម | ៦៨ | ២០៦ | ២២៧ | ២២៧ | ២២៧ | ៣១១ |
| | តង់ស្យុងទាប | ៧៩ | ៨៤ | ១១២ | ១១២ | ១១២ | ១២៥ |
| | បន្ទប់ភ្លើងសរុប | ៣៨ | ៧១ | ៩០ | ១០៥ | ១០៥ | ១៨៧ |
| | បន្ទប់ភ្លើង | - | - | - | - | - | - |
| | ប៉ុស្តិ៍លើបង្គោល | - | - | - | - | ១០៥ | ១៨៧ |
| កំពង់ត្រាច | ប្រវែងខ្សែ,cct-km | ៤៥ | ៤៥ | ៦០ | ៧៦ | ៧៦ | ១០០ |
| | តង់ស្យុងមធ្យម | ២៥ | ២៥ | ៣៩ | ៤៧ | ៤៧ | ៤៨ |
| | តង់ស្យុងទាប | ២០ | ២០ | ២១ | ២៩ | ២៩ | ៥២ |
| | បន្ទប់ភ្លើងសរុប | ២៤ | ៣១ | ៣៦ | ៤៤ | ៤៤ | ៤៧ |
| | បន្ទប់ភ្លើង | - | - | - | - | ១ | ១ |
| | ប៉ុស្តិ៍លើបង្គោល | - | - | - | - | ៤៣ | ៤៦ |
| ព្រៃវែង | ប្រវែងខ្សែ,cct-km | ១០០ | ១០០ | ១១២ | ៤៧៤ | ៧៩០ | ៧៩៤ |
| | តង់ស្យុងមធ្យម | ៥៣ | ៥៣ | ៥៦ | ៤១៧ | ៧៣១ | ៧៣១ |
| | តង់ស្យុងទាប | ៤៧ | ៤៧ | ៥៧ | ៥៧ | ៥៩ | ៦៣ |
| | បន្ទប់ភ្លើងសរុប | ១៧ | ១៧ | ២០ | ២១ | ១៩៤ | ២០២ |
| | បន្ទប់ភ្លើង | - | - | - | - | - | ៤ |
| | ប៉ុស្តិ៍លើបង្គោល | - | - | - | - | ១៩៤ | ១៩៨ |

## តារាងទី ១០ : ទិន្នន័យសង្ខេបនៃប្រព័ន្ធចែកចាយ និងបញ្ជូនរង(ត)

| ទីតាំង | ប្រភេទ | ២០១០ | ២០១១ | ២០១២ | ២០១៣ | ២០១៤ | ២០១៥ |
|---|---|---|---|---|---|---|---|
| បន្ទាយមានជ័យ | ប្រវែងខ្សែ,cct-km | ១៣៦ | ១៦០ | ១៧១ | ១៧៤ | ១៨១ | ២២៩ |
| | តង់ស្យុងមធ្យម | ៣០ | ៤១ | ៤៦ | ៤៩ | ៥១ | ៦៥ |
| | តង់ស្យុងទាប | ១០៧ | ១១៨ | ១២៥ | ១២៥ | ១៣០ | ១៦៤ |
| | បន្ទប់ភ្លើងសរុប | ៣៣ | ៣៩ | ៥០ | ៥៥ | ៦០ | ៨៦ |
| | បន្ទប់ភ្លើង | - | - | - | - | - | ៨ |
| | ប៉ុស្តិ៍លើបង្គោល | - | - | - | - | ៦០ | ៧៨ |
| មង្គលបូរី | ប្រវែងខ្សែ,cct-km | ៥០ | ៦៤ | ៨២ | ៨២ | ៨២ | ៨៩ |
| | តង់ស្យុងមធ្យម | ១៥ | ៣០ | ៤៥ | ៤៥ | ៤៥ | ៤៦ |
| | តង់ស្យុងទាប | ៣៤ | ៣៤ | ៣៧ | ៣៧ | ៣៧ | ៤៤ |
| | បន្ទប់ភ្លើងសរុប | ១៧ | ២៦ | ៣៥ | ៣៥ | ៣៩ | ៤២ |
| | បន្ទប់ភ្លើង | - | - | - | - | - | - |
| | ប៉ុស្តិ៍លើបង្គោល | - | - | - | - | ៣៩ | ៤២ |
| ស្ទឹងត្រែង | ប្រវែងខ្សែ,cct-km | ៧៤ | ១៣៣ | ១៣៣ | ២០២ | ២៤០ | ២៤០ |
| | តង់ស្យុងមធ្យម | ៤០ | ៩២ | ៩២ | ១៣២ | ១៥១ | ១៥១ |
| | តង់ស្យុងទាប | ៣៤ | ៤១ | ៤១ | ៧០ | ៨៩ | ៨៩ |
| | បន្ទប់ភ្លើងសរុប | ១៤ | ២៥ | ២៣ | ៣៧ | ៤៨ | ៥៣ |
| | បន្ទប់ភ្លើង | - | - | - | - | - | ៤ |
| | ប៉ុស្តិ៍លើបង្គោល | - | - | - | - | ៤៨ | ៤៩ |
| រតនគិរី | ប្រវែងខ្សែ,cct-km | ៥៤ | ១២៤ | ១៣០ | ១៣៩ | ១៤១ | ១៦៧ |
| | តង់ស្យុងមធ្យម | ២០ | ៩០ | ៩០ | ៩២ | ៩២ | ១០៣ |
| | តង់ស្យុងទាប | ៣៤ | ៣៤ | ៤០ | ៤៧ | ៤៩ | ៦៣ |
| | បន្ទប់ភ្លើងសរុប | ១៤ | ៣០ | ៥០ | ៧២ | ៨៥ | ១០៣ |
| | បន្ទប់ភ្លើង | - | - | - | - | ១ | ៥ |
| | ប៉ុស្តិ៍លើបង្គោល | - | - | - | - | ៨៤ | ៩៨ |
| ស្វាយរៀង | ប្រវែងខ្សែ,cct-km | ២១៨ | ៤០៦ | ៤១៨ | ៤១៩ | ៦០៥ | ៣៦៩ |
| | តង់ស្យុងមធ្យម | ១២៨ | ៣១៤ | ៣២៥ | ៣២៥ | ៤៦៦ | ១៥៤ |
| | តង់ស្យុងទាប | ៩០ | ៩២ | ៩២ | ៩៤ | ១៣៩ | ២១៥ |
| | បន្ទប់ភ្លើងសរុប | ៥៣ | ៥៦ | ៧១ | ៥៤ | ៧៦ | ១១៤ |
| | បន្ទប់ភ្លើង | - | - | - | - | - | ៥ |
| | ប៉ុស្តិ៍លើបង្គោល | - | - | - | - | ៧៦ | ១០៩ |
| បាវិត | ប្រវែងខ្សែ,cct-km | ៣២ | ៤០ | ១៧៤ | ១៨៦ | - | - |
| | តង់ស្យុងមធ្យម | ១១ | ១២ | ១៤១ | ១៤១ | - | - |
| | តង់ស្យុងទាប | ២១ | ២៨ | ៣៣ | ៤៤ | - | - |
| | បន្ទប់ភ្លើងសរុប | ៣៥ | ៥០ | ៥០ | ២១ | - | - |
| | បន្ទប់ភ្លើង | - | - | - | - | - | - |
| | ប៉ុស្តិ៍លើបង្គោល | - | - | - | - | - | - |

## តារាងទី ១០ : ទិន្នន័យសង្ខេបនៃប្រព័ន្ធចែកចាយ និងបញ្ជូនរង(ត)

| ទីតាំង | ប្រភេទ | ២០១០ | ២០១១ | ២០១២ | ២០១៣ | ២០១៤ | ២០១៥ |
|---|---|---|---|---|---|---|---|
| មណ្ឌលគិរី | ប្រវែងខ្សែ,cct-km | ៦២ | ៦៤ | ១០៩ | ១២០ | ១២៥ | ១៣៣ |
| | តង់ស្យុងមធ្យម | ៣០ | ៣២ | ៦៩ | ៧៣ | ៧៧ | ៨៥ |
| | តង់ស្យុងទាប | ៣២ | ៣២ | ៤០ | ៤៧ | ៤៧ | ៤៨ |
| | បន្ទប់ភ្លើងសរុប | ៤០ | ៤២ | ៤៩ | ៥៤ | ៥៥ | ៧៦ |
| | បន្ទប់ភ្លើង | - | - | - | - | - | - |
| | ប៉ុស្តិ៍លើបង្គោល | - | - | - | - | ៥៥ | ៧៦ |
| កែវសីមា | ប្រវែងខ្សែ,cct-km | ៤៤ | ៤៤ | ៦៤ | ៧៨ | ៨៩ | ៩០ |
| | តង់ស្យុងមធ្យម | ២០ | ២០ | ៣៣ | ៤៦ | ៤៨ | ៤៨ |
| | តង់ស្យុងទាប | ២៤ | ២៤ | ៣១ | ៣២ | ៤១ | ៤២ |
| | បន្ទប់ភ្លើងសរុប | ១៦ | ១៦ | ២២ | ២២ | ២៦ | ៣០ |
| | បន្ទប់ភ្លើង | - | - | - | - | - | - |
| | ប៉ុស្តិ៍លើបង្គោល | - | - | - | - | ២៦ | ៣០ |
| ក្រចេះ | ប្រវែងខ្សែ,cct-km | - | ៤៧ | ១៣៦ | ១៦០ | ១៦០ | ២២៥ |
| | តង់ស្យុងមធ្យម | - | ២៩ | ១១៧ | ១២៣ | ១២៣ | ១៣៩ |
| | តង់ស្យុងទាប | - | ១៨ | ១៩ | ៣៨ | ៣៨ | ៨៥ |
| | បន្ទប់ភ្លើងសរុប | - | ១៣ | ៤៤ | ៤៩ | ៥៣ | ៧១ |
| | បន្ទប់ភ្លើង | - | - | - | - | - | - |
| | ប៉ុស្តិ៍លើបង្គោល | - | - | - | - | ៥៣ | ៧១ |
| ស្នួល | ប្រវែងខ្សែ,cct-km | - | - | ៣៣ | ៣៣ | ៣៣ | ៣៧ |
| | តង់ស្យុងមធ្យម | - | - | ១៩ | ១៩ | ២០ | ២៤ |
| | តង់ស្យុងទាប | - | - | ១៤ | ១៤ | ១៤ | ១៤ |
| | បន្ទប់ភ្លើងសរុប | - | - | ២៥ | ២៨ | ៣២ | ៤០ |
| | បន្ទប់ភ្លើង | - | - | - | - | - | - |
| | ប៉ុស្តិ៍លើបង្គោល | - | - | - | - | ៣២ | ៤០ |
| សរុប | ប្រវែងខ្សែ,cct-km | ៤.២៣៩ | ៥.៧៨៥ | ៦.៨០០ | ៩.២១៦ | ១០.៨៣៨ | ១១.៦២២ |
| | តង់ស្យុងមធ្យម | ២.០៣៤ | ៣.៣០៩ | ៣.៩១៥ | ៥.៩៣៩ | ៧.៣៥៦ | ៧.៥៨៣ |
| | តង់ស្យុងទាប | ២.២០៦ | ២.៤៧៦ | ២.៨៨៥ | ៣.២៧៧ | ៣.៤៨២ | ៤.០៤០ |
| | បន្ទប់ភ្លើងសរុប | ២.៤០៥ | ៣.១២១ | ៣.៦២៧ | ៣.៩១៤ | ៤.៦៩៤ | ៥.៥២៨ |
| | បន្ទប់ភ្លើង | - | - | - | - | ១.២៨៤ | ១.៤៧៥ |
| | ប៉ុស្តិ៍លើបង្គោល | - | - | - | - | ៣.៤១០ | ៤.០៥៣ |

# មូលនិធិអគ្គិសនីភាវូបនីយកម្មជនបទ នៃអគ្គិសនីកម្ពុជា ( ម.អ.ជ )

រាជរដ្ឋាភិបាលបានចេញព្រះរាជក្រឹត្យលេខ នស/រកត/១២០៤/០៤៨ ចុះថ្ងៃទី ៤ ខែ ធ្នូ ឆ្នាំ ២០០៤ ស្តីពីការបង្កើតស្ថាប័ន មូលនិធិអគ្គិសនីភាវូបនីយកម្មជនបទនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីជំរុញការអភិវឌ្ឍន៍អគ្គិសនីភាវូបនីយកម្មជនបទ។ បន្ទាប់មកនៅថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០១២ រាជរដ្ឋាភិបាលកម្ពុជា បានចេញព្រះរាជក្រឹត្យថ្មីមួយទៀតលេខ នស/រកត/០៨១២/៧៣៤ ដោយធ្វើវិសោធនកម្មមាត្រាខ្លះនៃព្រះរាជក្រឹត្យចាស់ ដោយផ្ទេរស្ថាប័នមូលនិធិអគ្គិសនីភាវូបនីយកម្មជនបទ ឲ្យស្ថិតនៅក្រោមការគ្រប់គ្រងរបស់អគ្គិសនីកម្ពុជាវិញ ដើម្បីឲ្យកម្ពុជាខ្លួនឯងអាចម្ចាស់ការបន្តប្រតិបត្តិការការងាររបស់មូលនិធិអគ្គិសនីភាវូបនីយកម្មជនបទផង និងក៏នៅតែអាចទទួលនូវអំណោយ និងជំនួយនានាពីខាងក្រៅមកជួយអភិវឌ្ឍន៍អគ្គិសនីភាវូបនីយកម្មជនបទកម្ពុជាបានផង។

## សកម្មភាពការងារដែល ម.អ.ជ សម្រេចបានក្នុងឆ្នាំ២០១៥

ក្នុងឆ្នាំ២០១៥ ថវិការបស់ ម.អ.ជ គឺទទួលបានពីអគ្គិសនីកម្ពុជា និងធនាគារអភិវឌ្ឍន៍អាល្លឺម៉ង់ (KfW)។ ក្នុងឆ្នាំ២០១៥ អគ្គិសនីកម្ពុជាបានផ្តល់ថវិកាចំនួន ៩ លានដុល្លារអាមេរិក សម្រាប់ចំណាយប្រតិបត្តិការ របស់ ម.អ.ជ. និងអនុវត្តន៍កម្មវិធីអភិវឌ្ឍន៍អគ្គិសនីភាវូបនីយកម្មជនបទ និងធនាគារអភិវឌ្ឍន៍អាល្លឺម៉ង់បានផ្តល់ថវិកាចំនួន ២,៤៩ លានដុល្លាអាមេរិក សម្រាប់អនុវត្តន៍កម្មវិធីអភិវឌ្ឍន៍អគ្គិសនីភាវូបនីយកម្មជនបទ សរុបចំនួន ១១,៤៩ លានដុល្លាអាមេរិក។ កម្មវិធីទាំង៣នេះរួមមាន៖

១. **កម្មវិធីផ្តល់ចរន្តអគ្គិសនីដល់គ្រួសារក្រីក្រ៖** គោលបំណងនៃកម្មវិធីនេះ គឺជួយដល់គ្រួសារក្រីក្ររស់នៅតំបន់ជនបទ ដើម្បីឲ្យពួកគាត់អាចទទួលបានការតភ្ជាប់ចរន្តអគ្គិសនីពីប្រព័ន្ធផ្គត់ផ្គង់អគ្គិសនី ដោយការផ្តល់ប្រាក់កម្ចីអនុគ្រោះគ្មានការប្រាក់ឲ្យពួកគាត់ខ្ចីយកទៅ៖ ១-បង់ថ្លៃភ្ជាប់ចរន្តឲ្យអ្នកផ្គត់ផ្គង់ ២-បង់ថ្លៃប្រាក់កក់ឲ្យអ្នកផ្គត់ផ្គង់ ៣-ចំណាយលើការទិញ និងរាយខ្សែពីចំណុចភ្ជាប់ចរន្តមកដល់ផ្ទះរបស់ខ្លួន និង ៤-ចំណាយលើការរៀបចំខ្សែបណ្តាញ និងឧបករណ៍អគ្គិសនីក្នុងផ្ទះ ដើម្បីតភ្ជាប់ចរន្តអគ្គិសនីចូលផ្ទះ។ ប្រាក់កម្ចីនេះនឹងទូទាត់តាមរយៈអ្នកផ្គត់ផ្គង់អគ្គិសនី ដែលជាអ្នកទទួលខុសត្រូវក្នុងការបង់សងត្រឡប់មក ម.អ.ជ. វិញ ដោយបានមកពីការប្រមូលពីអ្នកខ្ចីដែលត្រូវបង់សងរំលស់១ខែម្តងមក ម.អ.ជ. ក្នុងរយៈពេល ៣ឆ្នាំ។ ចំនួនទឹកប្រាក់កម្ចីនេះ គឺមិនលើសពី ៤៨០.០០០ រៀល ក្នុង ១ គ្រួសារ។ ក្នុងឆ្នាំ២០១៥ នេះ មានគ្រួសារជនបទចំនួន ១.៦២២ គ្រួសារ ស្មើនឹង ៧.៤៦១ នាក់ ដែលបានទទួលផលដោយផ្ទាល់ក្រោមកម្មវិធីនេះ។

២. **កម្មវិធីប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យតាមផ្ទះ៖** គោលបំណងនៃកម្មវិធីនេះ គឺជួយសម្រួលឲ្យគ្រួសារជនបទរស់នៅតំបន់ដាច់ស្រយាល ដែលខ្សែបណ្តាញអគ្គិសនីមិនទាន់អាចពង្រីកទៅដល់ក្នុងរយៈពេលយូរ អាចទទួលបានអគ្គិសនីប្រើប្រាស់តាមរយៈប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យតាមផ្ទះ។ ម.អ.ជ. ជួយផ្តល់ប្រាក់ឧបត្ថម្ភធនចំនួន ១០០ ដុល្លារអាមេរិកក្នុង ១ ប្រព័ន្ធ ដល់គ្រួសារជនបទ ដើម្បីជួយកាត់បន្ថយការទូទាត់ថ្លៃទិញប្រព័ន្ធ ហើយអ្នកទិញត្រូវបង់ថ្លៃសល់ពីការឧបត្ថម្ភធននេះ រំលស់ប្រចាំខែដោយគ្មានការប្រាក់មក ម.អ.ជ. វិញក្នុងរយៈពេល ៤ឆ្នាំ។ ក្រោយពេលបង់រំលស់អស់ជាស្ថាពរ ប្រព័ន្ធនេះនឹងក្លាយជាកម្មសិទ្ធិរបស់អ្នកទិញ។ ក្នុងឆ្នាំ២០១៥ មានគ្រួសារជនបទចំនួន ១១.២៤០ គ្រួសារ ស្មើនឹង ៥១.៧០៤ នាក់ បានទទួលផលដោយផ្ទាល់ក្រោមកម្មវិធីនេះ។

៣. **កម្មវិធីជួយទុនសម្រាប់ពង្រីក និងកែលម្អការផ្គត់ផ្គង់អគ្គិសនីនៅតំបន់ជនបទ៖** គោលបំណងនៃកម្មវិធីនេះគឺជួយសម្រួលឲ្យអ្នកផ្គត់ផ្គង់អគ្គិសនីនៅតំបន់ជនបទ ដែលមានអាជ្ញាប័ណ្ណស្របច្បាប់ អាចមានទុនសម្រាប់វិនិយោគពង្រីក និងកែលម្អការផ្គត់ផ្គង់អគ្គិសនី ឲ្យពេញដែនអាជ្ញាប័ណ្ណចែកចាយរបស់ខ្លួន ដើម្បីឲ្យប្រជាពលរដ្ឋគ្រប់គ្រួសារអាចភ្ជាប់ចរន្តប្រើប្រាស់តាមលទ្ធភាពរបស់ខ្លួន ។ ក្នុងឆ្នាំ២០១៥ ម.អ.ជ បានផ្តល់ថវិកាជួយទុនសម្រាប់ពង្រីក និងកែលម្អការផ្គត់ផ្គង់អគ្គិសនីដល់សេវាករអគ្គិសនីសាងសង់ខ្សែបណ្តាញ MV និង LV សរុបចំនួន ២.៣៧៥ គីឡូម៉ែត្រ។

# ផែនការអភិវឌ្ឍន៍វិស័យថាមពលអគ្គិសនីនៅព្រះរាជាណាចក្រកម្ពុជា

## គោលនយោបាយអភិវឌ្ឍន៍វិស័យថាមពល

រាជរដ្ឋាភិបាលកម្ពុជា បានដាក់ចេញនូវគោលនយោបាយអភិវឌ្ឍន៍វិស័យថាមពលអគ្គិសនីនៅ ខែ តុលា ឆ្នាំ ១៩៩៤ ដែលមានទិសដៅដូចខាងក្រោម៖

- ផ្តល់នូវការផ្គត់ផ្គង់ថាមពលអគ្គិសនីឲ្យបានគ្រប់គ្រាន់ទូទាំងប្រទេសកម្ពុជា ក្នុងតម្លៃសមរម្យ។
- ធានានូវការផ្គត់ផ្គង់ថាមពលអគ្គិសនីឲ្យមាននិរន្តភាព និងសុវត្ថិភាព ដែលធ្វើឲ្យមានភាពងាយស្រួលដល់ការវិនិយោគក្នុងប្រទេសកម្ពុជា និងការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ។
- ជួយជំរុញនូវរបកគំហើញថ្មីៗ និងការអភិវឌ្ឍន៍នៃប្រភពផលិតថាមពលដែលមិនប៉ះពាល់ដល់បរិស្ថាន និងសង្គម ដែលជាតម្រូវការចាំបាច់សម្រាប់ផ្គត់ផ្គង់ថាមពលដល់គ្រប់វិស័យទាំងអស់នៃសេដ្ឋកិច្ចជាតិ។
- លើកទឹកចិត្តនូវការប្រើប្រាស់ថាមពលអគ្គិសនីឲ្យមានប្រសិទ្ធភាព និងកាត់បន្ថយផលប៉ះពាល់បរិស្ថាននូវកម្រិតអប្បបរមាពីប្រភពផ្គត់ផ្គង់ និងការប្រើប្រាស់ ។

## ការព្យាករណ៍តម្រូវការថាមពល

ដោយផ្អែកទៅលើឯកសារស្តីពីផែនការមេ នៃការអភិវឌ្ឍន៍វិស័យថាមពលអគ្គិសនី នៃព្រះរាជាណាចក្រកម្ពុជា ដែលបានរៀបចំឡើងនៅឆ្នាំ ២០១៥ បានកត់សម្គាល់ថា តម្រូវការថាមពលអគ្គិសនី នឹងមានកំណើនដ៏គួរឲ្យកត់សម្គាល់មួយក្នុងរយៈពេល ១៥ ឆ្នាំខាងមុខនេះ។ តម្រូវការសម្រាប់ផលិតថាមពលនៅព្រះរាជាណាចក្រកម្ពុជា នឹងមានកំណើនពី ២.២៤២ GWh និង ៤០៩ MW នៅឆ្នាំ ២០១០ ទៅ ១៤.៩៥១ GWh និង ២.៦៧៨ MW នៅឆ្នាំ ២០២៥។ ដើម្បីបំពេញតម្រូវការនាពេលអនាគត រាជរដ្ឋាភិបាលកម្ពុជា បានបង្កើតផែនការអភិវឌ្ឍន៍ថាមពលរហូតដល់ឆ្នាំ ២០៣០ ។

មួយភាគធំនៃកំណើនតម្រូវការប្រើប្រាស់ថាមពលស្ថិតនៅភាគខាងត្បូងនៃប្រទេស ដែលរួមបញ្ចូលទាំងរាជធានីភ្នំពេញផងដែរ ។ តារាងខាងក្រោមពណ៌នាពីការព្យាករណ៍អានុភាពអតិបរមា និងថាមពលបញ្ចេញសម្រាប់ព្រះរាជាណាចក្រកម្ពុជា។

### តារាងទី ១១ : ការព្យាករណ៍តម្រូវការថាមពលអគ្គិសនី នៅព្រះរាជាណាចក្រកម្ពុជា

| ករណីមូលដ្ឋាន | ២០១៥ | ២០២០ | ២០២៥ |
|---|---|---|---|
| អានុភាពអតិបរមាក្នុងបណ្តាញជាតិ (MW) | ៩៥១* | ១.៦៨១ | ២.៦៧៨ |
| អានុភាពអតិបរមាក្នុងប្រទេស (MW) | ១.១០៣ | | |
| ថាមពលក្នុងបណ្តាញជាតិ (GWh) | ៥.៦៩៨* | ៩.៤០៦ | ១៤.៩៥១ |
| ថាមពលក្នុងប្រទេស (GWh) | ៦.០១៥** | | |

* ថាមពល និងអានុភាពអតិបរមាក្នុងបណ្តាញជាតិ គឺជាទិន្នន័យជាក់ស្តែងក្នុងឆ្នាំ ២០១៥

** ថាមពលក្នុងប្រទេស គឺជាទិន្នន័យរបស់អាជ្ញាធរអគ្គិសនីកម្ពុជា

## ផែនការមេនៃការផលិតថាមពល

ផែនការមេនៃការផលិតថាមពល ត្រូវបានអភិវឌ្ឍដោយផ្អែកលើលក្ខណៈវិនិច្ឆ័យដូចខាងក្រោម ៖

- ការផលិតថាមពលដើរដោយរោងចក្រអគ្គិសនីដែលមានស្រាប់ សម្រាប់ប្រព័ន្ធភ្នំពេញនៅពេលបន្ទុកអតិបរមា។
- ប្រើប្រាស់ម៉ាស៊ីនឌីយ៉េស៊ែលខ្នាតតូច និងមធ្យម ដើម្បីជួយក្នុងការផលិតថាមពល សម្រាប់ចែករំលែកក្នុងបន្ទុកធម្មតា និងមានបន្ទុកអតិបរមានៅតាមបណ្តាខេត្ត-ក្រុង (សម្រាប់រយៈពេលខ្លី)។
- ពង្រីកការអភិវឌ្ឍន៍ផ្នែកវារីអគ្គិសនី ដោយមូលដ្ឋាននៃការអភិវឌ្ឍន៍លើរោងចក្រវារីអគ្គិសនីខ្នាតតូច ដែលមានភាពងាយស្រួលក្នុងការចូលអភិវឌ្ឍដូចជាៈ រោងចក្រវារីអគ្គិសនីគិរីរម្យ១ និង ៣, និងគម្រោងរោងចក្រវារីអគ្គិសនីខ្នាតមធ្យម និងធំ ជាបន្តបន្ទាប់ដូចជាៈ រោងចក្រវារីអគ្គិសនីសេសានក្រោម២, រោងចក្រវារីអគ្គិសនីបាត់ដំបង, រោងចក្រវារីអគ្គិសនីស្រែពកក្រោម២ ។

## តារាងទី ១២ : ផែនការអភិវឌ្ឍន៍ផ្នែកផលិតកម្មសម្រាប់ឆ្នាំ ២០១៦ - ២០៣០

| ល.រ | ឈ្មោះគម្រោង | ប្រភេទ | អានុភាព (MW) | ឆ្នាំដំណើរការ |
|---|---|---|---|---|
| ១ | រោងចក្រអគ្គិសនីដុតធ្យូងថ្ម (CIIDG) ១៣៥ MW | ធ្យូងថ្ម | ១២០ | ២០១៧ |
| ២ | រោងចក្រវារីអគ្គិសនីសេសានក្រោម២ | វារីអគ្គិសនី | ៤០០ | ២០១៨ |
| ៣ | រោងចក្រអគ្គិសនីដុតធ្យូងថ្មទី១ | ធ្យូងថ្ម | ១០០ | ២០១៩ |
| ៤ | រោងចក្រអគ្គិសនីដុតធ្យូងថ្មទី២ | ធ្យូងថ្ម | ១២០ | |
| ៥ | រោងចក្រអគ្គិសនីដុតធ្យូងថ្មទី៣ | ធ្យូងថ្ម | ២៥០ | ២០២០ |
| ៦ | រោងចក្រអគ្គិសនីដុតធ្យូងថ្មទី៤ | ធ្យូងថ្ម | ២៥០ | ២០២១ |
| ៧ | រោងចក្រវារីអគ្គិសនីស្ទឹងជាយអារ៉ែង | វារីអគ្គិសនី | ១០៨ | ២០២២ |
| ៨ | រោងចក្រវារីអគ្គិសនីស្ទឹងពោធិ៍សាត់១ | វារីអគ្គិសនី | ៤០ | ២០២៣ |
| ៩ | រោងចក្រវារីអគ្គិសនីស្ទឹងបាត់ដំបង២ | វារីអគ្គិសនី | ៣៦ | |
| ១០ | រោងចក្រវារីអគ្គិសនីសេសានក្រោម៣ | វារីអគ្គិសនី | ២៦០ | |
| ១១ | រោងចក្រវារីអគ្គិសនីស្រែពក៣ (៣ខ) | វារីអគ្គិសនី | ៦៨ | ២០២៤ |
| ១២ | រោងចក្រវារីអគ្គិសនីស្រែពក៤ | វារីអគ្គិសនី | ៤៨ | |
| ១៣ | រោងចក្រវារីអគ្គិសនីស្រែពក៣ (៣ក) | វារីអគ្គិសនី | ៣០០ | |
| ១៤ | រោងចក្រវារីអគ្គិសនីព្រែកល្ពាង១ | វារីអគ្គិសនី | ៧២ | ២០២៥ |
| ១៥ | រោងចក្រវារីអគ្គិសនីព្រែកល្ពាង២ | វារីអគ្គិសនី | ៥០ | |
| ១៦ | រោងចក្រវារីអគ្គិសនីព្រែកឆ្លង២ | វារីអគ្គិសនី | ១៦ | |
| ១៧ | រោងចក្រវារីអគ្គិសនីសេសានក្រោម១ | វារីអគ្គិសនី | ៩៦ | |
| ១៨ | រោងចក្រវារីអគ្គិសនីព្រែកពោធិ៍ | វារីអគ្គិសនី | ១៧ | |
| ១៩ | រោងចក្រវារីអគ្គិសនីសេកុង | វារីអគ្គិសនី | ១៩០ | |
| ២០ | រោងចក្រអគ្គិសនីដើរដោយថាមពលកំដៅ១ | ធ្យូងថ្ម/ហ្គាស | ៣០០ | |
| សរុប | | | ២.៨៤១ MW | |

## តារាងទី ១៣ : ផែនការមេនៃប្រព័ន្ធខ្សែបញ្ជូន
## ផែនការអភិវឌ្ឍន៍ផ្នែកប្រព័ន្ធខ្សែបញ្ជូន សម្រាប់ឆ្នាំ ២០១៦ - ២០២៥

| ល.រ | ខ្សែបញ្ជូនអគ្គិសនីតង់ស្យុងខ្ពស់ ១១៥ kV | ប្រវែងខ្សែ (km) | ឆ្នាំដំណើរការ | ដៃគូអភិវឌ្ឍន៍ |
|---|---|---|---|---|
| ១ | អនុស្ថានីយសៀមរាប - អនុស្ថានីយសៀមរាបថ្មីខាងកើត | ២៥ | ២០១៦ | BOT |
| ២ | អនុស្ថានីយទី២ - សួនច្បារសម្តេច ហ៊ុន សែន និង អនុស្ថានីយ | ៥ | ២០១៧ | សាងសង់ ផ្ទេរ (BT) |
| ៣ | អនុស្ថានីយទី៧ (ខាងត្បូងភ្នំពេញ) - អនុស្ថានីយព្រៃវែង - អនុស្ថានីយបាវិត | ១៦០ | | ធនាគារចិន អាហារ័ណនីហារ័ណ |
| ៤ | ព្រំប្រទល់ឡាវ - អនុស្ថានីយព្រះវិហារ | ៦០ | ២០១៧ | ធនាគារចិន អាហារ័ណនីហារ័ណ |
| ៥ | អនុស្ថានីយបាត់ដំបង - អនុស្ថានីយប៉ៃលិន | ៨០ | | អគ្គិសនីកម្ពុជា |
| ៦ | អនុស្ថានីយទី៣ - អនុស្ថានីយទួលគោក | ៥ | | អគ្គិសនីកម្ពុជា |
| ៧ | អនុស្ថានីយទី៥ - អនុស្ថានីយជ្រោយចង្វារ | ១៨ | | សល់ពីគម្រោងជុំវិញរាជធានីភ្នំពេញ ធនាគារចិន អាហារ័ណនីហារ័ណ |
| ៨ | អនុស្ថានីយកំពង់ចាម - អនុស្ថានីយព្រែកប្រសប់(ក្រចេះ) | ៩១ | ២០១៨ | ទីភ្នាក់ងារអភិវឌ្ឍន៍បារាំង |
| ៩ | អនុស្ថានីយស្វាយអន្ទរ - អនុស្ថានីយព្រៃវែង | ៤៦ | | ធនាគារចិន អាហារ័ណនីហារ័ណ |
| ១០ | អនុស្ថានីយខេត្តព្រះសីហនុ - អនុស្ថានីយរាម | ១២ | | ធនាគារចិន អាហារ័ណនីហារ័ណ |
| ១១ | អនុស្ថានីយរាម - អនុស្ថានីយចំការលួង | ៦០ | | កំពុងស្វែងរកដៃគូអភិវឌ្ឍន៍ |
| ១២ | អនុស្ថានីយចំការលួង - រោងចក្រវារីអគ្គិសនីគិរីរម្យ៣ | ២៧ | | កំពុងស្វែងរកដៃគូអភិវឌ្ឍន៍ |
| ១៣ | អនុស្ថានីយកំពង់ធំ - អនុស្ថានីយព្រះវិហារ | ១៤០ | | ធនាគារចិន អាហារ័ណនីហារ័ណ |
| ១៤ | អនុស្ថានីយក្រឡាញ់ - អនុស្ថានីយឧត្តរមានជ័យ | ៨០ | | កំពុងស្វែងរកដៃគូអភិវឌ្ឍន៍ |
| ១៥ | ខ្សែបញ្ជូនកប់ដីពីអនុស្ថានីយទី១ - អគ្គិសនីកម្ពុជា(វត្តភ្នំ) - សួនច្បារសម្តេច ហ៊ុន សែន - អនុស្ថានីយអូឡាំពិក - អង្គភាពមជ្ឈមណ្ឌលជាតិបញ្ជូន - អនុស្ថានីយទី៣ | ១៤ | ២០១៩ | JICA ជំហានទី១ |
| ១៦ | អនុស្ថានីយព្រែកប្រសប់ - អនុស្ថានីយក្រចេះ | ៣០ | ២០២១ | កំពុងស្វែងរកដៃគូអភិវឌ្ឍន៍ |
| | ប្រវែងខ្សែសរុប | ៨៥៣ km | | |

## ផែនការអភិវឌ្ឍន៍ផ្នែកប្រព័ន្ធខ្សែបញ្ជូន សម្រាប់ឆ្នាំ ២០១៦ - ២០២៥ (ត)

| ល.រ | ខ្សែបញ្ជូនអគ្គិសនីតង់ស្យុងខ្ពស់ ២៣០ kV | ប្រវែងខ្សែ (km) | ឆ្នាំ ដំណើរការ | ដៃគូអភិវឌ្ឍន៍ |
|---|---|---|---|---|
| ១ | អនុស្ថានីយកំពង់ចាម - អនុស្ថានីយក្រចេះ | ១២៥ | ២០១៧ | BOT |
| ២ | អនុស្ថានីយក្រចេះ - អនុស្ថានីយស្ទឹងត្រែង | ១១៥ | | ធនាគារឥណ្ឌា អ៊ិចស៊ីម |
| ៣ | អនុស្ថានីយស្ទឹងត្រែង - រោងចក្រវារីអគ្គិសនីសេសានក្រោម២ | ២៦ | | BOT |
| ៤ | អនុស្ថានីយបាត់ដំបង - សៀមរាប - កំពង់ធំ - កំពង់ចាម | ៣៥០ | ២០១៨ | ធនាគារចិន អាហរ័ណនីហរ័ណ |
| ៥ | ជុំវិញរាជធានីភ្នំពេញជំហានទី២ (ខាងជើង - ជ្រោយចង្វារ - ខាងកើត - ខាងជើង) | ៩៦ | ២០១៨ | ធនាគារចិន អាហរ័ណនីហរ័ណ |
| ៦ | រោងចក្រវារីអគ្គិសនីតាតៃ - ភ្នំពេញ | ១៨២ | | BOT |
| ៧ | អនុស្ថានីយកោះកុង - អនុស្ថានីយក្រុងកោះកុង | ២០ | | ទីភ្នាក់ងារ អភិវឌ្ឍន៍បារាំង |
| ៨ | អនុស្ថានីយចំការលួង - អនុស្ថានីយបុទុមសាគរ | ៥៤ | | |
| ៩ | អនុស្ថានីយបុទុមសាគរ - រោងចក្រវារីអគ្គិសនីតាតៃ | ៧០ | | កំពុងស្វែងរក ដៃគូអភិវឌ្ឍន៍ |
| ១០ | អនុស្ថានីយក្រចេះ - អនុស្ថានីមណ្ឌលគិរី | ១៧០ | ២០១៩ | ធនាគារចិន អាហរ័ណនីហរ័ណ |
| ១១ | អនុស្ថានីយរតនគិរី - អនុស្ថានីយស្ទឹងត្រែង | ១២០ | | ធនាគារចិន អាហរ័ណនីហរ័ណ |
| ១២ | អនុស្ថានីយស្ទឹងត្រែង - ព្រំប្រទល់ឡាវ PDR | ៤៨ | | កំពុងស្វែងរក ដៃគូអភិវឌ្ឍន៍ |
| ១៣ | អនុស្ថានីយបែកចាន - អនុស្ថានីយទី៥ - អង្គភាពមជ្ឈមណ្ឌលជាតិបញ្ជូន | ២០ | ២០២០ | JICA ជំហានទី២ |
| ១៤ | អនុស្ថានីយត្រពាំងប្រាសាទ - អនុស្ថានីយសៀមរាប | ៣០ | ២០២១ | BOT |
| | ប្រវែងខ្សែសរុប | ១.៤២៦ km | | |

| ល.រ | ខ្សែបញ្ជូនអគ្គិសនីតង់ស្យុងខ្ពស់ 500 kV | ប្រវែងខ្សែ (km) | ឆ្នាំ ដំណើរការ | ដៃគូអភិវឌ្ឍន៍ |
|---|---|---|---|---|
| ១ | រាជធានីភ្នំពេញ - ខេត្តព្រះសីហានុ | ១៩៨ | ២០១៩ | BOT |
| ២ | រាជធានីភ្នំពេញ - ក្រុងសួង | ៩៦ | ២០២១ | កំពុងស្វែងរក ដៃគូអភិវឌ្ឍន៍ |
| ៣ | ក្រុងសួង - សំបូរ - ស្ទឹងត្រែង | - | ២០២៥ | កំពុងស្វែងរក ដៃគូអភិវឌ្ឍន៍ |
| | ប្រវែងខ្សែសរុប | ២៩៤ km | | |

# ការតភ្ជាប់បណ្តាញអគ្គិសនីជាមួយប្រទេសជិតខាង

## ការតភ្ជាប់បណ្តាញអគ្គិសនីជាមួយប្រទេសថៃឡង់ដ៍

កិច្ចព្រមព្រៀងសហប្រតិបត្តិការថាមពលជាមួយប្រទេសថៃឡង់ដ៍ ត្រូវបានចុះហត្ថលេខា នៅថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០០០។ កិច្ចព្រមព្រៀងនេះ បានផ្តល់នូវក្របខណ្ឌការងារសម្រាប់ការធ្វើពាណិជ្ជកម្មថាមពល និងជំនួយបច្ចេកទេសរវាងប្រទេសទាំងពីរនេះ និងបើកឲ្យថាមពលអគ្គិសនីចូលទៅប្រទេសទីបី។ កិច្ចព្រមព្រៀងទិញ-លក់ថាមពល បានចុះហត្ថលេខានៅឆ្នាំ ២០០២ និងបានកែសម្រួលនៅឆ្នាំ២០០៧ ។ កិច្ចព្រមព្រៀងនេះ បានជំរុញឲ្យប្រើប្រាស់រួមគ្នា នូវធនធានធម្មជាតិដែលមានស្រាប់របស់ប្រទេសទាំងពីរ។ នៅពេលដែលប្រភពបញ្ចូលគ្នានឹងត្រូវបង្កើតឡើង ប្រទេសទាំងពីរអាចចូលរួមដោយទូលាយលើការផ្គត់ផ្គង់ថាមពល និងការទទួលថាមពល ។

ខ្សែបញ្ជូន ១១៥ kV ចេញពីអនុស្ថានីយអារញ្ញប្រាថេត ប្រទេសថៃឡង់ដ៍ ភ្ជាប់ទៅខេត្តបន្ទាយមានជ័យ ខេត្តបាត់ដំបង និងខេត្តសៀមរាប បានដាក់ឲ្យដំណើរការក្នុងឆ្នាំ ២០០៧។ ថាមពលអគ្គិសនីរវាងប្រទេសកម្ពុជា និងប្រទេសថៃឡង់ដ៍ ត្រូវបានបញ្ជូនដោយតង់ស្យុង ២២ kV និង ១១៥ kV ។ កិច្ចព្រមព្រៀងមួយ បានចុះហត្ថលេខាជាមួយខេត្តត្រាតនៃប្រទេសថៃឡង់ដ៍ ដើម្បីផ្គត់ផ្គង់ថាមពលឲ្យខេត្តកោះកុង និងក្រុងប៉ោយប៉ែតនៃប្រទេសកម្ពុជា ដោយប្រើបណ្តាញ ២២ kV ។ តំបន់ខាងលើបានភ្ជាប់ថាមពលតាំងពីឆ្នាំ ២០០១ ។

## ការតភ្ជាប់បណ្តាញអគ្គិសនីជាមួយប្រទេសវៀតណាម

កិច្ចសហប្រតិបត្តិការថាមពលជាមួយប្រទេសវៀតណាម បានចុះហត្ថលេខានៅថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ១៩៩៩។ កិច្ចព្រមព្រៀងនេះ មានបំណងសហប្រតិបត្តិការក្នុងវិស័យថាមពល រវាងប្រទេសទាំងពីរ ។ ការផ្គត់ផ្គង់ថាមពលឲ្យតំបន់តាមបណ្តោយព្រំដែន ដោយខ្សែបណ្តាញតង់ស្យុងមធ្យម និងការតភ្ជាប់ទៅវិញទៅមករវាងខ្សែបញ្ជូនតង់ស្យុងខ្ពស់ ត្រូវបានជំរុញ។

អគ្គិសនីកម្ពុជាបាននាំចូលថាមពលពីប្រទេសវៀតណាមតាមខ្សែបញ្ជូន ២៣០ kV ផ្គត់ផ្គង់នៅភ្នំជិនក្នុងខេត្តតាកែវ ក្នុងឆ្នាំ២០០៩ ។ អគ្គិសនីកម្ពុជាបានភ្ជាប់ខ្សែបញ្ជូន ២៣០ kV សម្រាប់នាំចូលថាមពលពីប្រទេសវៀតណាមមកភ្នំពេញ និងបានដាក់ឲ្យដំណើរការនៅខែ មីនា ឆ្នាំ២០០៩។ អគ្គិសនីកម្ពុជា បាននាំថាមពលពី PC2 ដើម្បីផ្គត់ផ្គង់នៅស្រុកមេមត់ និងស្រុកពញាក្រែក ខេត្តកំពង់ចាម បាវិតនៅខេត្តស្វាយរៀង កំពង់ត្រាចនៅខេត្តកំពត កោះធំ និងជ្រៃធំនៅខេត្តកណ្តាល ស្រុកស្នួលនៅខេត្តក្រចេះ ស្រុកកែវសីមានៅខេត្តមណ្ឌលគិរី ស្រុកកំពង់រោទិ៍នៅខេត្តស្វាយរៀងនៅឆ្នាំ២០០២។

## ការតភ្ជាប់បណ្តាញអគ្គិសនីជាមួយប្រទេសឡាវ

កិច្ចសហប្រតិបត្តិការថាមពល ជាមួយប្រទេសឡាវ ត្រូវបានចុះហត្ថលេខានៅថ្ងៃទី ២១ ខែតុលា ឆ្នាំ ១៩៩៩ ។ កិច្ចព្រមព្រៀងនេះ មានគោលបំណងសហប្រតិបត្តិការក្នុងវិស័យថាមពល រវាងប្រទេសទាំងពីរ។ ការផ្គត់ផ្គង់ថាមពលដល់តំបន់តាមបណ្តោយព្រំដែន ដោយបណ្តាញតង់ស្យុងមធ្យម ២២ kV និងការតភ្ជាប់បណ្តាញជាមួយបណ្តាញតង់ស្យុងខ្ពស់ ត្រូវបានជំរុញ។ ការតភ្ជាប់បណ្តាញតង់ស្យុង ២២ kV ពីខេត្តចម្ប៉ាសាក់ ប្រទេសឡាវ មក ខេត្តស្ទឹងត្រែង ត្រូវបានដាក់ឲ្យដំណើរការនៅឆ្នាំ២០១០។

នៅឆ្នាំ២០១៥ ខ្សែបញ្ជូនតភ្ជាប់ថ្មីពី អនុស្ថានីយបានហាត ខេត្តចម្ប៉ាសាក់ ប្រទេសឡាវ ទៅស្រុកកំពង់ស្រឡៅ ខេត្តព្រះវិហារ ប្រទេសកម្ពុជា ត្រូវបានរៀបចំ និងសាងសង់សម្រាប់ខ្សែបញ្ជូនតង់ស្យុង ១១៥ kV ប៉ុន្តែបញ្ជូនថាមពលអគ្គិសនីនៅកម្រិតតង់ស្យុង ២២ kV សម្រាប់ដំណាក់កាលដំបូង រហូតដល់ខ្សែបញ្ជូនពីព្រំប្រទល់ឡាវទៅអនុស្ថានីយជ័យសែន សាងសង់រួចរាល់។

## ការតភ្ជាប់បណ្តាញអនុតំបន់

ការសិក្សាតភ្ជាប់រវាងបណ្តាញ ដែលនៅដាច់ដោយឡែកពីប្រទេសមួយទៅប្រទេសមួយនៅក្នុងអនុតំបន់អាងទន្លេមេគង្គ (កម្ពុជា ឡាវ ថៃឡង់ដ៍ វៀតណាម យូណាន - ប្រទេសចិន និងប្រទេសភូមា) និងសូម្បីតែបណ្តាញប្រទេសម៉ាឡេស៊ី និងសឹង្ហបូរី ក៏ត្រូវបានយកមកធ្វើការសិក្សាផងដែរ ដោយមានគោលបំណងធ្វើឲ្យប្រសើរឡើងនូវការប្រើប្រាស់ប្រភពថាមពល។ របាយការណ៍ស្តីពី ផែនការមេនៃការតភ្ជាប់បណ្តាញរបស់អាស៊ានត្រូវបានសិក្សាបញ្ចប់នៅឆ្នាំ ២០០២ ដែលបង្ហាញពីការសិក្សាមួយយ៉ាងច្បាស់ ស្តីពីការតភ្ជាប់បណ្តាញរបស់អាស៊ាន។ បច្ចុប្បន្នមានការពិនិត្យឡើងវិញ អំពីផែនការមេនៃការតភ្ជាប់បណ្តាញរបស់អាស៊ាននេះ ដោយក្រុមសិក្សានៃបណ្តាប្រទេសអាស៊ាន។

ការសិក្សាផ្តល់ភាគច្រើន លើការវាយតម្លៃលើអាទិភាព និងលទ្ធភាពជោគជ័យនៃការតភ្ជាប់ខ្សែបណ្តាញទៅវិញទៅមកនៅក្នុងតំបន់ ដោយផ្អែកលើការសិក្សាបុរេសមិទ្ធិលទ្ធភាព។ ការសិក្សាបានស្នើឲ្យមានការអភិវឌ្ឍន៍បណ្តាញថាមពលអាស៊ាន (APG) ដោយបានបង្កើតគណៈកម្មាធិការទីប្រឹក្សាបណ្តាញថាមពលអាស៊ាន។ យ៉ាងណាក៏ដោយ ក្នុងចំណោមការសិក្សាតភ្ជាប់បណ្តាញចំនួន ១០ របស់អាស៊ាន ការតភ្ជាប់បណ្តាញរវាងប្រទេសកម្ពុជា និងប្រទេសវៀតណាម ជាប់លំដាប់ទី៤ និងបានចាត់ថ្នាក់ថាជាគម្រោង ដែលមានសក្តានុពលពីរយៈពេលខ្លីទៅរយៈពេលមធ្យម ដែលគួរបញ្ចប់គម្រោងនេះមុនឆ្នាំ ២០១០ ។




រូបភាពទី ១០: ផែនការអភិវឌ្ឍន៍ខ្សែបញ្ជូន ឆ្នាំ ២០១៥-២០២០

# ទិន្នន័យហិរញ្ញវត្ថុ

**អគ្គិសនីកម្ពុជា**
**តារាងតុល្យការ**
នាថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០១៥

| | ២០១៥<br>ពាន់រៀល | ២០១៤<br>ពាន់រៀល |
|---|---:|---:|
| **ទ្រព្យសកម្ម** | | |
| **ទ្រព្យសកម្មរយៈពេលវែង** | | |
| ទ្រព្យ រោងចក្រ និងបរិក្ខារ | ៣.២៥៣.៣៥៣.៩៥២ | ២.៨០៨.០៨៨.២១៨ |
| ទ្រព្យសកម្មអរូបិយ | ៥២០.៥០៨ | ៦៨៧.១០២ |
| ទ្រព្យសកម្មរយៈពេលវែងផ្សេងៗ | - | - |
| | **៣.២៥៣.៨៧៤.៤៦០** | **២.៨០៨.៧៧៥.៣២០** |
| **ទ្រព្យសកម្មចរន្ត** | | |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូល | ១.០៥១.៩៨៨.៥០៤ | ៩២៣.៦០៨.៤២១ |
| គណនីអតិថិជន និងគណនីត្រូវទទួលផ្សេងៗ | ៥៤១.១៣៧.០២២ | ៥០១.២២១.៩៨៣ |
| សន្និធិ | ២៣២.៩៥១.៨៧៣ | ២០២.១៩១.៦២១ |
| | **១.៨២៦.០៣៧.៣៩៩** | **១.៦២៧.០២២.០២៥** |
| **ទ្រព្យសកម្មសរុប** | **៥.០៧៩.៩១១.៨៥៩** | **៤.០៣៥.៧៩៧.៣៤៥** |
| **មូលធន** | | |
| ដើមទុន | ៧២៩.២៣១.៦១៥ | ៦៨៤.០១៨.០៦២ |
| ប្រាក់ចំណេញរក្សាទុក | ១.៤៧០.៦៨៨.៥៣៥ | ១.១១៧.០១១.៧៤២ |
| | **២.១៩៩.៩១៦.១៥០** | **១.៨០១.០២៩.៨០៤** |
| **ទ្រព្យអកម្ម** | | |
| **បំណុលរយៈពេលវែង** | | |
| ប្រាក់កម្ចី | ១.៨៨៩.២០៧.៤៩១ | ១.៥៣៩.៦៦៦.២២៧ |
| ប្រាក់កក់របស់អតិថិជន | ១៧៨.៨៧១.៦៧៥ | ១៣៥.៤៩៦.២៦៣ |
| សំវិធានធនសម្រាប់សោធននិវត្តន៍ | ៣.១៥០.១៩១ | ២.៦៧៦.៧១២ |
| បំណុលពន្ធពន្យារ, សុទ្ធ | ២៧.៥៧២.៧៩៨ | ១៩.៩៨៦.៨៦៩ |
| | **២.០៩៨.៨០២.១០៥** | **១.៦៩៧.៨២៦.០៧១** |
| **បំណុលចរន្ត** | | |
| គណនីអ្នកផ្គត់ផ្គង់ និងគណនីត្រូវទូទាត់ផ្សេងៗ | ៦២៧.៦៣៦.៣៦៦ | ៤០១.៦៧៨.៥៣៨ |
| ប្រាក់កម្ចី | ៨៦.៥៨៩.៧៦១ | ៧៩.៩២៦.៣៧០ |
| ពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំត្រូវទូទាត់ | ៦៦.៩៦៧.៤៧៧ | ៥៥.៣៣៦.៥៦២ |
| | **៧៨១.១៩៣.៦០៤** | **៥៣៦.៩៤១.៤៧០** |
| **បំណុល និងមូលធនសរុប** | **៥.០៧៩.៩១១.៨៥៩** | **៤.០៣៥.៧៩៧.៣៤៥** |

**អគ្គិសនីកម្ពុជា**
**របាយការណ៍លទ្ធផល**
សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០១៥

| | ២០១៥<br>ពាន់រៀល | ២០១៤<br>ពាន់រៀល |
|---|---|---|
| **ចំណូល** | | |
| ចំណូលពីការលក់ថាមពលអគ្គិសនី | ៣.៧៦៣.៦២៩.២៤១ | ២.៩៥៨.២៧៤.៤៤៥ |
| ចំណូលពីការតភ្ជាប់បណ្តាញអគ្គិសនី | ៣៤.២៩៨.១១២ | ៣៩.៥៤៤.៧០៩ |
| ចំណូលផ្សេងៗ | ១៥.៧២២.០៩០ | ១៥.៣៩២.១៦៣ |
| | **៣.៨១៣.៦៤៩.៤៤៣** | **៣.០១៣.២១១.៣១៧** |
| **ចំណាយប្រតិបត្តិការ** | | |
| ការទិញថាមពល | (២.៨២០.៩៨៥.០៧៨) | (២.២៤៣.៨៦៦.៤៩២) |
| ចំណាយថ្លៃប្រេង | (៦.៩២៧.២៦៧) | (២៩.៤៧១.៧៨៥) |
| ចំណាយលើពន្ធនាំចូល | (២៩.០៦៥.៦៣០) | (៣៣.៩៦៣.១៨១) |
| ចំណាយលើប្រាក់បៀវត្សរ៍ និងអត្ថប្រយោជន៍ផ្សេង | (១៥៣.១៧២.៧១៣) | (១២៥.៧២៦.៩៨៣) |
| ចំណាយប្រតិបត្តិការផ្សេងៗ | (២១៤.២៨៧.២៩៣) | (៧៧.៨៩៤.០១៥) |
| រំលស់លើទ្រព្យពោងចក្រ និងបរិក្ខារ | (៨២.៤៦៨.៨៨៣) | (៧២.០៨១.៣៣៤) |
| រំលស់លើទ្រព្យសកម្មអរូបិយ | (១៩៥.៥១២) | (១៥៧.២៦១) |
| **ចំណេញប្រតិបត្តិការ** | **៥០៦.៥៤៧.៤៦៧** | **៤៣០.១០០.២៦៦** |
| ចំណាយហិរញ្ញវត្ថុ-សុទ្ធ | (៣៩.៦៨២.៨៤៩) | (៤៩.៥១៣.៦០៤) |
| **ប្រាក់ចំណេញមុនដកពន្ធ** | **៤៦៦.៨៦៤.៦១៨** | **៣៨០.៥៨៦.៦៦២** |
| ពន្ធលើប្រាក់ចំណេញ | (៩៨.១០៨.២៧២) | (៧៨.៩១៥.៦៩១) |
| **ប្រាក់ចំណេញសុទ្ធ សម្រាប់ការិយបរិច្ឆេទ/ចំណូលរួមសរុប** | **៣៦៨.៧៥៦.៣៤៦** | **៣០១.៦៧០.៩៧១** |

# អគ្គិសនីកម្ពុជា
## របាយការណ៍លំហូរសាច់ប្រាក់
សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០១៥

| | ២០១៥<br>ពាន់រៀល | ២០១៤<br>ពាន់រៀល |
|---|---|---|
| **លំហូរទឹកប្រាក់ពីសកម្មភាពប្រតិបត្តិការ** | | |
| ប្រាក់ចំណេញប្រចាំឆ្នាំ | ៣៦៨.៧៥៦.៣៤៦ | ៣០១.៦៧០.៩៧១ |
| និយ័តកម្មលើ: | | |
| ចំណាយរំលស់ | ៨២.៦៦៣.៩៩៥ | ៧២.២៣៨.៥៩៥ |
| ចំណេញ ឬខាតពីការប្តូររូបិយប័ណ្ណបរទេស | (៣១.៥៧១.៨៩៩) | ១៤,១១៧,៨៤៨ |
| ខាតលើការលក់ទ្រព្យ រោងចក្រ និងបរិក្ខារ | ១២.៨០៨.២៣៩ | ៦.២៨៣.៨១៤ |
| ចំណាយការប្រាក់ | ៥៥.០០១.៦៣៥ | ៥១.៩១៩.៤២៧ |
| ចំណាយលើពន្ធប្រាក់ចំណេញ | ៩៨.១០៨.២៧២ | ៧៨.៩១៥.៦៩១ |
| សំវិធានធនបន្ថែមលើគណនីអាក្រក់ និងជាប់សង្ស័យ | ១.៥៣៥.៩៣០ | ៩២៧.៣២៦ |
| សំវិធានធនសម្រាប់អត្ថប្រយោជន៍ចូលនិវត្តន៍ | ៤៧៣.៤៧៩ | ៨១.១៤៨ |
| សំវិធានធនសម្រាប់សន្និធិខូច | ៤.៧០០.៤៤៩ | ៣.២៣៤.៥៣៦ |
| | ៥៩២.៤៧៦.៤៤៦ | ៥២៩.៣៨៩.៣៥៦ |
| ប្រែប្រួលនៃ: | | |
| គណនីអតិថិជន និងគណនីត្រូវទទួលផ្សេងៗ | (៨.១៩៤.៣៧៧) | ១៩៤.១៦០.០២៧ |
| សន្និធិ | (១៤២.២០៨.៩៦៨) | (៩៩.៩៦០.២២៥) |
| ទ្រព្យសកម្មរយៈពេលវែងផ្សេងៗ | - | ១៩២.២៥១.៥២៨ |
| គណនីអ្នកផ្គត់ផ្គង់ និងគណនីត្រូវទូទាត់ផ្សេងៗ | ២២៣.៣៥៧.៩១២ | (១៨៦.៧៣៥.៥៣៣) |
| ប្រាក់កក់របស់អតិថិជន | ៤៣.៣៧៥.៤១២ | ៣២.២៦៥.៧៣០ |
| សាច់ប្រាក់សុទ្ធទទួលបានពីប្រតិបត្តិការ | ៧០៨.៨០៦.៤២៥ | ៦៦១.៣៧០.៨៨៣ |
| ការប្រាក់បានបង់ | (៥២.៤០១.៧១៩) | (៨២.៩៧៨.៧២២) |
| ពន្ធបានបង់ | (៧៨.៨៩១.៤២៨) | (៧៦.៣៣០.៤៨៩) |
| **សាច់ប្រាក់សុទ្ធទទួលបានពីសកម្មភាពប្រតិបត្តិការ** | **៥៧៧.៥១៣.២៧៨** | **៥០២.០៦១.៦៧២** |

## អគ្គិសនីកម្ពុជា
## របាយការណ៍លំហូរសាច់ប្រាក់ (ត)
សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០១៥

| | ២០១៥<br>ពាន់រៀល | ២០១៤<br>ពាន់រៀល |
|---|---|---|
| **លំហូរទឹកប្រាក់ពីសកម្មភាពវិនិយោគ** | | |
| ការទិញ ទ្រព្យ រោងចក្រ និងបរិក្ខារ | (៣៩៥.០៩៦.១៥១) | (៣០៨.០៥៥.០២៩) |
| ការទិញ ទ្រព្យអរូបី | (២៨.៩១៨) | (៧២៣.៩៦៣) |
| សាច់ប្រាក់ទទួលបានពីការលក់ទ្រព្យ រោងចក្រ និងបរិក្ខារ | ៩៦.៦៦៤ | ២៩៦.២៦៤ |
| **សាច់ប្រាក់សុទ្ធប្រើប្រាស់ក្នុងសកម្មភាពវិនិយោគ** | **(៣៩៥.០២៨.៤០៥)** | **(៣០៨.៤៨២.៧២៨)** |
| **លំហូរទឹកប្រាក់ពីសកម្មភាពហិរញ្ញប្បទាន** | | |
| សាច់ប្រាក់ទទួលបានពីប្រាក់កម្ចី | ៣០.១៧២.៣៨៧ | ៧៦.២២២.៩៣២ |
| ការទូទាត់សងប្រាក់កម្ចី | (៨៦.២៥៣.១១៣) | (១១៧.០០៣.៤០៩) |
| ជំនួយដែលទទួលបាន | ១.៩៣៥.៩៣៦ | (១៤៦.០១២) |
| **សាច់ប្រាក់សុទ្ធប្រើប្រាស់ក្នុងសកម្មភាពហិរញ្ញប្បទាន** | **(៥៤.១៤៤.៧៩០)** | **(៤០.៩២៦.៤៨៩)** |
| **ការកើនឡើងសុទ្ធនៃសាច់ប្រាក់ និងសាច់ប្រាក់សមមូល** | ១២៨.៣៤០.០៨៣ | ១៥២.៦៥២.៤៥៥ |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូលនាដើមការិយបរិច្ឆេទ** | **៩២៣.៦០៨.៤២១** | **៧៧០.៩៥៥.៩៦៦** |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូលនាចុងការិយបរិច្ឆេទ** | **១.០៥១.៩៤៨.៥០៤** | **៩២៣.៦០៨.៤២១** |

**អគ្គិសនីកម្ពុជា**

អគារលេខ ២ ផ្លូវព្រះអង្គយុគន្ធរ( ១៩ ) សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ
រាជធានីភ្នំពេញ ប្រទេសកម្ពុជា
ទូរស័ព្ទ : ៨៥៥ ២៣ ៧២៤ ៧៧១
ទូរសារ : ៨៥៥ ២៣ ៤២៦ ០១៨
អ៊ីម៉ែល : info@edc.com.kh
គេហទំព័រ : www.edc.com.kh